ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ នៅខេត្តឧត្តរមានជ័យ

## The Situation of Teacher Allocation and Utilization at Lower Secondary School in Oddarmeanchey Province

ដោយ/By

វិន សុធី/VIN SOTHY

ដើម្បីបំពេញលក្ខខណ្ឌបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ជំនាន់ទី៣

ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ឆ្នាំសិក្សា ២០១៩ –២០២០

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth, and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ នៅខេត្តឧត្តរមានជ័យ

# The Situation of Teacher Allocation and Utilization at Lower Secondary School in Oddarmeanchey Province

**ដោយ**/By

**វិន សុធី**/VIN SOTHY

**ដើម្បីបំពេញលក្ខខណ្ឌបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ជំនាន់ទី៣**

**ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ**

**ភ្នំពេញ ២០១៩ -២០២០**

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ នៅខេត្តឧត្តរមានជ័យ

# The Situation of Teacher Allocation and Utilization at Lower Secondary School in Oddarmeanchey Province

ដោយ/By

**វិន សុធី**/VIN SOTHY

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៣**

**ឯកទេសៈ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៩-២០២០**

**សាស្ត្រាចារ្យដឹកនាំៈ ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា**

# សេចក្តីប្រកាសរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទដែលមានចំណងជើង "**ស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ នៅខេត្តឧត្តរមានជ័យ**" សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្រវគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិនៅវិទ្យាស្ថានភាពអប់រំ គឺជាស្នាដៃខ្ញុំបាទទាំងស្រុងពិតប្រាកដមែន។ ស្នាដៃនេះ ពុំទាន់ត្រូវបានប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសិក្សា សម្រាប់ទទួលបានសញ្ញាបត្រនៅវិទ្យាស្ថានជាតិនេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយ ត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះ ពិតជាស្រាវជ្រាវ និងចងក្រងដោយរូបខ្ញុំបាទប្រាកដមែន។

ថ្ងៃ..................... ខែ.............. ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី........... ខែ................. ឆ្នាំ២០២០

**ហត្ថលេខា**

**ខិន សុធី**

# លិខិតបញ្ជាក់

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** ជាសាស្ត្រាចារ្យដឹកនាំ

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

**លោក ទិន សុធី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ជំនាន់ទី៣ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ " **ស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ នៅខេត្តឧត្តរមានជ័យ**"ពិតប្រាកដមែន។

ថ្ងៃ..................... ខែ................ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី......... ខែ............ ឆ្នាំ២០២០

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា**

នាយកវិទ្យាស្ថានជាតិអប់រំ

# លិខិតបញ្ជាក់ និងទទួលស្គាល់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**វិទ្យាស្ថានជាតិអប់រំ**

លេខ:.....................វជអ

## លិខិតបញ្ជាក់ និងទទួលស្គាល់

**នាយកវិទ្យាស្ថានជាតិអប់រំ**

សូមបញ្ជាក់ និងទទួលស្គាល់ថា ៖

**លោក មិន សុធី** ជានិស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០ ពិតជាបានការពារគម្រោងស្រាវជ្រាវ និងសរសេរនិក្ខេបបទដែលមានប្រធានបទ **"ស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិក្នុងខេត្តឧត្ដរមានជ័យ"** ស្របតាមលក្ខខណ្ឌកម្មវិធីបណ្ដុះបណ្ដាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ពិតប្រាកដមែន ។

ថ្ងៃ សុក្រ ១៣កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ១១ ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត សៀង សុវណ្ណា**

# លិខិតបញ្ជាក់ និងទទួលស្គាល់

# លិខិតបញ្ជាក់ និងទទួលស្គាល់

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ ៖ ៣៣៤..... វជអ. ន៍ក

## លិខិតឧទ្ទេសនាម

យោង៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩។

បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចូលរួមវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២០ ចាប់ពីម៉ោង៨៖០០នាទី ព្រឹកតទៅ នៅមជ្ឈមណ្ឌលវប្បធម៌ **សម្តេច ហ៊ុន សែន និងលោកជំទាវ៖**

I. **គណៈកម្មការវាយតម្លៃ**

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | នាយកវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោកបណ្ឌិត នី ផ្កា | ប្រធានការិយាល័យសិក្សា | អនុប្រធាន |
| ៣ | លោក ម៉ៅ សារឿន | ប្រធានដេប៉ាតឺម៉ង់អប់រំ | សមាជិក |
| ៤ | លោកបណ្ឌិត គួយ សុគាន | គ្រូឧទ្ទេស | សមាជិក |
| ៥ | ល.ស នូ ចន្ទី | គ្រូឧទ្ទេស | សមាជិក |
| ៦ | លោក សៀង វាសនា | គ្រូឧទ្ទេស | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោកបណ្ឌិត នូវ វីរ៉ា | នាយករងវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោក ម៉ន មុនិន្ទ | ប្រធានដេប៉ាតឺម៉ង់ផែនការ | អនុប្រធាន |
| ៣ | លោក ប៉ូ ប៊ុន្តន | អនុប្រធានការិយាល័យសិក្សា | សមាជិក |
| ៤ | លោកបណ្ឌិត ឈាង សង្វាត | គ្រូឧទ្ទេស | សមាជិក |
| ៥ | លោកបណ្ឌិត អាន វ៉ូប្រាវ | គ្រូឧទ្ទេស | សមាជិក |
| ៦ | ល.ស ខែក សំណាង | គ្រូឧទ្ទេស | សមាជិក |

II. **លេខាអត់ត្រា** (កត់ត្រាមតិយោបល់គណៈកម្មការវាយតម្លៃ បូកសរុបពិន្ទុ និងបញ្ចូលមធ្យមភាគក្នុងតារាងពិន្ទុ)

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | លោក ចាប រតនា | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក លន លីណា | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | ល.ស សុខ វណ្ណា | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោក ឡុច ចាន់ថន | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក ចាន់ ធឿន | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | លោក ម៉ែន សុខសុន្ទី | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

III. **អ្នកសម្របសម្រួល** (រៀបចំលិខិតបទង្ហាន ដំណើរការកម្មវិធី និងបូកសរុបរបាយការណ៍)

| | | | |
|---|---|---|---|
| ១ | លោក លឹម វ៉ាន់ | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |

ថ្ងៃ ពុធ ៤រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

- នាយក នាយករង នាយិការងដេអ "ដើម្បីជ្រាបជាព័ត៌មាន និងអនុវត្ត"
- ប្រធានដេប៉ាតឺម៉ង់-ការិយាល័យក្រោមឱវាទដេអ "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ៖ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការដេអ

# មូលន័យសង្ខេប

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីស្វែងយល់ពីការកែប្រែរបស់គណៈគ្រប់គ្រងអង្គភាពនីមួយៗលើការគ្រប់គ្រង និងចែកភារកិច្ចបុគ្គលិកម្នាក់ៗតាមតួនាទី និងនិយាមគរុកោសល្យ។ ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងនៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តឧត្តរមានជ័យ ហើយអ្នកចូលរួមក្នុងការស្រាវជ្រាវមានៈ គណៈគ្រប់គ្រងអង្គភាព លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ ការសិក្សាស្រាវជ្រាវនេះ ត្រូវបានរៀបចំឡើងដោយវិភាគទិន្នន័យតាមបែបគុណវិស័យនិងបរិមាណវិស័យតាមរយៈការប្រើកម្រងសំណួរសម្ភាសន៍និងកម្រងសំណួរបំពេញ។ លទ្ធផលនៃការសិក្សា បានបង្ហាញឱ្យឃើញថាសាលាមធ្យមសិក្សាបឋមភូមិមួយចំនួន ជួបប្រទះនូវបញ្ហាប្រឈមជាច្រើននៅក្នុងអង្គភាព ដោយសារតែការប្រើប្រាស់និងបែងចែកបុគ្គលិកទៅតាមតួនាទី និងម៉ោងបង្រៀនរបស់បុគ្គលិកម្នាក់ៗ។ បញ្ហាទាំងនោះរួមមានការខ្វះគ្រូតាមឯកទេសមួយចំនួន គ្រូផ្ទេរចេញ និងសាលាខ្លះមានគ្រូលើសជាដើមជាពិសេសនៅទីប្រជុំជន ដែលមានគ្រូផ្ទេរចូលច្រើន។ សរុបសេចក្ដីមក ការបំណែងចែកភារកិច្ចគ្រូបង្រៀន នៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តឧត្តរមានជ័យ មិនទាន់មានលក្ខណៈត្រឹមត្រូវតាមនិយាមទាំងស្រុង នៅឡើយ។ មានកត្តាមួយចំនួនជាមូលហេតុនាំឲ្យការប្រើប្រាស់បុគ្គលិកមិនត្រឹមត្រូវតាមនិយាមគរុកោសល្យ និង មិនចំទិសដៅផងដែរ។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ សូមក្រាបថ្វាយបង្គំគោរព លើកម្រាមទាំងដប់ថ្លែងអំណរគុណ ចំពោះលោកអ្នកមានគុណទាំងអស់ដែលបានជួយជ្រោមជ្រែង រួមចំណែកលះបង់ពេលវេលា ក្នុងការចងក្រងនិក្ខេបបទនេះឡើង។ ជាបឋម ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់លោកឪពុក អ្នកម្តាយ និងក្រុមគ្រួសាររបស់ខ្ញុំ ជាទីស្រឡាញ់ ដ៏ស្មោះស្ម័គ្របំផុតអស់ពីបេះដូង និងចិត្តដែលបានផ្តល់កំណើត និងខិតខំរកស៊ីចិញ្ចឹមបីបាច់ថែរក្សា និងផ្តល់ថវិកាទំនុកបម្រុងក្នុងការរៀនសូត្រ ព្រមទាំងលើកទឹកចិត្តដល់ខ្ញុំរហូតមកដល់បច្ចុប្បន្ននេះ។ ខ្ញុំបាទសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ **ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំដែលមានគំនិតផ្តួចផ្តើមបើកវគ្គបណ្តុះបណ្តាលនេះឡើង ដើម្បីពង្រឹង និងពង្រីកសមត្ថភាពគុណភាពគណៈគ្រប់គ្រងសាលាឲ្យសមស្របទៅនិងស្តង់ដាអាស៊ាន។ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ **ឯកឧត្តមបណ្ឌិត ជ័យ សារិន លោកបណ្ឌិត នួន វីរ៉ា លោកបណ្ឌិត នី រដ្ឋា** និង **លោកសាស្ត្រចារ្យ ចាប រតនា** ព្រមទាំងគ្រូឧទ្ទេសទាំងអស់ នៃវិទ្យាស្ថានជាតិអប់រំ ដែលបានយកចិត្តទុកដាក់បង្ហាត់បង្ហាញនិងផ្តល់មេរៀនឲ្យយើងខ្ញុំ នូវការណែនាំ ផ្តល់មតិយោបល់ល្អៗ ពីរបៀបរៀបចំកម្រងសំណួរ ការជ្រើសរើសសំណាកគំរូ ដើម្បីធ្វើការសម្ភាស ជាពិសេសជំរុញឲ្យខ្ញុំខិតខំប្រឹងប្រែងរៀនសូត្រ ដើម្បីសម្រេចបាននូវការសរសេរនិក្ខេបបទនេះឡើងប្រកបដោយជោគជ័យ និងជាទីមោទនភាពខ្ពស់បំផុត។ សូមថ្លែអំណរគុណ លោកសាស្ត្រាចារ្យ នៅក្រសួងអប់រំ យុវជន និងកីឡា និងសាស្ត្រាចារ្យទាំងអស់នៃវិទ្យាស្ថានជាតិអប់រំដែលបានខិតខំលះបង់ទាំងកម្លាំងកាយ ចិត្ត ក្នុងការរកវិធីសាស្ត្រល្អៗដើម្បីផ្ទេរចំណេះដឹង និងផ្តល់ការណែនាំសម្រាប់យកទៅអនុវត្តស្របតាមស្តង់ដាអាស៊ាន។ សូមថ្លែងអំណរគុណអស់ពីដួងចិត្តដល់មន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ ការិយាល័យអប់រំ យុវជននិងកីឡាស្រុកទាំងអស់ទូទាំងខេត្ត គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានផ្តល់ពេលវេលាសមរម្យ និងសហការល្អបំផុត តាមរយៈការផ្តល់ឱកាសអនុញ្ញាតឲ្យខ្ញុំបាទបានជួបសម្ភាសន៍ និងបានផ្តល់ចម្លើយតាមកម្រងសំណួរដែលបានរៀបចំរួចជាស្រេច ធ្វើឲ្យការសិក្សាស្រាវជ្រាវនេះ ទទួលបានជោគជ័យ ។ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះក្រសួងអប់រំ យុវជន និងកីឡា ដែលបានបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាង ដល់វគ្គនាយកសាលាជំនាន់ទី៣។ ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធិពរជ័យជូនចំពោះឯកឧត្តម លោកគ្រូ អ្នកគ្រូ លោក លោកស្រី នាងកញ្ញាទាំងអស់ សូមមានសុខភាពល្អបរិបូណ៌ និងទទួលបានសេចក្តីសុខចម្រើនព្រមទាំងបានជោគជ័យគ្រប់ភារកិច្ច។

# មាតិកា


សេចក្តីប្រកាសរបស់បេក្ខជន……………………………………………….. ទំព័រ i

លិខិតបញ្ជាក់ ........................................................................ ទំព័រ ii

លិខិតបញ្ជាក់ និងទទួលស្គាល់.................................................... ទំព័រ iii

លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ............... ទំព័រ iV

មូលន័យសង្ខេប…………………………………………………………. ទំព័រ V

សេចក្តីថ្លែងអំណរគុណ…………………………………………………… ទំព័រ Vi

**ជំពូកទី១ សេចក្តីផ្តើម**……………………………………………….. ទំព័រ 1

១.១.បញ្ហានៃការស្រាវជ្រាវ………………………………………………. ទំព័រ 1

១.២.សំណួរស្រាវជ្រាវ…………………………………………………….. ទំព័រ 4

១.៣.គោលបំណងនៃការស្រាវជ្រាវ……………………………………… ទំព័រ 4

១.៤.សារៈប្រយោជន៍នៃការស្រាវជ្រាវ…………………………………. ទំព័រ 4

១.៥.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ……………………….. ទំព័រ 4

១.៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ………………………………………… ទំព័រ 5

**ជំពូកទី២ រំលឹកទ្រឹស្តី**…………………………………………………… ទំព័រ 6

២.១.សេចក្តីផ្តើម…………………………………………………………... ទំព័រ 6

២.២.និយមន័យ និងពាក្យគន្លឹះ……………………………………………. ទំព័រ 7

ក.តួនាទីគ្រូបង្រៀន…………………………………………………… ទំព័រ 7

ខ.ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន……………………………………………. ទំព័រ 8

២.៣.ការគ្រប់គ្រង និងការបែងចែកធនធានមនុស្សក្នុងវិស័យអប់រំ……… ទំព័រ 8

២.៤.គោលនយោបាយស្តីពីគ្រូបង្រៀន……………………………………. ទំព័រ 9

២.៥.តួនាទី និងភារកិច្ចគ្រូបង្រៀននៅកម្ពុជា………………………………. ទំព័រ 11

២.៦.ក្រមសីលធម៌ វិជ្ជាជីវៈគ្រូបង្រៀន………………………………………. ទំព័រ 12

២.៧.ក្រមសីលធម៌ វិជ្ជាជីវៈនាយកសាលារៀន……………………………… ទំព័រ 12

២.៨.តួនាទី និងភារកិច្ចនាយកសាលានៅកម្ពុជា…………………………. ទំព័រ 13

២.៨.១.ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន…………………………………. ទំព័រ 14

២.៨.២.ប្រសិទ្ធភាពនៃការពង្រាយគ្រូ……………………………………….. ទំព័រ 14

២.៨.៣.ការលើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀន………………………... ទំព័រ 15

២.៩.បញ្ហាប្រឈម ចំពោះការបែងចែកធនធានមនុស្ស……………………. ទំព័រ 16

២.១០.ចំនួនគ្រូបង្រៀន៖ ចំណោល និងបញ្ហាប្រឈម…………………….. ទំព័រ 17

**ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ**…………………………………… ទំព័រ 18

៣.១.ដែនកំណត់ និងវិសាលភាព……………………………………………….. ទំព័រ 18
៣.២.ទីតាំងនៃការស្រាវជ្រាវ………………………………………………….. ទំព័រ 18
៣.៣.វិធីសាស្ត្រជ្រើសរើសអ្នកពាក់ព័ន្ធក្នុងការប្រមូលទិន្នន័យ………….. ទំព័រ 18
៣.៤.កម្រងសំណួរសម្រាប់គ្រូ…………………………………………….. ទំព័រ 18
១.កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង………………………… ទំព័រ 19
ក.ស្ថានភាពទូទៅរបស់គណៈគ្រប់គ្រងអនុវិទ្យាល័យ…………… ទំព័រ 19
ខ.ព័ត៌មានទាក់ទងការគ្រប់គ្រងនិងបែងចែកភារកិច្ចបុគ្គលិក-
របស់នាយកអនុវិទ្យាល័យ……………………………………… ទំព័រ 19
៣.៥.វិភាគទិន្នន័យ………………………………………………………….. ទំព័រ 19
៣.៥.និតិវិធី ឬដំណើរការប្រមូលទិន្នន័យ…………………………………. ទំព័រ 20
**ជំពូកទី៤ លទ្ធផលស្រាវជ្រាវ**…………………………………………. ទំព័រ 21
៤.១ អនុ.វិទ្យាល័យទាំង ៣៦ ក្នុងខេត្តឧត្តរមានជ័យ……………………. ទំព័រ 21
៤.២ វិទ្យាល័យហ៊ុនសែនចុងកាល់៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង…… ទំព័រ 22
៤.៣ វិទ្យាល័យហ៊ុនសែនពង្រ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង……… ទំព័រ 23
៤.៤ អនុវិទ្យាល័យជើងទៀន៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង……….. ទំព័រ 24
៤.៥ អនុវិទ្យាល័យគោកស្អាន៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង……… ទំព័រ 25
៤.៦ អនុវិទ្យាល័យ សម្តេចតេជោ ហ៊ុនសែន ចុងកាល់៖ស្ថិតិ-
សិស្ស ថ្នាក់ គ្រូ និងម៉ោង……………………………………………. ទំព័រ 27
៤.៧ វិទ្យាល័យ តេជោសែនសំរោង ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង… ទំព័រ 28
៤.៨ អនុវិទ្យាល័យ កូនក្រៀល ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង……… ទំព័រ 29
៤.៩ អនុវិទ្យាល័យ ហ៊ុនសែន រួតចំប៉ី ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង.. ទំព័រ 30
៤.១០ អនុវិទ្យាល័យ បុស្សរូ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង………… ទំព័រ 31
៤.១១ អនុវិទ្យាល័យ បន្សាយរាក់ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង…… ទំព័រ 32
៤.១២ អនុវិទ្យាល័យ គោកក្អក ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង……… ទំព័រ 33
៤.១៣.អនុវិទ្យាល័យ សូរ៉ែកគុណពោធិវង្ស ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង.. ទំព័រ 34
៤.១៤ វិទ្យាល័យ បន្ទាយអំពិល ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង……. ទំព័រ 35
៤.១៥ វិទ្យាល័យ អំពិល ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង…………… ទំព័រ 36
៤.១៦ អនុវិទ្យាល័យ ឈូក ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង………… ទំព័រ 37
៤.១៧ អនុវិទ្យាល័យ គោកខ្ពស់ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង…… ទំព័រ 38
៤.១៨ អនុវិទ្យាល័យ បេង ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង………… ទំព័រ 39
៤.១៩ អនុវិទ្យាល័យ គោកឪឡោក ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង… ទំព័រ 40
៤.២០ អនុវិទ្យាល័យ ប្រាសាទបី ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង…… ទំព័រ 41
៤.២១ វិទ្យាល័យ អន្លង់វែង ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង………. ទំព័រ 42

៤.២២ វិទ្យាល័យ តេជោហ៊ុនសែន ត្រពាំងតាវ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង- ទំព័រ 43

៤.២៣ អនុវិទ្យាល័យ ហ៊ុនសែន ត្រពាំងប្រីយ៍ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង- ទំព័រ 44

៤.២៤ អនុវិទ្យាល័យ លំទង ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង………. ទំព័រ 45

៤.២៥ អនុវិទ្យាល័យថ្លាត ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង…………. ទំព័រ 46

៤.២៦ អនុវិទ្យាល័យ រំចេក ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង……….. ទំព័រ 47

៤.២៧ អនុវិទ្យាល័យសម្តេចតេជោ អូស្រមរ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង… ទំព័រ 48

៤.២៨ អនុវិទ្យាល័យ ហ៊ុនសែនទួលតាសេក ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង... ទំព័រ 49

៤.២៩ អនុវិទ្យាល័យ ទំនប់ដាច់ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង…… ទំព័រ 50

៤.៣០ អនុវិទ្យាល័យ ហ៊ុនសែនអូក្រូច ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង…… ទំព័រ 51

៤.៣១ អនុវិទ្យាល័យ អូរស្វាយ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង……. ទំព័រ 52

៤.៣២ អនុវិទ្យាល័យ ផ្អាវ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង…………. ទំព័រ 53

៤.៣៣ អនុវិទ្យាល័យ ព្រះប្រឡាយ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង… ទំព័រ 54

៤.៣៤ អនុវិទ្យាល័យ ជ័យនិវត្តន៍ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង…… ទំព័រ 55

៤.៣៥ អនុវិទ្យាល័យ បាក់ងន្លូង ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង…… ទំព័រ 56

៤.៣៦ អនុវិទ្យាល័យ តេជោ ថ្មល់បំបែក ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង…. ទំព័រ 57

៤.៣៧ អនុវិទ្យាល័យ ដីក្រហម ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង……. ទំព័រ 58

**ជំពូកទី៥ ការសន្និដ្ឋាន និងសំណូមពរ**…………………………. ទំព័រ 60

៥.១.ការសន្និដ្ឋាន……………………………………………………. ទំព័រ 60

៥.២.សំណូមពរ……………………………………………………….. ទំព័រ 60

# ជំពូកទី១    សេចក្តីផ្តើម

## ១.១ បញ្ហានៃការស្រាវជ្រាវ

នៅក្នុងពិភពលោកយើងនេះមិនថាប្រទេសណាមួយនោះទេ គឺការអប់រំពិតជាសំខាន់ខ្លាំងណាស់ ព្រោះវិស័យនេះគឺជាឆ្អឹងខ្នងសម្រាប់ប្រទេសជាតិ។ ការអប់រំរបស់ពិភពលោក នាពេលបច្ចុប្បន្ននេះ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយសារការសិក្សាតាមប្រព័ន្ធបច្ចេកវិទ្យាទំនើបៗ ស្របតាមសម័យកាលសាកលភាវូបនីយកម្មនៃពិភពលោកកំពុងរីកចម្រើន។ យ៉ាងណាមិញ ប្រទេសកម្ពុជាដែលជាប្រទេសកំពុង អភិវឌ្ឍន៍ ក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំងផងដែរពីការអប់រំ ហើយវិស័យអប់រំនៅកម្ពុជានាពេលបច្ចុប្បន្នមានការរីចម្រើនគួរឲ្យកត់សម្គាល់។

ការអភិវឌ្ឍធនធានមនុស្ស ដែលជាដើមចម ឈានទៅរកការអភិវឌ្ឍជាតិឲ្យមានការរីកចម្រើនលើគ្រប់វិស័យ គឺមានសារៈសំខាន់ខ្លាំងណាស់។ ការអប់រំ មិនត្រឹមតែជួយប្រទេសជាតិ ឲ្យរីកចម្រើននោះទេ វាថែមទាំងធ្វើឲ្យពិភពលោកមានសន្តិភាព សុវត្ថិភាពទាំងការដើរហើរ និងរបស់របរប្រើប្រាស់ផ្សេងៗជាពិសេសសុវត្ថិភាពចំណីអាហារដែលផ្តល់នូវសុខភាពល្អគ្មានជាតិគីមី។

ប្រទេសជាតិមួយរីកចម្រើនទៅបាន អាស្រ័យទៅលើសម្បទាពេញលេញ នៃធនធានរបស់ប្រទេសនោះ ពោលគឺមានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទាល្អ។ ក្នុងន័យនេះ គ្រូបង្រៀនដើរតួនាទីសំខាន់ណាស់ ព្រោះពួកគេជាអ្នកផលិតធនធានមនុស្ស សម្រាប់ឲ្យទៅបម្រើការងារនៅគ្រប់វិស័យក្នុងសង្គម ហើយក៏ជាវិស្វករនៃព្រលឹងដែលរដ្ឋមានទំនុកចិត្តឲ្យបង្រៀន និងអប់រំ យុវជន យុវនារីដែលជាសរសរទ្រូងដ៏មានតម្លៃមិនអាចកាត់ថ្លៃបានចំពោះគ្រួសារ និងសង្គមជាតិទាំងមូល។ អនាគតប្រទេសជាតិទាំងមូល គឺពឹងពាក់ទាំងស្រុងទៅលើគ្រូបង្រៀន។ គ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ និងទេពកោសល្យ ក្នុងការបង្ហាត់បង្រៀន គឺជាកត្តាដ៏សំខាន់បំផុត ក្នុងការធ្វើឲ្យសម្រេចបាននូវគោលនយោបាយអប់រំរបស់កម្ពុជាដែលរួមមាន៖ ធានាឲ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ក៏ដូចជាធានាភាពស័ក្តិសិទ្ធ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ (ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨)។

បច្ចុប្បន្នក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកែទម្រង់ជាច្រើន ដើម្បីធានានូវការពង្រឹងគុណភាពអប់រំ

ឲ្យសមស្របទៅនឹងនិន្នាការអប់រំក្នុងតំបន់ និងពិភពលោកនាសតវត្សទី២១។ ក្នុងន័យនេះ តម្រូវការ នៃការប្រើប្រាស់គ្រូបង្រៀនឲ្យមានប្រសិទ្ធភាព មានសារៈសំខាន់ណាស់ ដល់គុណភាពអប់រំ ហើយពាក់ព័ន្ធទៅនឹងកត្តាជាច្រើនដូចជា៖ ការបង្កើនជាតុចូល និងការបន្ថយនិយាមសិស្ស ថ្នាក់ ឬសិស្ស គ្រូជាដើម។ ការបែងចែកគ្រូបង្រៀនពិតជាមានសារៈសំខាន់ណាស់ ក្នុងការធានាបាននូវគុណភាពគុណវុឌ្ឍិ និងស្របទៅ តាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជារាជរដ្ឋាភិបាល ដែលបានយកចិត្តទុក ដាក់លើវិស័យអប់រំ។ ការប្រើប្រាស់គ្រូបង្រៀនចំគោលដៅ ស្របតាមច្បាប់ គឺសិស្សទទួលបានការអប់រំ សម្បូរបែប និងទទួលបានចំណេះ ជំនាញច្បាស់លាស់ ពីគ្រូបង្រៀនដែលមានគរុកោសល្យត្រឹម

ត្រូវស្របតាមច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ហើយឋានៈគ្រូបង្រៀន ឬសង្គមត្រូវឲ្យតម្លៃខ្ពស់ទៅលើគ្រូបង្រៀន។ ការពង្រីកធនធានតាមរយៈការផ្តត់ផ្គង់ពីប្រភពផ្សេងៗ ក៏ដូចជាការជ្រើសរើសមនុស្សមានសមត្ថភាពឲ្យចូលធ្វើគ្រូបង្រៀន អាចធ្វើទៅបានតាមរយៈការបង្កើនប្រាក់លើកទឹកចិត្ត និងប្រាក់គាំទ្រជាពិសេសដល់អ្នកដែលស្ម័គ្រចិត្ត ទៅបង្រៀននៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក ព្រោះគ្រូបង្រៀនជាមូលដ្ឋានគ្រឹះនៅក្នុងដំណើរការបង្ហាត់បង្រៀន ហើយគុណភាពនៃការបង្រៀនគឺជាកត្តាដែលកំណត់ឲ្យគុណភាពនៃការអប់រំ ដោយសារគ្រូបង្រៀន គឺជាកត្តាចម្បងដែលជះឥទ្ធិពលទៅដល់លទ្ធផលសិក្សារបស់សិស្ស និងគុណភាពនៃការអប់រំ។

ជាភ័ព្វសំណាងអាក្រក់ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលមានរយៈពេលបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ ដែលគ្រប់គ្រងដោយពួកខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់១៩៧៩ មានធនធានមនុស្ស ប្រហែលប្រមាណ៨០ភាគរយ ត្រូវបានកាប់សម្លាប់ចោល ជាពិសេសគ្រូបង្រៀន គ្រូពេទ្យ និងមន្ត្រីរាជការផ្សេងៗទៀត ដោយរបបនេះចាត់ទុកគ្រូបង្រៀន និងគ្រូពេទ្យ ជាមុខសញ្ញាដែលនាំឲ្យមានចលនាប៉ះបោរ ហើយក៏ជាមុខសញ្ញាដែលត្រូវកម្ទេចចោល។ ក្នុងរបបនោះ ប្រព័ន្ធអប់រំទាំងមូលត្រូវបានបិទទាំងស្រុង ហេដ្ឋារចនាសម្ព័ន្ធវិស័យអប់រំទាំងមូល ត្រូវបានប្រែក្លាយទៅជាមន្ទីរឃុំឃាំង ជង្រុកស្រូវ កន្លែងធ្វើទារុណកម្ម ឬក៏ជាឃ្លាំងសម្រាប់ទុកដាក់របស់របរចាស់ៗ។ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ គឺក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ វិស័យសិក្សាធិការជាតិបើកទ្វារឡើងវិញ។ កុមារចុះឈ្មោះចូលរៀនយ៉ាងច្រើនសន្ធឹកសន្ធាប់ ហើយសាលារៀនជាច្រើនត្រូវបានស្ថាបនា សាងសង់ថ្មី និងបើកដំណើរការឡើងវិញ។ គ្រូបង្រៀនជាច្រើនក៏ត្រូវបានជ្រើសរើស និងធ្វើការបណ្តុះបណ្តាលតាមរូបមន្តផ្សេងៗដូចជាប្រព័ន្ធ ៩+២ ១២+២ ១២+៤ ប្រព័ន្ធមួយខែកន្លះពីរដងពេលរាំកង ប្រព័ន្ធផ្ទៃក្នុង និងបច្ចុប្បន្នតាមប្រព័ន្ធពន្លឿន ក្រោមពាក្យស្លោក" អ្នកចេះច្រើន បង្រៀនអ្នកចេះតិច ហើយអ្នកចេះតិច បង្រៀនអ្នកមិនចេះសោះ" ត្រូវបានយកមកអនុវត្តនៅទូទាំង ប្រទេស។ ទន្ទឹមនឹងនេះដែរ ក្រសួងក៏បានប្រមូលផ្តុំធនធានមនុស្សដែលនៅសេសសល់ពីការសម្លាប់ ក្នុង របបខ្មែរក្រហមដើម្បីបញ្ចូលក្នុងប្រព័ន្ធអប់រំជាបន្តបន្ទាប់នៅទូទាំងប្រទេស។ ចំណែកឯការបែងចែកគ្រូបង្រៀននាពេលនោះក៏មិនបានគិតដល់និយាមគ្រូ សិស្ស ថ្នាក់ បន្ទប់ និងគុណវុឌ្ឍិគ្រូបង្រៀនឲ្យបានត្រឹមត្រូវ និងហ្មត់ចត់ផងដែរ ដែលធ្វើឲ្យមានបញ្ហាជាច្រើនរហូតមកដល់ពេលបច្ចុប្បន្ននេះ។ បញ្ហាផ្គត់ផ្គង់ និងតម្រូវការគ្រូបង្រៀនដែលស្មើឡើងជាមូលដ្ឋាន ក៏មិនទាន់ច្បាស់លាស់តាមលក្ខណៈជាក់ស្តែង ដោយសារតែការបំប៉ោង ឬបន្ថយទិន្នន័យនៃការស្នើសុំ និងផ្តល់ឲ្យ ដែលការស្នើសុំពេលខ្លះខុសឯកទេសជំនាញដែលត្រូវការ។ ដូច្នេះ វិធីគណនាតម្រូវការគ្រូនៅបឋមសិក្សា និងអនុវិទ្យាល័យមិនទាន់ឯកភាពគ្នាឬមិនទាន់ស្របតាមតម្រូវការ ជាហេតុដែលនាំឲ្យមានការខ្វះគ្រូ ឬលើសគ្រូតាមឯកទេសនៅអនុវិទ្យាល័យ។ មុខវិជ្ជាខ្លះខ្វះនៅតែខ្វះ ហើយមុខវិជ្ជាលើសនៅតែបន្តលើសដដែល។ កង្វះខាតប្រព័ន្ធព័ត៌មានវិទ្យាអត្រាវិចរិល អត្រាគ្រូវិលចូលក្នុងប្រព័ន្ធវិញ អត្រាគ្រូបង្រៀនចូលនិវត្តន៍ អត្រាកំណើនសិស្សក្នុងតំបន់ និងបទប្បញ្ញត្តិមិនសមស្រប ធ្វើឲ្យមានបញ្ហាលើស ឬខ្វះគ្រូបង្រៀននៅតាមតំបន់។ ការព្យាករណ៍ពីតម្រូវការគ្រូបង្រៀនតាមវិធីការធ្វើជាចំណោលក៏ជាគន្លឹះ និងជាដំណោះស្រាយមួយដោយសមហេតុសមផលមួយ ក្នុងការដឹងពីតម្រូវការគ្រូរយៈពេលវែង។ ក្រមសីលធម៌ ក្នុងការអនុវត្តការងារ សមត្ថភាព មន្ត្រីគ្រប់គ្រងពុំទទួលបានការបណ្តុះបណ្តាលស្តីពីជំនាញគ្រប់គ្រងធនធានមនុស្ស

បញ្ហាអវត្តមានគ្រូ កង្វះធនធានតួនាទី និងការទទួលខុសត្រូវរួមគ្នា ទំនាក់ទំនងមិនច្បាស់លាស់លើការវាយតម្លៃ និងការសម្រេចចិត្តមិនដូចគ្នានាំឲ្យមានការគ្រប់គ្រងគ្រូបង្រៀនមិនទាន់មានប្រសិទ្ធភាពនៅឡើយ។ ទន្ទឹមនឹងនេះ គ្រូបង្រៀនដែលបានជ្រើសរើសប៉ុស្តិ៍ ដែលនៅទីក្រុង ទីប្រជុំជន និងនៅទីជនបទ ការផ្លាស់ប្តូរតាមសហព័ទ្ធ ជាពិសេសលក្ខខណ្ឌរស់នៅរបស់គ្រូបង្រៀន និងការលើកទឹកចិត្តគ្រូបង្រៀននៅមានកម្រិតដោយសារប្រាក់ខែនៅទាប ហើយគ្រូស្រីជាទូទៅមិនជ្រើសរើសប៉ុស្តិ៍នៅជនបទក៏ជាបញ្ហាប្រឈមយ៉ាងសំខាន់ផងដែរ។ប៉ុន្មានឆ្នាំនេះ ជាពិសេសនាពេលបច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំ និងបង្កើតកម្មវិធីវិក្រឹតការជាបន្តបន្ទាប់ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ និងនៅតាមអនុ ឬវិទ្យាល័យទូទាំងប្រទេស។ ទោះបីមានការរៀបចំធ្វើវិក្រឹការយ៉ាងណាក៏ដោយ ក៏សមត្ថភាពអ្នកគ្រប់គ្រងទាំងអស់នោះ នៅមានកម្រិត ពុំទាន់ឆ្លើយតបទៅនឹងការធ្វើកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា នៅឡើយ ជាហេតុធ្វើឲ្យស្ថានភាព នៃការប្រើប្រាស់ និងបែងចែកគ្រូបង្រៀនអាចជួបប្រទះបញ្ហាប្រឈមជាច្រើន ហើយក៏ជាកត្តាមួយដែលធ្វើឲ្យគុណភាព នៃការអប់រំធ្លាក់ចុះផងដែរ។ មកដល់ពេលបច្ចុប្បន្ននេះ មិនទាន់មានការសិក្សាណាមួយ បានបង្ហាញពីស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀន នៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យនានា ក្នុងប្រទេសកម្ពុជា ក្នុងគោលបំណងរកឲ្យឃើញពីស្ថានភាពជាក់ស្តែង និងបញ្ហាប្រឈមនានា ដើម្បីផ្តល់យោ បល់ដល់អ្នករៀបចំធ្វើគោលនយោបាយ ក្នុងការកាត់បន្ថយនូវបញ្ហាប្រឈមទាំងនោះនៅឡើយ។

បច្ចុប្បន្ន វិស័យអប់រំនៅកម្ពុជា មានការរីកចម្រើនខ្លាំងទាំងគុណភាព និងបរិមាណ ដោយមានការគាំទ្រពីសហគមន៍ជាតិ អង្គការជាតិ និងអន្តរជាតិទាំងផ្នែកថវិកា និងសម្ភារៈ ដោយយកចិត្តទុកដាក់ជាសំខាន់លើវិស័យអប់រំនៅកម្ពុជា។ ទោះបីមានសមិទ្ធិផលជាច្រើន ក្រសួងសម្រេចបានក៏ដោយ ក៏នៅតែជួបប្រទះបញ្ហាជាច្រើនដែលក្រសួងកំពុងតែយកចិត្តទុកដាក់រៀបចំគោលនយោបាយ និងធ្វើកំណែទម្រង់លើ វិស័យអប់រំទាំងថ្នាក់ជាតិ និងអន្តរជាតិ។ បញ្ហាប្រឈមផ្សេងៗទាំងនោះរួមមាន៖

-ការប្រើប្រាស់គ្រូបង្រៀនបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិមួយចំនួនមិនទាន់បានត្រឹមត្រូវទៅតាមឯកទេសនៅឡើយ ព្រោះមិនទាន់បានប្រើប្រាស់គ្រូឲ្យអស់លទ្ធភាព។

-ការពង្រាយគ្រូបង្រៀនទៅតាមតំបន់ដាច់ស្រយាល និងតំបន់ជួបប្រទះការលំបាក ពុំមានតម្លាភាព និងមិនមានប្រសិទ្ធភាពនៅឡើយ

-ការអនុវត្តសេវាម៉ោងបង្រៀន និងម៉ោងបន្ថែមមិនទាន់បានត្រឹមត្រូវ ទៅតាមនិយាមកំណត់

-លំហូរចេញ ការបាត់បង់ក្របខណ្ឌ បុគ្គលិកអប់រំផ្ទេរចូលបម្រើទីចាត់ការ និងការផ្លាស់ប្តូរទីកន្លែងធ្វើការងារ ឬទៅតាមសហព័ទ្ធជាដើម

-អតុល្យភាពនៃការប្រើប្រាស់គ្រូ ការផ្គត់ផ្គង់ និងតម្រូវការបុគ្គលិកអប់រំដែលមានសមត្ថភាព តាមមុខវិជ្ជានីមួយៗ និងបច្ចេកទេសជំនាញ បំណិនជីវិត ព័ត៌មានវិទ្យា...។

-ភាពមានប្រសិទ្ធភាពនៃការធ្វើរបាយការណ៍បុគ្គលិកបង្រៀន

-អវត្តមាននៃបុគ្គលិកអប់រំ និងគុណវុឌ្ឍិរបស់បុគ្គលិកខ្លះ គឺនៅមានកម្រិតនៅឡើយដោយមិនមានឱកាសអភិវឌ្ឍសមត្ថភាពរបស់ខ្លួនឡើយ។

## ១.២ សំណួរស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើស្ថានភាព ក្នុងការប្រើប្រាស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិនៅក្នុងខេត្តឧត្តរមានជ័យ៖

១.តើស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តឧត្តរមានជ័យ ដំណើរការយ៉ាងដូចម្តេច?

២.តើការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិក្នុងខេត្តឧត្តរមានជ័យជួបបញ្ហាប្រឈមអ្វីខ្លះ?

៣.តើគណៈគ្រប់គ្រងសាលារៀនមានទស្សនៈយល់ឃើញយ៉ាងដូចម្តេច ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ដើម្បីឲ្យកាន់តែច្បាស់ និងស្វែងយល់បន្ថែមពីគុណភាព និងប្រសិទ្ធភាព ក្នុងការប្រើប្រាស់គ្រូបង្រៀននៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិក្នុងខេត្តឧត្តរមានជ័យធ្វើឲ្យអ្នកសិក្សាស្រាវជ្រាវជ្រើសរើសយកប្រធានបទរបស់ខ្លួន មកសិក្សាស្រាវជ្រាវសម្រាប់បញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ។ ការស្រាវជ្រាវនេះ មានគោលបំណងសំខាន់ៗ៣គឺ៖

១.រកឲ្យឃើញពីស្ថានភាពបច្ចុប្បន្ននៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិនៅក្នុងខេត្តឧត្តរមានជ័យ

២.កំណត់ឲ្យបាននូវបញ្ហាប្រឈមសំខាន់ៗដែលទាក់ទងទៅនឹងការប្រើប្រាស់គ្រូបង្រៀនក្នុងខេត្តឧត្តរមានជ័យ

៣.ស្វែងយល់ពីទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន លើការដោះស្រាយបញ្ហានានាដែលទាក់ទងទៅនឹងការប្រើប្រាស់គ្រូបង្រៀនក្នុងខេត្តឧត្តរមានជ័យ។

## ១.៤ សារៈប្រយោជន៍នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ពិតជាមានគុណតម្លៃ និងសារៈប្រយោជន៍សំខាន់ណាស់ សម្រាប់នាយកនាយិកាក្នុងការយកចិត្តទុកដាក់ចំពោះភារកិច្ចរបស់ខ្លួន និងបែងចែកភារកិច្ចបុគ្គលិកនៅតាមអនុវិទ្យាល័យ នានាឲ្យមានប្រសិទ្ធភាពសមស្របទៅតាមនិយាម ដែលក្រសួងបានកំណត់ ដើម្បីពង្រឹងគុណវុឌ្ឍិ និងគុណភាពអប់រំ ដោយជំរុញសាលានីមួយៗប្រើប្រាស់គ្រូបង្រៀនចំគោលដៅ ទៅតាមមុខវិជ្ជាឯកទេស និងតាមជំនាញ ក្នុងការបង្រៀន និងរៀន ប្រកបដោយគុណភាព និងសមត្ថភាព។ គុណភាពចំណេះដឹង គុណភាពបំណិន និងគុណភាពឥរិយាបថរបស់ប្រជាជននៃប្រទេសគឺត្រូវតែសមស្របទៅនឹងបរិបទសាកលភាវូបនីយកម្មពិភពលោកដែលកំពុងមានការរីកចម្រើន ពិសេសនៅក្នុងតំបន់អាស៊ាន និងនៅលើឆាកអន្តរជាតិ ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ដោយមិនចំណាយថវិកាខ្ជះខ្ជាយទៅលើបុគ្គលិកអប់រំអេសកម្ម នៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យនានានៅទូទាំងប្រទេស។

## ១.៥ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

អ្នកសិក្សាស្រាវជ្រាវសម្រេចជ្រើសរើសយកខេត្តឧត្តរមានជ័យមកសិក្សាស្រាវជ្រាវ ព្រោះខេត្តនេះជាតំបន់ដាច់ស្រយាល និងជាតំបន់ជួបការលំបាក ដែលមានសាលារៀន និងសិស្សច្រើនបង្គួរ។ ការខ្វះគ្រូបង្រៀនក៏នៅមានចំនួនច្រើនបង្គួរដែរហើយជាប់នឹងព្រំប្រទល់ប្រទេសថៃភាគខាងជើងនៃប្រទេសកម្ពុជា។ ការសិក្សាស្រាវជ្រាវនេះគឺធ្វើឡើងនៅតាមអនុវិទ្យាល័យនានា ដែលកំពុងតែដំណើរការអនុវត្តភារកិច្ចនៅក្នុងខេត្តឧត្តរមានជ័យ។ ការសិក្សាស្រាវនេះ គឺស្វែងយល់ពីទស្សនៈរបស់គណៈគ្រប់គ្រងអង្គភាព ក្នុងការបែងចែកការអនុវត្តភារកិច្ចរបស់បុគ្គលិកអប់រំម្នាក់ៗ និងស្វែងយល់ពីទិន្នន័យគ្រូបង្រៀន នៅអនុវិទ្យាល័យដែលមានគុណវុឌ្ឍិ និងតាមឯកទេសដែលសាលានីមួយៗមានជាក់ស្តែង និងស្វែងយល់ពីទិន្នន័យចំនួនថ្នាក់អនុវិទ្យាល័យ (៧,៨,៩) ដែលសាលានីមួយៗមាន និន្នន័យចំនួនម៉ោងសរុប ម៉ោងមុខវិជ្ជាឯកទេសនិយាមគ្រូ និងម៉ោងដែលកំពុងអនុវត្តជាក់ស្តែង។ ចំពោះប្រភេទសំណាកវិញ អ្នកស្រាវជ្រាវជ្រើសរើសយកតែអ្នកពាក់ព័ន្ធមួយចំនួនតែប៉ុណ្ណោះ ដែលរួមមានមន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុក និងនាយកនាយករង នាយិកា នាយិការង នៅក្នុងសាលាអនុវិទ្យាល័យមួយចំនួនក្នុងខេត្ត។ នៅក្នុងសាលាអនុវិទ្យាល័យទាំងអស់ ដូចបានរៀបរាប់ខាងលើ យើងខ្ញុំរៀបចំសំណួរតាមបែបគុណវិស័យ និងបរិមាណវិស័យដោយមានកម្រងសំណួរសម្រាប់បំពេញ និងសម្ភាសន៍។ ជាលទ្ធផលប្រមូលព័ត៌មានបានមកពីការធ្វើសម្ភាសន៍នេះ គឺដើម្បីប្រមូលទិន្នន័យ សម្រាប់សរសេរនិក្ខេបបទតែប៉ុណ្ណោះ ដោយគ្មានគោលដៅអ្វីផ្សេងឡើយ។

## ១.៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា ៥ ជំពូកធំៗរួមមានដូចខាងក្រោមនេះ៖

**ជំពូកទី១៖** សេចក្តីផ្តើម នៅក្នុងជំពូកទី១នេះរួមមាន បញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហា សំណួរស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សារៈប្រយោជន៍នៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ។

**ជំពូកទី២៖** រំលឹកទ្រឹស្តី នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានប្រមូលយកទ្រឹស្តីចាស់ៗ ពីអ្នក
និពន្ធ និងអ្នកសិក្សាស្រាវជ្រាវមុនៗដែលពាក់ព័ន្ធទៅនឹងប្រធានបទ ដើម្បីធ្វើជាគំនិត សម្រាប់ធ្វើការស្រាវជ្រាវ និងបង្កើតជាស្នាដៃថ្មីៗក្នុងនិក្ខេបបទនេះ។

**ជំពូកទី៣៖** វិធីសាស្ត្រស្រាវជ្រាវ ក្នុងជំពូកទី៣ នេះ នឹងធ្វើការបង្ហាញនូវឧបករណ៍ស្រាវជ្រាវ និងវិធី
សាស្ត្រប្រមូលទិន្នន័យ វិធីសាស្ត្រជ្រើសរើសយកសំណាក ព្រមទាំងគំរូវិធីសាស្ត្រ ក្នុងការវិភាគទិន្នន័យ។

**ជំពូកទី៤៖** លទ្ធផល និងការពិភាក្សា ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវ និងយកទិន្នន័យជាក់ស្តែង
ដែលប្រមូលបានមកវិភាគ និងធ្វើការបកស្រាយយ៉ាងលម្អិត ដើម្បីរកឲ្យឃើញពីភាពអវិជ្ជមានដែលបានចោទសួរទាំងអស់ ក្នុងចំណោទបញ្ហាស្តីពីស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តឧត្តរមានជ័យ។

**ជំពូកទី៥៖** សេចក្តីសន្និដ្ឋាន និងសំណូមពរ វាជាផ្នែកមួយដ៏សំខាន់ ដែលអ្នកសិក្សាស្រាវជ្រាវត្រូវយកមកធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគព្រមទាំងបានផ្តល់សំណូមពរមួយចំនួនក្នុងគោលបំណងចូលរួមចំណែកក្នុងការធ្វើឲ្យការអនុវត្តបំណែងចែកភារកិច្ចរបស់បុគ្គលិកអប់រំតាមសាលាអនុវិទ្យាល័យនានាក្នុងខេត្តឧត្តរមានជ័យឲ្យកាន់តែមានតម្លាភាព ប្រសិទ្ធភាព និងកាន់តែល្អប្រសើរឡើងថែមទៀត។

# ជំពូកទី២ រំលឹកទ្រឹស្តី

## ២.១ សេចក្តីផ្តើម

ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់ និងទទួលស្គាល់សារៈសំខាន់ ក្នុងការជំរុញឲ្យ វិស័យអប់រំនៅកម្ពុជាទាំងមូល អាចធ្វើការជាមួយគ្នាបាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការសង្គម និងសេដ្ឋកិច្ច។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ផ្តោតលើការពង្រឹងសមិទ្ធផល ដែលមានកន្លងមកដើម្បីផ្តល់ការអប់រំប្រកបដោយគុណភាព និងភាពឆ្លើយតប សម្រាប់ការអភិវឌ្ឍប្រទេស។ ការផ្តល់សេវាអប់រំប្រកបដោយវិជ្ជាជីវៈ និងគណនេយ្យភាព ជាមូលដ្ឋានគ្រឹះ សម្រាប់កសាងសង្គមមួយប្រកបដោយចំណេះដឹង និងជំនាញ។

វិស័យអប់រំ នឹងរៀបចំក្របខ័ណ្ឌធានាគុណភាពទូទាំងវិស័យ ដោយផ្អែកលើស្តង់ដាការសិក្សារៀនសូត្រ និងការផ្តល់សេវា ដែលឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ និងសហគមន៍ និងទីផ្សារការងារ។ គុណភាពអប់រំពឹងផ្អែកទាំងស្រុងលើគុណភាពគ្រូបង្រៀន និងគុណភាពនាយកសាលា ក្នុងន័យកែទម្រង់ការគ្រប់គ្រងសាលារៀនប្រកបដោយការច្នៃប្រឌិត ដើម្បីបម្រើសេវាអប់រំជូនប្រជាពលរដ្ឋនិងប្រទេសជាតិ។ ការគ្រប់គ្រង និងការបែងចែកគ្រូបង្រៀន គឺជាអាទិភាពមួយ ដែលត្រូវយកចិត្តទុកដាក់ ក្នុងការកែលម្អប្រសិទ្ធិភាពនៃការគ្រប់គ្រង ពិសេសការគ្រប់គ្រងធនធានមនុស្ស។ ជាការពិតណាស់គ្រូបង្រៀនគឺស្ថិតនៅក្នុងបេះដូងនៃដំណើរការរៀនសូត្រ។ គ្រូបង្រៀនមានឥទ្ធិពលលើកម្រិតគុណភាព និងនៅទីបំផុតសមិទ្ធផលនៃការសិក្សារបស់សិស្ស។ មុខងារជាច្រើនបានផ្សារភ្ជាប់ទៅនឹងការគ្រប់គ្រងនិងចាត់ចែងគ្រូបង្រៀន ដូចជាការជ្រើសរើស ការបណ្តុះបណ្តាល ការបែងចែក និងការដំឡើងឋានៈជាដើម។ វាជាគន្លឹះក្នុងការលើក កម្ពស់គុណភាព និងប្រសិទ្ធភាពអប់រំ។ នៅពេលជាមួយគ្នានោះដែរ គ្រូបង្រៀនជាផ្នែកមួយយ៉ាងសំខាន់នៃធនធានក្នុងវិស័យអប់រំ និងប្រាក់ឈ្នួលរបស់ពួកគេស្រូបអស់ពីរភាគបីនៃការចំណាយសាធារណៈនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន។ ការចំណាយ និងការគ្រប់គ្រងគ្រូបង្រៀនឲ្យមានប្រសិទ្ធភាពគឺជាគន្លឹះដ៏សំខាន់ក្នុងការធានាថាការប្រើប្រាស់អាចធ្វើទៅបានល្អបំផុតដែលត្រូវធ្វើឡើងសម្រាប់ធនធានដែលមានក្នុងវិស័យអប់រំ និងធានាថាលទ្ធផលដែលរំពឹងទុកនៃការគ្រប់គ្រងទទួលបាន

លទ្ធផលល្អ។ ការពង្រីកយ៉ាងឆាប់រហ័សនៃប្រព័ន្ធអប់រំ រដ្ឋាភិបាលបានជួបប្រទះនូវការកើនឡើងពីបញ្ហាប្រឈមដែលទាក់ទងទៅនឹងការផ្គត់ផ្គង់គ្រូបង្រៀនឲ្យមានចំនួនគ្រប់គ្រាន់ ខណៈមានការធានាគុណភាពគ្រូបង្រៀននៅមានកម្រិត។នៅក្នុងករណីជាច្រើន ក្រសួងអប់រំ យុវជន និងកីឡា បានជ្រើសរើសយកគោលនយោបាយ និងយុទ្ធសាស្រ្តដាក់លាក់ដើម្បីឲ្យប្រាក់ខែគ្រូបង្រៀន ដូចជាការជួលគ្រូបង្រៀនគ្មានគុណវុឌ្ឍិ ឬគ្រូបង្រៀនមានគុណវុឌ្ឍិមិនគ្រប់គ្រាន់។ ឧទាហរណ៍ដូចជាការបង្កើតប្រភេទគ្រូថ្មី (គ្រូបណ្តោះអាសន្ន ឬកិច្ចសន្យា ឬគ្រូសហគមន៍)។ ទោះជាយ៉ាងណា ខណៈពេលដែលមានការប្រឈមការទាក់ទងនឹងការផ្គត់ផ្គង់ និងការបណ្តុះបណ្តាលខុសគ្នាយ៉ាងខ្លាំង ជាមួយនឹងបរិបទនៃការអភិវឌ្ឍស្ទើរគ្រប់ប្រទេសទាំងអស់ ក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះដែលកំពុងប្រឈម និងបញ្ហាមិនស្មើភាពគ្នាក្នុងការកំណត់ចំនួនគ្រូតាមតំបន់ភូមិសាស្រ្តផ្សេងៗគ្នា និងតាមប្រភេទសាលារៀនព្រមទាំងអវត្តមានគ្រូបង្រៀន និងការវិចវិលបន្តិចម្តងៗ។ ការប្រើប្រាស់គ្រូបង្រៀនមិនសូវមានប្រសិទ្ធភាពនៅតាមសាលារៀន និងការធ្លាក់ចុះនៃសីលធម៌របស់គ្រូបង្រៀនក៏ត្រូវបានសង្កេតឃើញផងដែរនៅក្នុងករណីនេះ។ បញ្ហាការផ្គត់ផ្គង់គ្រូបង្រៀនមានភាពធ្ងន់ធ្ងរខ្លាំងនៅមធ្យមសិក្សា។ កង្វះខាតនៃមុខវិជ្ជាឯកទេសបង្រៀន និងការកម្រិតកំណត់ចំនួនបេក្ខជនដែលមានសក្តានុពលជាបញ្ហាប្រឈមដ៏ធំមួយនៃការពង្រីកការអប់រំនៅមធ្យមសិក្សា។

## ២.២ និយមន័យ និងពាក្យគន្លឹះ

–បឋមសិក្សា ឬអនុវិទ្យាល័យ គឺជាគ្រឹះស្ថានសិក្សាសាធារណៈ សម្រាប់បណ្តុះបណ្តាលប្រជាពលរដ្ឋក្នុងសហគមន៍ ឲ្យមានចំណេះដឹង។

–ស្ថានភាព គឺជាទីតាំងនៅយ៉ាងពិតប្រាកដ។

–គ្រូបង្រៀន ជាឪពុកម្តាយទី២ ដែលត្រូវតែរក្សា លើកទឹកចិត្តស្រឡាញ់រាប់អានសិស្សដូចជាកូន

–គ្រូបង្រៀន ជាអ្នកស្រាវជ្រាវ មិត្តភក្តិ មគ្គុទេសក៏ និងជាទីប្រឹក្សា

–គ្រូបង្រៀន គឺជាអ្នកបង្ហាត់បង្រៀនចំណេះវិជ្ជានិងសិល្ប៍សាស្រ្តផ្សេងៗដល់សិស្ស

–គ្រូបង្រៀន គឺជាវិស្វករនៃព្រលឹង

–គ្រូបង្រៀន គឺជាគ្រូពេទ្យព្យាបាលជម្ងឺអវិជ្ជា

–គ្រូបង្រៀន ជាអ្នកដឹកនាំមនុស្សឲ្យមានសាមគ្គីភាពនឹងគ្នា

–គ្រូបង្រៀន ជាបុគ្គលដែលប្រទេសជាតិត្រូវការជាចាំបាច់

–គ្រូបង្រៀន ជាអ្នកកសាងធនធានមនុស្សសម្រាប់អភិវឌ្ឍប្រទេសជាតិ

–គ្រូបង្រៀន ជាអ្នកជុសខាត់ ឬបង្ហាញផ្លូវដល់សិស្ស និងមនុស្សទូទៅ

## ក.តួនាទីគ្រូបង្រៀន

គ្រូបង្រៀនមិនមែនគ្រាន់តែជាអ្នកទៅសាលារៀន ដើម្បីប្រាប់មេរៀនដែលក្រសួងបានកំណត់នៅក្នុងកម្មវិធីសិក្សា និងមេរៀនដែលតម្រូវឲ្យសិស្សសិក្សារៀនសូត្រនោះទេ។ ប៉ុន្តែ ក្នុងនាមជាគ្រូបង្រៀនមួយ

រូប គឺត្រូវដើរតួនាទីជាច្រើនក្នុងអាជីពរបស់ខ្លួន គឺជាមាតាបិតា ជាអ្នកសិក្សាស្រាវជ្រាវ ជាមគ្គុទេសក៍ ជាទីប្រឹក្សា ជាអ្នកច្នៃប្រឌិត វិភាគ ជាអ្នកកំចាត់បក្សពួកនិយម ជាអ្នកផ្តល់ទស្សនវិស័យវាយតម្លៃ ជាសិល្បៈករ និងជាអ្នកសម្របសម្រួលដ៏ស្ទាត់ជំនាញ។

សព្វថ្ងៃនេះ ការបង្រៀនគឺជាជំនាញវិជ្ជាជីវៈ។ គ្រូបង្រៀនជាញឹកញាប់អនុវត្តតួនាទីរបស់ថៅក្រុមផ្នែកអាណាព្យាបាល អ្នកសម្របសម្រួលថ្នាក់ អ្នកណែនាំផ្តល់ប្រឹក្សាគំរូ រៀបចំផែនការ និងតួនាទីពាក់ព័ន្ធផ្សេងទៀតជាច្រើន។ គ្រូបង្រៀនត្រូវបានគេចេញផ្សាយកម្មវិធីសិក្សាជាក់លាក់មួយ ដើម្បីបង្រៀន និងណែនាំអំពីវិធីបង្រៀនដោយប្រើវិធីសាស្ត្រដូចគ្នា។ នៅក្នុងពិភពលោកនាបច្ចុប្បន្ននេះ តួនាទីគ្រូបង្រៀនគឺមានច្រើនយ៉ាងណាស់។ ការងាររបស់ពួកគាត់គឺផ្តល់ដំបូន្មានដល់សិស្សានុសិស្ស ជួយពួកគេរៀនពីរបៀបប្រើប្រាស់ចំណេះដឹង និងបញ្ចូលវាទៅក្នុងជីវិតរបស់ពួកគេ ដើម្បីឲ្យពួកគេក្លាយជាសមាជិកនៃសង្គម។ គ្រូបង្រៀនត្រូវបានលើកទឹកចិត្តឲ្យសម្របខ្លួនតាមវិធីសាស្ត្ររៀនសូត្រ។ ចំពោះការរៀនសូត្ររបស់សិស្សម្នាក់ៗដើម្បីប្រគួតប្រជែង និងជំរុញឲ្យពួកគេរៀន។

គ្រូបង្រៀនក្នុងឋានៈជាសិក្ខាបនជារី ត្រូវទទួលខុសត្រូវក្នុងការបញ្ចប់កម្មវិធីសិក្សា ប្រកបដោយប្រសិទ្ធភាព និងគុណភាព។ ក្រៅពីបង្រៀន គឺទទួលបន្ទុកថ្នាក់ និងជាអ្នកគ្រប់គ្រងផ្ទាល់មួយថ្នាក់ផងដែរ។គ្រូបង្រៀនមានភារកិច្ចក្នុងការគ្រប់គ្រងការសម្អាត ការតុបតែងលម្អថ្នាក់រៀន គ្រប់គ្រងវត្តមាន គ្រប់គ្រងការសិក្សា គ្រប់គ្រងសីលធម៌ ទំនាក់ទំនងជាមួយមាតាបិតា ឬអាណាព្យាបាលសិស្ស ស្តីពីការសិក្សារបស់សិស្ស និងដឹកនាំសិស្សចូលរួមកិច្ចការសង្គមផ្សេងៗ។

## ខ.ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

–ស្តង់ដាគ្រូបង្រៀន ជាការយល់ដឹងយ៉ាងច្បាស់លាស់នូវគោលនយោបាយ ការយល់ដឹងទាំងឡាយដែលគ្រូបង្រៀនមានទំនួលខុសត្រូវ។

–ស្តង់ដាគ្រូបង្រៀន ជាការបញ្ជាក់ពីការប្រតិបត្តិវិជ្ជាជីវៈ ដែលសមស្រប និងសម្បូរបែបសម្រាប់វាយតម្លៃលទ្ធផលសិក្សា សិស្សប្រកបដោយតម្លាភាព។

–ស្តង់ដាគ្រូបង្រៀន ជាឧបករណ៍ សម្រាប់វាស់ស្ទង់សមត្ថភាពជាក់ស្តែង របស់គ្រូបង្រៀនដែលបានអនុវត្តជាប្រចាំ។ ស្តង់ដាគ្រូបង្រៀនមានលក្ខណៈសម្បត្តិដូចជាៈ ចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ(ថៅ ឧស្សាហ៍ អធិការអប់រំជំនាន់១)។

## ២.៣.ការគ្រប់គ្រង និងការបែងចែកធនធានមនុស្សក្នុងវិស័យអប់រំ

ការគ្រប់គ្រងធនធានមនុស្សទាក់ទងនឹងការផ្សារភ្ជាប់ធនធានមនុស្ស ទៅនឹងវត្ថុបំណង នៃអង្គភាពដូចជាក្រសួងអប់រំ យុវជន និងកីឡា។ ការគ្រប់គ្រងធនធានមនុស្ស នៅក្នុងវិស័យអប់រំទាក់ទងនឹងមុខងារនៃការទាក់ទាញ ការអភិវឌ្ឍ និងការរក្សាបុគ្គលិកដែលមានគុណវុឌ្ឍិ ដើម្បីបំពេញសកម្មភាពចាំបាច់ដើម្បីសម្រេចគោលដៅរបស់សកម្មភាព(ដោយប្រឈមនឹងឧបសគ្គនានា)។ ទាក់ទងទៅនឹងការពង្រីកការសិក្សាជាពិសេសការអប់រំនៅមធ្យមសិក្សា ធនធានមនុស្សនៅក្នុងវិស័យអប់រំត្រូវតែផ្តល់ការផ្គត់ផ្គង់ ឲ្យបានគ្រប់គ្រាន់ និងប្រកបដោយសីលធម៌ដូចជាគ្រូបង្រៀនជាដើម។ ដើម្បីបង្កើនគុណភាពប្រសិទ្ធភាព និងសីលធម៌នៅក្នុងវិស័យអប់រំ គោលបំណងសំខាន់បំផុតនៃការគ្រប់គ្រងធនធានមនុស្សក្នុង

វិស័យអប់រំគឺត្រូវធានាបាននូវការជ្រើសរើសគ្រូបង្រៀនដោយសមស្រប ត្រឹមត្រូវ និងមាននិតិវិធីក្នុងការបណ្តុះបណ្តាលក៏ដូចជាការបែងចែកគ្រូបង្រៀនប្រកបដោយសមធម៌ ព្រមទាំងមានការលើកទឹកចិត្តខ្ពស់ ការកំណត់ឲ្យ បានច្បាស់លាស់ចំពោះបុគ្គលិកបង្រៀន បុគ្គលិកមិនបង្រៀន និងបុគ្គលិកទីចាត់ការផងដែរ។ ចំពោះឧបសគ្គថវិកា ការគ្រប់គ្រងថវិកាក្នុងវិស័យអប់រំ ត្រូវតែត្រួតពិនិត្យ ធ្វើការតាមដានសម្រាប់បន្ថែមលើការចំណាយចំណូលសម្រាប់បុគ្គលិក និងសាលាទាំងមូល។ ការអនុវត្តការងារជាក់ស្តែង ជារៀងរាល់ថ្ងៃនៃមុខងារនៃការគ្រប់គ្រងនិងបែងចែកគ្រូបង្រៀន នៅថ្នាក់កណ្តាល ជាទូទៅគឺត្រូវបានគិត និងយល់យ៉ាងច្បាស់ លាស់រួមមាន៖

–ការរៀបចំធ្វើផែនការគ្រូបង្រៀន

–ការរៀបចំធ្វើការជ្រើសរើសគ្រូបង្រៀន

–ការរៀបចំធ្វើការបែងចែក

–ការរៀបចំការពិនិត្យតាមដាន

–យោងក្របខណ្ឌច្បាប់ រួមទាំងយន្តការអនុវត្តច្បាប់

–ធ្វើការត្រួតពិនិត្យការវាយតម្លៃ និងដំឡើងឋានៈ

ការគ្រប់គ្រងនិងការបែងចែកគ្រូបង្រៀនគឺជាដំណើរការនៃការរួមបញ្ចូលទាំងមុខងាររបស់បុគ្គលិក ការតែងតាំងគ្រូបង្រៀន ការបែងចែកគ្រូបង្រៀន ការធ្វើលិខិតបញ្ជាក់ ការវាយតម្លៃ និងការអភិវឌ្ឍបុគ្គលិកលក្ខណៈ ការដំឡើងថ្នាក់ ការដាក់ពិន័យ និងបញ្ហាជាច្រើនទៀត ដែលប៉ះពាល់ដល់សេវានៃការបង្រៀនរបស់គ្រូ។ ជាធម្មតាបញ្ហាទាំងអស់នោះ និងរួមបញ្ចូលទាំងការទទួលខុសត្រូវសម្រាប់រៀបចំព័ត៌មានពាក់ព័ន្ធនឹងប្រាក់ខែ និងប្រាក់ឧបត្ថម្ភផ្សេងៗ។

## ២.៤.គោលនយោបាយស្តីពីគ្រូបង្រៀន

ការអនុម័គោលនយោបាយស្តីពីគ្រូបង្រៀននៅឆ្នាំ២០១៣ គឺជាការចាប់ផ្តើមធ្វើកំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាល និងការជ្រើសរើសគ្រូបង្រៀនមានរួមបញ្ចូល កម្មវិធី សកម្មភាព កាលបរិច្ឆេទ និងលទ្ធផល

រំពឹងទុក្ខ ព្រមទាំងការចំណាយថវិកាសម្រាប់អនុវត្តពីឆ្នាំ២០១៥ ដល់២០១៨ ដើម្បីរៀបចំចក្ខុវិស័យសម្រាប់គោលនយោបាយវិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជា។

- គោលនយោបាយទី១ គឺទាក់ទាញអ្នកមានសមត្ថភាពឲ្យចូលធ្វើគ្រូបង្រៀនដោយ៖
    - ✓ ផ្តល់ផលប្រយោជន៍សង្គម និងហិរញ្ញវត្ថុដោយដំឡើងប្រាក់បៀវត្សនិងអត្ថប្រយោជន៍ផ្សេង
    - ✓ បើកទូលាយការជ្រើសរើសគ្រូ (អនុញ្ញាតឲ្យអ្នកមានបរិញ្ញាបត្រពីគ្រប់គ្រឹះស្ថានសិក្សារដ្ឋ និងគ្រឹះស្ថានសិក្សាឯកជនទទួលបានអាជ្ញាប័ណ្ណអប់រំ)។
    - ✓ ផ្តល់ការបំប៉នគ្រូបឋមភូមិតាមរយៈប្រព័ន្ធពន្លឿនទៅជាបរិញ្ញាបត្រ
    - ✓ ផ្តល់ការបំប៉នគ្រូបឋមភូមិឲ្យបំពេញជាបរិញ្ញាបត្រ(គម្រោងSEP)
    - ✓ រឹតបន្តឹងការជ្រើសរើសចូលបណ្តុះបណ្តាល(ប្រកួតប្រជែងចំណាត់ថ្នាក់ជាតិលែងធ្វើចំណាត់ថ្នាក់តាមខេត្ត)។

- ✓ បេក្ខជនទទួលបាននិទ្ទេសABCប្រឡងជាប់ថ្នាក់ទី១២ ជាប់ជាស្វ័យប្រវត្តិ។
- ✓ ធ្វើការកែលម្អការប្រឡងចូល(១)ការប្រឡងគោរពគោលការណ៍ច្បាប់ តម្លាភាព យុត្តិធម៌(២)ការប្រឡងសរសេរ (៣) ការសម្ភាសន៍ផ្ទាល់មាត់ (៤) ការកែប្រែគោលការណ៍កំណត់អាយុ និង (៥) ការតាមដានការបណ្តុះបណ្តាល។

➢ គោលនយោបាយទី២ គឺបណ្តុះបណ្តាលគ្រូបង្រៀនដោយ៖

- ✓ កែទម្រង់កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិតតាមរូបមន្ត១២+៤
- ✓ រៀបចំកម្មវិធីបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់+១ ឲ្យក្លាយជាគ្រូវិទ្យាល័យ។
- ✓ អនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ផ្អែកតាមស្តង់ដា តាមរូបមន្ត១២+៤នៅតាមភូមិភាគ
- ✓ បង្កើនប្រសិទ្ធភាពកម្មវិធីសិក្សាមុនតែងតាំងស៊ប់ក្នុងក្របខណ្ឌ។
- ✓ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។
- ✓ ប្រែក្លាយសាលាគរុកោសល្យទៅជាវិទ្យាស្ថានអភិវឌ្ឍគ្រូបង្រៀន។
- ✓ បង្កើនគុណវុឌ្ឍិនិងបទពិសោធន៍បុគ្គលិកអប់រំឲ្យមានសមត្ថភាពយ៉ាងទាបបរិញ្ញាបត្រជាន់ខ្ពស់

➢ គោលនយោបាយទី៣ ការគ្រប់គ្រងគ្រូ៖

- ✓ ធ្វើទំនើបកម្មផែនការតម្រូវការនិងផ្គត់ផ្គង់គ្រូបង្រៀន
- ✓ ពង្រីកការប្រើប្រាស់គ្រូបង្រៀនផ្អែកតាមនិយាម និងគោលការណ៍ប្រើប្រាស់បុគ្គលិកដើម្បីធ្វើការកែលម្អការអនុវត្តការពង្រាយគ្រូបង្រៀន។
- ✓ លើកកម្ពស់ដំណើរការ នីតិវិធីនៃការជ្រើសរើស និងរក្សាទុកគ្រូបង្រៀនមានស្នាដៃល្អសម្រាប់ជានានិរន្តរភាពគ្រឹះស្ថានសិក្សា។
- ✓ ធ្វើប្រតិភូកម្មការជ្រើសរើសនិងការគ្រប់គ្រងគ្រូបង្រៀនទៅថ្នាក់ក្រោមជាតិតាមការកំណត់
- ✓ ការចូលរួមរបស់គណៈគ្រប់គ្រងសាលា និងអ្នកពាក់ព័ន្ធក្នុងការធ្វើសេចក្តីសម្រេច (ការជ្រើសរើស ការផ្តល់រង្វាន់ ការពិន័យ ការផ្ទេរ ការវាយតម្លៃ វេទិការសាធារណៈ ការប្រជុំការវាយតម្លៃសេវាមូលដ្ឋាន និងការបង្រៀនបំណិនជីវិតជាដើម)។

➢ គោលនយោបាយទី៤ ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន៖

- ✓ បណ្តុះវប្បធម៌រៀនពេញមួយជីវិត ដោយចែករំលែកបទពិសោធន៍ជាមួយបណ្តាក្រុមអ្នកអប់រំ និងបង្កើនគុណវុឌ្ឍិគ្រូបង្រៀនឲ្យទទួលបានសញ្ញាបត្រតាមរយៈផ្តល់ឲ្យទៅរៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ(គំរោងSEIP)។
- ✓ អភិវឌ្ឍនិងអនុវត្តការងារវិក្រឹតការគ្រូបង្រៀន ពង្រឹងចំណេះដឹងភាសាខ្មែរ គណិតវិទ្យា ប្រវត្តិវិទ្យា និងវិទ្យាសាស្ត្រសម្រាប់គ្រូបង្រៀនថ្នាក់ទី៧.៨.៩ ។
- ✓ បង្កើតប្រព័ន្ធវិក្រឹតការឲ្យមានប្រសិទ្ធភាព
- ✓ ការបង្កើនគុណវុឌ្ឍិគ្រូឧទ្ទេសឲ្យដល់កម្រិតយ៉ាងទាបបរិញ្ញាបត្រជាន់ខ្ពស់ដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារការងារជាតិ និងអន្តរជាតិ ។

- ✓ អនុវត្តអាហារូបករណ៍និងកម្មវិធីរ៉ៃកឹតការពន្លឿនសម្រាប់គ្រូបង្រៀនទទួលបានបរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ចំនួន១០០កន្លែងក្នុងមួយឆ្នាំ។
- ✓ បង្កើនប្រព័ន្ធក្រេឌីតដើម្បីរៀបចំឲ្យមានការឯកភាពគ្នាមួយ នៅរាល់ប្រភេទនៃវគ្គរ៉ៃកឹតការសម្រាប់ទទួលបាននៅការលើកកម្ពស់គុណវុឌ្ឍិ និងផលប្រយោជន៍បន្ថែម។
- ✓ បង្កើតកម្មវិធីសម្រាប់គ្រូឧទ្ទេសសាលាគរុកោសល្យក្នុងការចុះជួយបំប៉នសមត្ថភាពគ្រូ។

➢ គោលនយោបាយទី៥ ការលើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀន៖

- ✓ ការលើកកម្ពស់លក្ខខណ្ឌការងារ និងការរស់នៅរបស់គ្រូបង្រៀន តាមរយៈការផ្ដល់បៀវត្សរ៍លាភការ សុខុមាលភាពសង្គម អត្ថប្រយោជន៍ទូទៅពេលចូលនិវត្តន៍ ជាពិសេសអ្នកគ្រូ និងលោកគ្រូបម្រើការងារនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។
- ✓ ផ្ដល់សម្ភារៈរូបវ័ន្ត កែលម្អលក្ខខណ្ឌការងារនៅសាលារៀនដាច់ស្រយាល និងជួបការលំបាក។
- ✓ ទទួលស្គាល់និងជូនរង្វាន់ដល់គ្រូដែលមានស្នាដៃ(រក្សាគ្រូដែលមានស្នាដៃ)។
- ✓ រៀបចំគន្លងអាជីបគ្រូបង្រៀន។
- ✓ រៀបចំបណ្ដាញគាំទ្រជាប្រចាំ(សហគមន៍ មាតាបិតាសិស្ស សមាគមន៍វិជ្ជាជីវៈ តាមមុខវិជ្ជា)។
- ✓ បង្កើតក្រុមបច្ចេកទេសក្នុងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនសម្រាប់ចុះជួយតាមមុខវិជ្ជា។

➢ គោលនយោបាយទី៦ ពង្រឹងភាពជាអ្នកដឹកនាំសាលារៀន(នាយក)៖

- ✓ រៀបចំស្ដង់ដានាយក និងសៀវភៅណែនាំពីការគ្រប់គ្រងសាលារៀន
- ✓ ធ្វើការបណ្ដុះបណ្ដាលនាយកសាលាតាមស្ដង់ដានាយកសាលា
- ✓ បង្កើតក្រុមប្រឹក្សាសហគមន៍នាយកសាលា និងយន្តការពង្រឹងការគាំទ្រនាយកសាលា
- ✓ ធ្វើការការពារ និងលើកកម្ពស់សិទ្ធិគ្រូបង្រៀន
- ✓ ធ្វើការកែលម្អការប្រឡងជ្រើសរើស ការបណ្ដុះបណ្ដាល ការបំពេញការងារ និងផលប្រយោជន៍គ្រូឧទ្ទេស និងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា។

➢ គោលនយោបាយទី៧ ពង្រឹងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ៖

- ✓ កែលម្អទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានគ្រូបង្រៀន។
- ✓ រៀបចំយន្តការពិនិត្យតាមដាន និងវាយតម្លៃការងារគ្រូបង្រៀនដោយផ្ដោតលើស្ដង់ដាវិជ្ជាជីវៈគ្រូបង្រៀន ការប្រើប្រាស់និយាម លក្ខណៈសម្បត្តិ និងគន្លងអាជីពគ្រូបង្រៀន។
- ✓ ពង្រឹងការពិនិត្យតាមដាននៅនឹងកន្លែង តាមរយៈការធ្វើអធិការកិច្ចជាប្រចាំ ការផ្ដល់សិទ្ធិពេញលេញដល់នាយកសាលា។
- ✓ កំណត់សិទ្ធគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈក្នុងការធ្វើការសម្រេចចិត្តលើការគ្រប់គ្រង និងអភិវឌ្ឍអង្គភាព។

## ២.៥.តួនាទី និងភារកិច្ចគ្រូបង្រៀននៅកម្ពុជា

គ្រូបង្រៀនមានតួនាទីបណ្ដុះបណ្ដាលធនធានមនុស្សប្រកបដោយសីលធម៌ គុណភាពនិងប្រសិទ្ធភាពខ្ពស់។ គ្រូបង្រៀនគឺបណ្ដុះកុមារ និងយុវវ័យឲ្យស្គាល់តម្លៃជាតិ និងតម្លៃជាសកល ដោយអប់រំពួកគេបន្តិចម្ដងៗឲ្យមានសមត្ថភាពចូលរួមបម្រើសង្គមជាតិ និងសកលលោកផងដែរ។ គ្រូបង្រៀនអាចទទួលបំពេញតួនាទីនេះបាន លុះត្រាតែគាត់មានជំនឿលើខ្លួនឯង និងឲ្យតម្លៃខ្ពស់លើតួនាទីទាំងនេះផង ពិសេសគ្រូបង្រៀនត្រូវចាប់អារម្មណ៍និងជឿជាក់លើការរីកចម្រើននៃវិទ្យាសាស្ត្របច្ចេកទេសលើសោភ័ណភាព លើសង្គម និងសីលធម៌ផងដែរ។

## ២.៦.ក្រមសីលធម៌ វិជ្ជាជីវៈគ្រូបង្រៀន

គ្រូបង្រៀនជាមនុស្សម្នាក់ ដែលរដ្ឋផ្ដល់ទំនុកចិត្តឲ្យបង្រៀន និងអប់រំកុមារ និងជំទង់។ កុមារ និងជំទង់មានតម្លៃមិនអាចកាត់ថ្លៃបានចំពោះគ្រួសារ និងសង្គម ហើយអនាគតប្រទេសជាតិអាស្រ័យទាំងស្រុងទៅលើពួកគេ។ ប្រទេសជាតិទទួលការរីកចម្រើន ឬមានភាពទន់ខ្សោយអាស្រ័យទៅលើគុណភាពនៃយុវជន។ បើគ្រូបង្រៀនម្នាក់ខ្វះចំណេះដឹង ខ្វះសីលធម៌ ហើយបំពេញភារកិច្ចរបស់ខ្លួនមិនបានទទួលជោគជ័យ អ្នកដែលត្រូវទទួលផលវិបាកអាក្រក់ គឺមនុស្សទូទៅ ជាពិសេសគឺយុវជនដែលជា សរសរទ្រូងនៃប្រទេស។

សីលធម៌វិជ្ជាជីវៈ គឺជាសីលធម៌ដោយឡែកសម្រាប់អ្នកដែលត្រូវចូលរួមបំពេញមុខងារអ្វីមួយនៅក្នុងសង្គម។ មន្ត្រីរាជការដែលប្រកបមុខរបរអ្វីមួយ ត្រូវតែមានការយល់ដឹងពីសីលធម៌ដែលទាក់ទងទៅនឹងមុខរបរនោះ។ មុខងារជាគ្រូបង្រៀន តម្រូវឲ្យគ្រូបង្រៀនម្នាក់ៗ ស្វែងយល់បន្ថែមទៀតនូវសីលធម៌ដោយឡែក ដែលទាក់ទងដល់មុខរបរជាគ្រូបង្រៀន ដោយហេតុថា បញ្ញត្តិសីលធម៌ទូទៅ មិនគ្រប់គ្រាន់សម្រាប់គ្រូបង្រៀនឡើយ។ មហាជនតែងចាត់ទុកថារាល់សកម្មភាពគ្រូបង្រៀនទោះក្នុងសាលាក្ដី ក្រៅសាលាក្ដី នៅទីផ្សារក្ដី ក្នុងវត្តក្ដីគឺជាសកម្មភាពរបស់គ្រូបង្រៀនម្នាក់មិនមែនជាទង្វើផ្ទាល់ខ្លួនបុគ្គល ឡើយ។ គ្រូបង្រៀនត្រូវតែជាមនុស្សល្អបរិសុទ្ធ ហើយត្រូវតែប្រកាន់អាកប្បកិរិយា ដូចអ្នកបួសក្នុងសាសនា ឬដូចអាចារ្យវត្តនោះឡើយ ព្រោះថាគ្រូបង្រៀនជាមនុស្សធម្មតា មិនមែនជាព្រះ ឬអាទិទេពឡើយ។ គ្រូបង្រៀនត្រូវតែមានការប្រុងប្រយ័ត្នជាងអ្នកដទៃដោយត្រូវស្វែងយល់ និងស្វ័យអប់រំខ្លួនជាប្រចាំ មិនត្រូវភ្លេចខ្លួនឡើយ។

មុខងារគ្រូបង្រៀនពោរពេញទៅដោយភាពស្មុគស្មាញ តែក៏ជាមុខរបរមួយប្រកបដោយកិត្តិយសដែលគ្រូបង្រៀនត្រូវតែមានសុទិដ្ឋិនិយម ខិតខំបំពេញភារកិច្ចឲ្យបានសម្រេចគឺដើម្បីអនាគតកុមារ យុវជន និងប្រទេសជាតិទាំងមូល។

## ២.៧.ក្រមសីលធម៌វិជ្ជាជីវៈនាយកសាលារៀន

វិស័យអប់រំ មានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សឲ្យមានចំណេះដឹង មានសមត្ថភាព មានសម្បទាគ្រប់គ្រាន់ មានជំនាញ មានភាពច្នៃប្រឌិតនិងនវានុវត្តន៍ មានស្មារតីសហគ្រិនភាព និងមានក្រមសីលធម៌ខ្ពស់ ដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ជួយបង្កើនកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការធ្វើពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។

គុណភាពអប់រំ គឺពឹងផ្អែកទាំងស្រុងទៅលើគុណភាពគ្រូបង្រៀន និងគុណភាពនាយកសាលារៀន។ ក្នុងន័យនេះ យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ ២០១៩-២០២៣ ផ្តោតទៅលើការគ្រប់គ្រងសាលារៀន ការពង្រឹងគុណភាពគ្រូ និងការកែលម្អការបង្រៀន និងរៀន ដោយឲ្យសាលារៀនមានស្វ័យភាពហិរញ្ញវត្ថុ និងការទទួលខុសត្រូវ ចំពោះលទ្ធផលសិក្សារបស់សិស្ស។ ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រខាងលើ និងដើម្បីអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ ២០១៨-២០២៣ ក្រសួងអប់រំ យុវជន និង កីឡា បានរៀបចំស្តង់ដានាយកសាលារៀនដោយតម្រូវឱ្យនាយកសាលារៀនមានគុណវុឌ្ឍិគ្រប់គ្រាន់ មានសមត្ថភាពខាងការគិតបែបយុទ្ធសាស្ត្រ និងនវានុវត្តន៍ មានភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរដ្ឋបាលសាលារៀន កម្មវិធីសិក្សា ការបង្រៀន និងការរៀនតាមបរិបទថ្មីក្នុងសតវត្សទី២១ ដើម្បីជំរុញឲ្យគណៈគ្រប់គ្រងសាលារៀនមានលទ្ធភាពអភិវឌ្ឍខ្លួនពេញមួយជីវិត មានលទ្ធភាពដោះស្រាយបញ្ហាថ្មីៗប្រកបដោយឧត្តមភាព ដោយផ្សារភ្ជាប់សាលារៀន និងសហគមន៍ រួមទាំងមានក្រមសីលធម៌វិជ្ជាជីវៈដើម្បីពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀន។

ក្រមសីលធម៌នាយកសាលារៀនរួមមាន ការប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈគ្រូបង្រៀន ការពង្រឹងសាមគ្គីភាព ការគោរពវិន័យការងារ ការរក្សាការសម្ងាត់វិជ្ជាជីវៈ ភក្តីភាពចំពោះអង្គភាព មានចំណេះដឹងវិជ្ជាជីវៈការផ្តល់តម្លៃអ្នកសិក្សា ការមិនរើសអើង ការមិនប្រើអំពើហិង្សា និងមានសីលធម៌រស់នៅល្អប្រកបដោយគុណធម៌ យុត្តិធម៌ សុភវិនិច្ឆ័យ និងការពិគ្រោះយោបល់ផ្អែកលើភស្តុតាងជាក់ស្តែង។

## ២.៨.តួនាទី និងភារកិច្ចនាយកសាលានៅកម្ពុជា

នាយកសាលាមានតួនាទីជាអាជ្ញាធរអប់រំ មន្ត្រីរដ្ឋបាល ទីប្រឹក្សាគរុកោសល្យ អធិការកិច្ចអចិន្ត្រៃយ៍ និងជាភ្នាក់ងារអភិវឌ្ឍរបស់សហគមន៍៖

-ជាអជ្ញាធរអប់រំ ដោយសារនាយកសាលាជាប្រតិភូអចិន្ត្រៃយ៍របស់ក្រសួងអប់រំ យុវជន និងកីឡាប្រចាំភូមិសិក្សារបស់សាលានីមួយៗ។ គាត់ជាអ្នកធានាទំនាក់ទំនងការងាររវាងសាលារៀន និងថ្នាក់លើ។ នាយកសាលាជាអ្នកឃ្លាំមើល និងជាអ្នកអនុវត្តបទប្បញ្ញត្តិសិក្សា និងអត្ថបទច្បាប់ផ្លូវការទាំងឡាយ។ នាយកសាលាដឹកនាំ គ្រប់សកម្មភាពទាំងឡាយរបស់សាលារៀនដើម្បីឱ្យធានាបាននូវប្រសិទ្ធភាព តាមគោលដៅអប់រំដែលបានគ្រោងទុក។ នាយកសាលារៀនទទួលខុសត្រូវទាំងស្រុងចំពោះសាលារៀន និងថ្នាក់លើនូវរាល់អ្វីៗដែលមាននៅក្នុងដែនសមត្ថកកិច្ចរបស់ខ្លួន។

-ជាមន្ត្រីរដ្ឋបាលដោយសារនាយកសាលាជាអ្នកណែនាំអនុវត្តរដ្ឋបាលសិក្សាទាំងអស់ នៅក្នុងសាលារៀន ធានាធ្វើឲ្យសម្រេចគោលដៅអប់រំ ដោយរិះរកគ្រប់មធ្យោបាយ និងវិធានការចាំបាច់ ដើម្បីឲ្យសកម្មភាពប្រព្រឹត្តិទៅប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ។

-ជាទីប្រឹក្សាគរុកោសល្យ ដោយសារក្នុងឋានៈជាគ្រូបង្រៀន និងជាគ្រូដែលមានបទពិសោធនាយកសាលារៀនមានសិទ្ធិអំណាចណែនាំគរុកោសល្យដល់គ្រូបង្រៀនក្រោមឱវាទ នូវគំនិត ល្បិច និងគន្លឹះល្អៗនៃការបង្រៀនរបស់គ្រូ។ នាយកសាលា អាចបំពេញភារកិច្ចនេះបាន លុះត្រាណា ជានិច្ចកាលស្វ័យសិក្សានិងអភិវឌ្ឍសម្បទាចិត្ត-គរុកោសល្យគ្មានឈប់ឈរ។ គ្រូបង្រៀនតែងតែផ្តល់កិត្តិយស និងគោរពនាយកសាលាណា ដែលមានសម្បទាអាចធានាការរៀបចំគរុកោសល្យបាន។

–ជាអធិការអេចិន្ត្រៃយ៍ដោយសារនាយកសាលារៀនមានសិទ្ធិត្រួតពិនិត្យ តាមដាន និងជួយកែលម្អសកម្មភាពអប់រំ ជាអធិការអេប់រំអេចិន្ត្រៃយ៍បន្តណែនាំឲ្យអនុវត្តជួយកែលម្អ និងវាយតម្លៃ ដើម្បីបានសម្រេចទៅតាមស្មារតីនៃការណែនាំរបស់អធិការអេប់រំ។

–ជាភ្នាក់ងារអេភិវឌ្ឍរបស់សហគមន៍ដ៏សំខាន់ និងចាំបាច់នៃការអេភិវឌ្ឍរបស់សហគមន៍ជាពិសេស ការអេភិវឌ្ឍចិត្តគំនិត និងស្មារតី ដោយសារនាយកសាលាមានសិទ្ធិចូលរួមគ្រប់សកម្មភាពរបស់សហគមន៍ ពីតួនាទី និងភារកិច្ច (ការអប់រំសម្រាប់ទាំងអស់គ្នា និងទាំងអស់គ្នាសម្រាប់ការអប់រំ)។ ក្រៅពីនេះ នាយកសាលាមានភារកិច្ចទទួលខុសត្រូវលើការងារមួយចំនួនទៀតដូចជា៖

+ការងាររដ្ឋបាលរបស់សាលារៀនគ្រប់ប្រភេទ សំដៅធ្វើឲ្យដំណើរការងារប្រចាំថ្ងៃ។

+ការងាបច្ចេកទេសគរុកោសល្យគ្រប់គ្រងសកម្មភាពបង្រៀន និងរៀន។

+ការងារទំនាក់ទំនង មានទំនាក់ទំនងល្អទាំងផ្ទៃក្នុង និងផ្ទៃក្រៅ។

## ២.៨.១.ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន

ចាប់ពីខែកញ្ញា ឆ្នាំ១៩៩៧ មានការប្រើប្រាស់ពាក្យគ្រូមធ្យមសិក្សាបឋមភូមិ គ្រូមធ្យមសិក្សាទុតិយភូមិ ជួសឲ្យពាក្យគ្រូមធ្យមសិក្សាកម្រិត១ និងគ្រូមធ្យមសិក្សាកម្រិត២។ ចំណែកពាក្យថាសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិត្រូវបានប្រើជំនួសដោយពាក្យសញ្ញាបត្រមធ្យមសិក្សាកម្រិត១ និងសញ្ញាបត្រមធ្យមសិក្សាកម្រិត២។

## ២.៨.២.ប្រសិទ្ធភាព នៃការពង្រាយគ្រូ

*ការធ្វើសនិទានកម្មគ្រូបង្រៀនឲ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា*

ដើម្បីធ្វើសនិទានកម្មគ្រូបង្រៀន ឲ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សានានា ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើទំនើបកម្មផែនការតម្រូវការ និងផ្គត់ផ្គង់គ្រូបង្រៀន សម្រាប់បណ្តុះបណ្តាលមុនពេលបម្រើការងារ និងធ្វើសុខដុមនីយកម្មទិន្នន័យ ដើម្បីបង្កើនប្រសិទ្ធភាពនៃការធ្វើផែនការគ្រូបង្រៀន។ បន្ថែមពីនេះ ក្រសួងក៏ត្រូវធ្វើបច្ចុប្បន្នភាពទិន្នន័យ ព្រមទាំងធានាសុក្រឹតភាព ភាពជឿទុកចិត្តបាន តាមរយៈការធ្វើបច្ចុប្បន្នកម្ម និងសុពលភាពទិន្នន័យ។ ក្រសួងត្រូវប្រើប្រព័ន្ធទិន្នន័យដែលបានរៀបចំសម្រាប់ធ្វើផែនការផ្គត់ផ្គង់ និងតម្រូវការគ្រូបង្រៀនឲ្យមានប្រសិទ្ធភាព បង្កើតឲ្យមានទម្រង់ព័ត៌មានគ្រូ (Teacher Profile) អត្រាគង់វង្សគ្រូ អត្រាគ្រូវិចរិល ផែនការបម្រុងសម្រាប់ជំនួសអ្នកឈប់ និងធ្វើចំណោលតម្រូវការគ្រូបង្រៀនសម្រាប់មុខវិជ្ជានីមួយៗជាដើម។

ពង្រឹងប្រសិទ្ធភាពការប្រើប្រាស់គ្រូបង្រៀនប្រើទៅតាមនិយាម និងតាមគោលការណ៍ច្បាប់ដោយអនុវត្តនិយាមប្រើប្រាស់បុគ្គលិកអប់រំ រៀបចំធ្វើផែនការកែលម្អនិយាមប្រើប្រាស់បុគ្គលិកអប់រំតាមលទ្ធផលនៃការសាកល្បងនៅតាមរាជធានីខេត្ត និងអនុវត្តនិយាមថ្មី សម្រាប់ប្រើប្រាស់បុគ្គលិកអប់រំ នៅទូទាំងប្រទេស។ ការប្រើនិយាមបុគ្គលិកថ្មី ដើម្បីកែលម្អការពង្រាយគ្រូបង្រៀន ផលធៀបសិស្សគ្រូនៅតាមរាជធានីខេត្ត ក្រុង ស្រុកខណ្ឌ និងឃុំសង្កាត់។ លើកកម្ពស់ការគ្រប់គ្រងគ្រូបង្រៀន និងរៀបចំក្របខណ្ឌគ្រូបង្រៀនគឺត្រូវគ្រប់គ្រងគ្រូបង្រៀនឲ្យមានប្រសិទ្ធភាព។ គ្រូបង្រៀនថ្មី គ្រប់ភូមិសិក្សា ត្រូវមានកាតព្វកិច្ចបម្រើការនៅតំបន់ដែលខ្វះគ្រូតាមគោលការណ៍។

នាពេលបច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើផែនការជ្រើសរើសគ្រូ ដោយតម្រូវឲ្យបេក្ខជនចុះទៅដាក់ពាក្យផ្ទាល់នៅសាលារៀនដែលខ្លួនចង់ទៅបម្រើការងារនិងមានចុះហត្ថលេខាពីនាយកសាលាផ្ទាល់ នៅតាមសាលា និងតំបន់ផ្សេងៗទូទាំងប្រទេស។ នេះគឺជាការធានានូវតម្រូវការគ្រូចេញថ្មីឲ្យមានប្រសិទ្ធភាព ទៅតាមគោលការណ៍ និងគោលដៅដែលក្រសួងចង់បាន និងសាលារៀនផ្ទាល់ដែលមានការខ្វះគ្រូដើម្បីប្រើប្រាស់ឲ្យបានត្រឹមត្រូវតាមនិយាម មានគុណភាព និងប្រសិទ្ធភាពខ្ពស់។

លើកកម្ពស់ការក្សាទុកគ្រូបង្រៀនដែលមានស្នាដៃ រក្សាគ្រូទាំងនោះសម្រាប់ទុកចែករំលែកនូវបទពិសោធ និងចំណេះដឹងដល់អ្នកជំនាន់ក្រោយ។ ធ្វើប្រតិភូកម្ម ការជ្រើសរើស និងការគ្រប់គ្រងគ្រូបង្រៀនទៅថ្នាក់ក្រោមជាតិ តាមគោលការណ៍កំណត់របស់អង្គភាពអប់រំនៅថ្នាក់ក្រោមជាតិ និងគ្រប់គ្រងគ្រូបង្រៀនត្រូវធ្វើការសិក្សាអំពីមុខងារ និងធនធានសមស្រប និងមានរបាយការណ៍ជាក់លាក់ ស្តីពីការត្រួតពិនិត្យឡើងវិញនៅមុខងារវិស័យអប់រំ យុវជន និងកីឡា។ រៀបចំធ្វើការណែនាំស្តីពីការធ្វើប្រតិភូកម្ម និងការជ្រើសរើសគ្រប់គ្រងគ្រូបង្រៀននៅថ្នាក់ក្រោមជាតិផ្អែកតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ របស់ក្រសួង ព្រមទាំងធ្វើការពង្រឹងសមត្ថភាពមន្ត្រីអប់រំ នៅមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត លើការងារជ្រើសរើស ការងារគ្រប់គ្រងគ្រូបង្រៀន ផ្អែកតាមនិយាមប្រើប្រាស់បុគ្គលិកថ្មី។ ធ្វើការជ្រើសរើស និងពង្រាយគ្រូបង្រៀន ការរៀបចំសម្ភារៈជូនគ្រូបង្រៀនទៅតាមសេចក្តីណែនាំ ការធ្វើប្រតិភូកម្មនិយាមប្រើប្រាស់បុគ្គលិកអប់រំ និងគោលការណ៍ប្រើប្រាស់បុគ្គលិកអប់រំ និងធ្វើការពិនិត្យតាមដានវាយតម្លៃការជ្រើសរើស និងគ្រប់គ្រងគ្រូបង្រៀនដែលបានផ្ទេរទៅថ្នាក់ក្រោមជាតិ ដើម្បីកែលម្អ និងពង្រឹងការអនុវត្ត។ បង្កើនការចូលរួមរបស់គណៈកម្មការទ្រទ្រង់សាលារៀន និងអ្នកពាក់ព័ន្ធឲ្យកាន់តែសកម្ម ការធ្វើសេចក្តីសម្រេចចិត្តទាក់ទងទៅនឹងគ្រូបង្រៀន និងគ្រឹះស្ថានសិក្សា ការជ្រើសរើស ការផ្តល់រង្វាន់ ការពិន័យ ការផ្ទេរ ការវាយតម្លៃ វេទិកាសាធារណៈប្រជុំសិស្ស ការវាយតម្លៃសេវាមូលដ្ឋាន និងការបង្រៀនបំណិនជីវិត។

## ២.៨.៣.ការលើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀន

ការលើកកម្ពស់លក្ខខណ្ឌការងារ និងការរស់នៅរបស់គ្រូបង្រៀន តាមរយៈការផ្តល់បៀវត្សរ៍លាភការសុខមាលភាពសង្គម អត្ថប្រយោជន៍ទូទៅ អត្ថប្រយោជន៍ពេលចូលនិវត្តន៍ ជាពិសេសលោកគ្រូ អ្នកគ្រូបង្រៀនបម្រើការងារនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។ លើកកម្ពស់សុខមាលភាពសង្គមរបស់គ្រូបង្រៀន គឺត្រូវរៀបចំសំណើច្បាស់លាស់មួយទាក់ទងនឹងកញ្ចប់បៀវត្សរ៍និងកាំប្រាក់ ប្រាក់វិភាជន៍គ្រួសាររបស់គ្រូបង្រៀន។ សិក្សា និងកសាងផែនការកែលម្អសុខមាលភាពសង្គម សម្រាប់គ្រូបង្រៀនពេញមួយជីវិត ការធានាពិនិត្យសុខភាពមិនបង់ប្រាក់ ធានាអាយុជីវិត កម្មវិធីកម្ចី ឥណទាន ឧបត្ថម្ភធនធានសម្រាប់សង់ផ្ទះ ប្រាក់ម៉ោងបន្ថែម ប្រាក់ឧបត្ថម្ភគ្រូបង្រៀន រួមទាំងរបបសោធននិវត្តន៍។ ផ្តល់ឯកសារ និងសម្ភារៈបរិក្ខារសម្រាប់គ្រូបង្រៀន និងរៀន ផ្តល់ការលើកទឹកចិត្តឲ្យគ្រូបន្តអភិវឌ្ឍន៍សមត្ថភាពជាប្រចាំ និងផ្តល់ឯកសារសម្រាប់ស្រាវជ្រាវជូនគ្រូបន្ថែម។

ទទួលស្គាល់ និងជូនរង្វាន់ដល់គ្រូបង្រៀនដែលមានស្នាដៃល្អ និងជួយលើកទឹកចិត្តបន្ថែម ឲ្យគ្រូបង្រៀនបន្តធ្វើអ្វីដែលជាអំពើល្អដល់សិស្ស សាលា និងសហគមន៍។ ការផ្តល់រង្វាន់ ត្រូវធានាបានដល់គ្រូបង្រៀនដោយផ្តោតលើលទ្ធផល ទាំងការបំពេញការងារ ទាំងការរៀន បង្រៀន ការស្រាវជ្រាវ និងកិច្ចការ

សាលារៀនផ្សេងៗជាច្រើនទៀត។ ធ្វើការសិក្សា និងកែសម្រួលសេចក្តីណែនាំ លក្ខណៈវិនិច្ឆ័យ នៃការផ្តល់
ជូនរង្វាន់ដល់គ្រូបង្រៀន សមត្ថភាព វាស់បាន តម្លាភាព និងផ្អែកលើស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន និងការសិក្សាស្រាវជ្រាវ ព្រមទាំងគ្រូបង្រៀនដែលចូលនិវត្តន៍មានបទពិសោធន៍ ចំណេះដឹង និងស្នាដៃ។ ធ្វើការបើកវគ្គបំប៉នអំពីសេចក្តីណែនាំថ្មី ស្តីពីការជូនរង្វាន់ដល់គ្រូបង្រៀន គ្រូបង្រៀនឆ្នើម គ្រូបង្រៀនល្អ គ្រូបង្រៀនដែលបម្រើការងារច្រើនឆ្នាំក្នុងក្រសួងអប់រំ យុវជន និងកីឡា បូករួមទាំងគ្រូចូលនិវត្តន៍ ដែលមានស្នាដៃ និងបទពិសោធន៍ល្អ។ រៀបចំឲ្យមានវេទិកាប្រគល់រង្វាន់ដល់គ្រូបង្រៀនឆ្នើម ចែករំលែកនៅទូទាំងប្រទេស ដើម្បីបង្ហាញជាបទពិសោធន៍ដល់គ្រូបង្រៀន ដែលទើបបាន៥ឆ្នាំ ឬគ្រូចេញបង្រៀនថ្មី។

## ២.៩.បញ្ហាប្រឈម ចំពោះការបែងចែកធនធានមនុស្ស

ការរៀបចំគ្រូបង្រៀនផ្នែកមធ្យមសិក្សាបឋមភូមិ មានបញ្ហាប្រឈមខ្ពស់ជាងនៅកម្រិតបឋមសិក្សាយ៉ាងច្រើន ដូចជាការពង្រាយគ្រូទៅតាមមុខវិជ្ជាដោយសមធម៌ នៅមានភាពស្មុគស្មាញមិនច្បាស់លាស់គួរតែលើកយកមកពិចារណាឡើងវិញឲ្យបានត្រឹមត្រូវ។ បញ្ហាប្រឈមទាំងនេះ កាន់តែមានភាពស្មុគស្មាញឡើងទាក់ទងទៅនឹងការជ្រើសគ្រូបង្រៀន គ្រូចេញថ្មី និងការរក្សាទុកគ្រូបង្រៀនឲ្យស្ថិតនៅក្នុងវិជ្ជាជីវៈរបស់គាត់គ្រប់ភូមិសិក្សាទៅតាមកម្រិតគុណវុឌ្ឍិគ្រូបង្រៀន។ បញ្ហាប្រឈមមួយទៀតនោះគឺការស្នើសុំគ្រូថ្មីមិនបានដូចតាមការស្នើសុំរបស់នាយកសាលាទាំងកម្រិតបឋមភូមិ និងបឋមសិក្សា។ បញ្ហា ទាក់ទងនឹងការបែងចែកធនធានមនុស្សនៅមធ្យមសិក្សាបឋមភូមិ រួមមាន៖

- ✓ ការលើស និងខ្វះបុគ្គលិក៖ការផ្គត់ផ្គង់គ្រូបង្រៀន តែងតែជួបនូវស្ថានភាពនៃការលើស និងខ្វះបុគ្គលិកនៅកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជាឯកទេស តាមតំបន់ជនបទ និងតាមតំបន់ដាច់ស្រយាល ហើយជាទូទៅនៅតំបន់ទីប្រជុំជនតែងតែមានលក្ខណៈលើសជាធម្មតា។ បាតុភូតបែបនេះបង្ហាញថា ការធ្វើផែនការ គឺគ្មានភាពច្បាស់លាស់ មិនមានតុល្យភាពក្នុ ងការជ្រើសរើសគ្រូនិងមានបញ្ហានៅក្នុងដំណើរការនៃការពង្រាយគ្រូ។
- ✓ ការវិចវិល៖កើតមានច្រើននៅកម្រិតមធ្យមសិក្សាបឋមភូមិ ហើយការវិចវិលក៏ច្រើនកើតឡើងនៅកម្រិតមធ្យមដែរ ដូច្នេះត្រូវលើកយកមកពិចារណាឲ្យបានច្បាស់លាស់ពិសេសនៅពេលធ្វើផែនការជ្រើសរើសគ្រូបង្រៀន។
- ✓ បញ្ហាប្រើប្រាស់គ្រូមិនសមស្រប៖គ្រូបង្រៀនតិចម៉ោង នាំឲ្យមានសមភាពទៅនឹង អត្រានៃការប្រើប្រាស់គ្រូបង្រៀន និងនាំឲ្យមានការចំណាយថវិកាខ្ពស់នៅក្នុងប្រព័ន្ធអប់រំ។ បញ្ហាទាំងអស់នេះកើតឡើងដោយការប្រើប្រាស់គ្រូមិនបានត្រឹមត្រូវ មិនមានប្រសិទ្ធភាពទៅតាមនិយាមកំណត់ ឬក៏មិនបានជំរុញឲ្យប្រើប្រាស់ទៅតាមនិយាមដែលបានកំណត់ទៅតាមគោលការណ៍របស់ក្រសួង។
- ✓ ការបែងចែក៖ស្ថានភាពនេះ នៅមានភាពលំអៀង ក្នុងការពង្រាយគ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងតំបន់នានា តាមទីរួមខេត្ត ទីប្រជុំជន តំបន់ជនបទ តំបន់ដាច់ស្រយាល តំបន់ជួបការលំបាក និងក្នុងចំណោមសាលារៀន យេនឌ័រ មុខវិជ្ជាឯកទេស និងគ្រូដែលមានគុណភាព។ ការបែងចែកនេះបង្កើតឲ្យមានការរិះគន់ពាក់ព័ន្ធទៅនឹងការបែងចែកនិយាមនិងផែនការបែងចែកចាត់ចែងគ្រូបង្រៀននិងការដាក់កម្រិតឬបង្ខំឲ្យគេប្រតិបត្តិតាម។

- ✓ ការខ្វះឬលើសគ្រូះការខ្វះគ្រូបង្រៀននៅតាមសាលារៀនមួយចំនួន គឺធ្វើឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរនៅតាមតំបន់ជនបទជាច្រើន។ តែវាមិនមានខុសប្លែកអ្វីនោះទេ ក្នុងនោះយើងអាចស្វែងរកដំណោះស្រាយបាន ដូចជាគ្រូកម្រិតមធ្យម យើងជ្រើសរើសគ្រូមធ្យមសិក្សាបឋមភូមិពីសាលាក្បែរគ្នា មកជួយបង្រៀន ដោយផ្តល់ប្រាក់ម៉ោងបន្ថែមជូនគាត់ ទៅតាមនិយាម និងតាមច្បាប់កំណត់។

## ២.១០.ចំនួនគ្រូបង្រៀនៈ ចំណោល និងបញ្ហាប្រឈម

តារាងខាងក្រោមនេះ បានបង្ហាញថា កំណើនខ្ពស់នៃតម្រូវការគ្រូបង្រៀន នៅមធ្យមសិក្សាបឋមភូមិ ពាក់ព័ន្ធនឹងការបណ្តុះបណ្តាលគ្រូ ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ គ្រូមធ្យមសិក្សាបឋមភូមិមានចំនួន១៩៩៣ និងគ្រូបង្រៀនបឋមសិក្សាមានចំនួន១២៣៤ និងត្រូវជ្រើសរើសបន្ថែមដើម្បីឆ្លើយតបទៅនឹងកំណើនចំនួនសិស្សថ្មីនៅកម្រិតបឋមភូមិ។ ក្នុងស្ថានភាពបែបនេះ ត្រូវចោទជាសំណួរទៅលើរចនាសម្ព័ន្ធបច្ចុប្បន្ន ក្នុងដំណើរការជ្រើសរើសគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិ និងបឋមសិក្សា នៅក្នុងប្រទេសកម្ពុជា។ ខណៈពេលដែលតម្រូវការគ្រូនៅកម្រិតមធ្យមមានការកើនឡើងច្រើន នៅឆ្នាំ២០១៩ ចំនួនអ្នកបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ដែលដាក់ពាក្យប្រឡងធ្វើគ្រូនៅតាមគ្រឹះស្ថានបណ្តុះបណ្តាល និងវិក្រឹត្យការគ្រូមានការកើនឡើងកាន់តែខ្លាំង ដូច្នេះការបែងចែកចំនួនទៅតាមខេត្តនីមួយៗមានចំនួនតិច( ចំនួនកំណត់ )ដែលនឹងនាំឱ្យមានគម្លាតរវាងគ្រូបង្រៀន និងសិស្សនៅកម្រិតមធ្យមសិក្សាដែលកំពុងតែមានកំណើនខ្ពស់។ តាមនិន្នាការនេះ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើការកែទម្រង់ការជ្រើសគ្រូបង្រៀនកម្រិតបឋមភូមិ និងបឋមសិក្សា ដោយផ្តល់អត្ថប្រយោជន៍នានា ដើម្បីទាក់ទាញសិស្ស និងនិស្សិតដែលបានបញ្ចប់ការសិក្សាឱ្យជ្រើសរើសអាជីពជាគ្រូបង្រៀន ដោយសេចក្តីថ្លៃថ្នូរជាទីពេញចិត្ត។

# ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១.ដែនកំណត់ និងវិសាលភាព

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងចំពោះតែសាលាអនុវិទ្យាល័យនានា នៅទូទាំងខេត្តឧត្តរមានជ័យ ដែលមានស្រុកចំនួន៣ និងក្រុងមួយ រួមមានសាលារៀនអនុវិទ្យាល័យសរុបចំនួន៣៦សាលា។ ព័ត៌មានផ្សេងៗត្រូវបានផ្តល់ឱ្យដោយការិយាល័យអប់រំ យុវជន និងកីឡាស្រុក ក្រុង មន្ទីរអប់រំ យុវជន និងកីឡាខេត្ត នាយក នាយិកា នាយករង នាយិការង ហើយព័ត៌មានចាំបាច់ គឺចំនួនគ្រូដែលមានគុណវុឌ្ឍិគ្រូមធ្យមសិក្សាបឋមភូមិជាក់ស្តែង កំពុងបម្រើការងារនៅក្នុងសាលានិងចំនួនសិស្សនៅតាមអនុវិទ្យាល័យនីមួយៗ។

## ៣.២.ទីតាំងនៃការស្រាវជ្រាវ

ទីតាំងដែលបានធ្វើការសិក្សាស្រាវជ្រាវលើនិក្ខេបបទ ស្តីពី"ស្ថានភាពក្នុងការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យក្នុងប្រទេសកម្ពុជា៖ករណីសិក្សាគឺក្នុងខេត្តឧត្តរមានជ័យ។ ទិន្នន័យនេះ ត្រូវបានប្រមូលពីស្រុកចំនួន៣ និងក្រុង១ ដែលមានអនុវិទ្យាល័យសរុបចំនួន ៣៦។ នាយក នាយករង នាយិកា នាយិការងនៅតាមអនុវិទ្យាល័យនានាក្នុងខេត្តនេះ បានយកចិត្តទុកដាក់សហការ និងបានកោតសរសើរដល់កម្មវិធីបណ្តុះបណ្តាលវគ្គនាយកសាលាមធ្យមសិក្សាទុតិយភូមិរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្របតាមកំណែទម្រង់ទាំង១៥ចំណុចជាអាទិភាពក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

## ៣.៣.វិធីសាស្ត្រជ្រើសរើសអ្នកពាក់ព័ន្ធក្នុងការប្រមូលទិន្នន័យ

ការជ្រើសរើសអ្នកពាក់ព័ន្ធទី១ គឺមន្ទីរអប់រំ យុវជន និងកីឡា ខេត្តឧត្តរមានជ័យ ការិយាល័យផ្នែកផែនការ និងស្ថិតិ។ ការជ្រើសរើសនេះ ធ្វើតាមរយៈការផ្ទៀងផ្ទាត់ឯកសារតារាងSCE នៃអនុវិទ្យាល័យទាំងអស់ មុននឹងចុះប្រមូលទិន្នន័យ និងធ្វើការទាក់ទងទៅលោកនាយក-លោកស្រីនាយិកានៃសាលាអនុវិទ្យាល័យនីមួយៗ ដោយបានទទួលលទ្ធផល១០០%។

ការជ្រើសរើសអ្នកពាក់ព័ន្ធទី២ គឺការិយាល័យអប់រំ យុវជន និងកីឡា ស្រុក ទទួលបន្ទុកផ្នែកផែនការ និងស្ថិតិ ដោយធ្វើការផ្ទៀងផ្ទាត់ជាមួយទិន្នន័យរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ឲ្យបានគ្រប់ចំនួន និងមានសមភាពទិន្នន័យបានល្អប្រសើរ។

ការជ្រើសរើសអ្នកពាក់ព័ន្ធទី៣ គឺធ្វើទៅលើលោកនាយក នាយករង លោកស្រីនាយិកា នាយិការង និងលេខាធិការនៃអនុវិទ្យាល័យនីមួយៗ។ ចំពោះកម្រងសំណួរយកមកធ្វើសម្ភាសន៍ គឺផ្តល់ឲ្យពួកគាត់បំពេញតាមរយៈការពន្យល់ខ្លឹមសារនៃកម្រងសំណួរដែលមានស្រាប់ទាក់ទងនឹងប្រធានបទស្រាវជ្រាវ។

## ៣.៤.កម្រងសំណួរសម្រាប់គ្រូ

ការសិក្សាស្រាវជ្រាវនេះ គឺប្រើទិន្នន័យតាមបែបបរិមាណវិស័យ និងគុណវិស័យ។ ទិន្នន័យតាមបែបបរិមាណវិស័យគឺត្រូវបានប្រមូល តាមរយៈការបំពេញកម្រងសំណួរបិទ និងតាមការប្រមូលស្ថិតិតាម

សាលា។ ចំណែកឯការប្រមូលទិន្នន័យតាមបែបគុណវិស័យ ត្រូវបានប្រមូលតាមរយៈការបំពេញកម្រងសំណួរបើក។ កម្រងសំណួរត្រូវបានរៀបចំសម្រាប់នាយកសាលា នាយិកាសាលាបំពេញស្ថិតិរបស់សាលាចូលក្នុងកម្រងសំណួរ។ កម្រងសំណួរដែលពាក់ព័ន្ធការបំពេញស្ថិតិរបស់សាលារួមមានការបំពេញ ស្ថិតិគ្រូបង្រៀនសរុប ថ្នាក់ សិស្ស និងគ្រូបង្រៀនតាមមុខវិជ្ជាឯកទេស ស្ថិតិគ្រូដែលមានគុណវុឌ្ឍិ (គ្រូមធ្យមសិក្សាបឋមភូមិ) និងមុខវិជ្ជាបង្រៀនក្នុងកម្រិតថ្នាក់នីមួយៗ។ ទិន្នន័យទាំងអស់នេះ មានសារៈសំខាន់ណាស់ ដើម្បីឲ្យបានយល់ដឹងពីស្ថានភាព និងបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន នៅកម្រិតអនុវិទ្យាល័យ ក្នុងខេត្តឧត្តរមានជ័យនាពេលបច្ចុប្បន្ន។ ចំណែកឯការបំពេញកម្រងសំណួរបើក គឺដើម្បីស្វែងយល់ពីវិធីសាស្ត្ររបស់នាយកសាលាអនុវិទ្យាល័យនីមួយៗ ក្នុងការដោះស្រាយបញ្ហាប្រឈមនានា ជាពិសេសនៅពេលដែលមានបញ្ហាក្នុងករណីលើស ឬខ្វះគ្រូតាមមុខវិជ្ជាឯកទេសនីមួយៗ។

ការវិភាគទិន្នន័យតាមបែបបរិមាណវិស័យគឺវិភាគតាមក្រាហ្វ ភាគរយ និងតារាង Bar Chatដោយប្រើកម្មវិធីEXCEL។ ការវិភាគទិន្នន័យតាមបែបគុណវិស័យ គឺវិភាគតាមរយៈការចាត់ថ្នាក់ជាក្រុម និងដាក់ចំណងជើងដោយផ្អែកលើទស្សនៈនិងអត្ថន័យនៃប្រយោគដែលមានលក្ខណៈស្រដៀងគ្នារួចហើយធ្វើការបរិយាយ និងពន្យល់តាមចំណាត់ថ្នាក់នៃក្រុមនីមួយៗឲ្យបានច្បាស់លាស់។

**១.កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង**

**ក**.ស្ថានភាពទូទៅរបស់គណៈគ្រប់គ្រងអនុវិទ្យាល័យ៖ នៅក្នុងផ្នែកនេះ មានការដាក់បញ្ចូលព័ត៌មាន ដូចជាឈ្មោះអនុវិទ្យាល័យ ចំនួនបុគ្គលិកបង្រៀន និងសិស្សរៀនជាក់ស្តែងតាមអនុវិទ្យាល័យនីមួយៗ និងកម្រិតសិក្សាជាដើម។ នៅចំណុចនេះ តម្រូវឲ្យលោកនាយក នាយិកា ឬគណៈគ្រប់គ្រងសាលាជ្រើសរើសយកចម្លើយមួយដែលបញ្ជាក់ពីស្ថានភាពជាក់ស្តែងរបស់ពួកគាត់ដែលបានអនុវត្តន៍កន្លងមក។

**ខ**.ព័ត៌មានទាក់ទងការគ្រប់គ្រង និងបែងចែកភារកិច្ចបុគ្គលិករបស់នាយកអនុវិទ្យាល័យ៖ នៅក្នុងចំណុច**ខ**នេះ អ្នកសិក្សាស្រាវជ្រាវបានរៀបរាប់សំណួរចំនួន ៩៩% ដែលផ្តោតលើការគ្រប់គ្រងបុគ្គលិករបស់អង្គភាព ការសិក្សាស្វែងយល់ពីទិន្នន័យគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិ ទៅតាមឯកទេសដែលសាលារៀននីមួយៗមានជាក់ស្តែង សិក្សាស្វែងយល់ពីគ្រូបង្រៀននីមួយៗដែលសាលាកំពុងប្រើប្រាស់ជាក់ស្តែង ទិន្នន័យចំនួនថ្នាក់ជាក់ស្តែង( ទី៧,៨,៩ )ដែលសាលានីមួយៗមាន ម៉ោងបង្រៀនជាក់ស្តែង ទិន្នន័យចំនួនម៉ោងសរុប នៃមុខវិជ្ជាឯកទេសនីមួយៗដែលកំពុងអនុវត្តជាក់ស្តែង។

## ៣.៥.វិភាគទិន្នន័យ

ការវិភាគទិន្នន័យគឺប្រើវិធីសាស្ត្រគុណវិស័យ រួមមានពាក្យសម្តីតាមរយៈការធ្វើសម្ភាស និងអង្កេត។ ចំណែកវិធីសាស្ត្រគុណវិស័យ រួមមានលេខ ចំនួន ភាគរយ ដូច្នេះការវិភាគទិន្នន័យពឹងផ្អែកលើការពិពណ៌នា និងគណនាយ៉ាងប្រុងប្រយ័ត្នពីអ្នកចូលរួម ហើយការសិក្សានេះសំអាងលើការរកឃើញពីការធ្វើ

សម្ភាសន៍ និងបញ្ជីសំណួរ។ ការសិក្សាស្រាវជ្រាវនេះ ត្រូវបានសម្រេចតាមវិធីសាស្ត្របរិមាណវិស័យ និងគុណវិស័យ ព្រោះអ្នកចូលរួមបានយល់ដឹងយ៉ាងជ្រាលជ្រៅនៃបាតុភូតដ៏ជាក់លាក់ ហើយមានការសហ

ការជាមួយអ្នកចូលរួមក្នុងការសិក្សានេះ។ អ្នកសិក្សាស្រាវជ្រាវថែមទាំងបានសម្ភាសន៍ និងបំពេញកម្រងសំណួរជាមួយគណៈគ្រប់គ្រងទៀតផង។

## ៣.៦.និតិវិធី ឬដំណើរការប្រមូលទិន្នន័យ

ការចុះធ្វើការសិក្សាស្រាវជ្រាវនៅតាមទីកន្លែងដែលបានជ្រើសរើសនេះ គឺចាប់ពីថ្ងៃទី២៩ ខែមិថុនាឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ និងធ្វើឡើងបន្ទាប់ពីឧបករណ៍ស្រាវជ្រាវនានាបានរៀបចំរួចស្រេចក្រោយពេលទទួលបានការអនុញ្ញាតពីវិទ្យាស្ថានជាតិអប់រំ ដើម្បីដំណើរការរៀបចំ និងប្រមូលទិន្នន័យ ព្រមទាំងការយល់ព្រម និងឯកភាពពីគណៈគ្រប់គ្រងអនុវិទ្យាល័យគោលដៅ។ ចំណែកឯក្រមសីធម៌ដើរតួនាទីសំខាន់ណាស់សម្រាប់អ្នកសិក្សាស្រាវជ្រាវ បើអ្នកសិក្សាស្រាវជ្រាវគ្មានក្រមសីលធម៌នោះទេហាក់បីដូចជាគ្មានតម្លៃទាល់តែសោះ។ ដូច្នេះហើយមុនពេលប្រមូលទិន្នន័យ អ្នកស្រាវជ្រាវ ត្រូវសុំការអនុញ្ញាតពីនាយក ប្រធានអង្គភាព និងមានការអនុម័តពីក្រសួង។ បន្ទាប់មក អ្នកស្រាវជ្រាវធ្វើលិខិតអនុញ្ញតជាមួយគោលបំណងនៃការសិក្សាដ៏ជាក់លាក់ទៅកាន់អង្គភាពពាក់ព័ន្ធ គណៈគ្រប់គ្រង អនុវិទ្យាល័យ ហើយត្រូវស្នើសុំការយល់ព្រមពីនាយកសាលា នាយករង នាយិកា នាយិការង។ អ្នកសិក្សាស្រាវជ្រាវសុំការអនុញ្ញាតពីអ្នកចូលរួមដោយកត់ត្រាពាក្យសម្ដី និងថតសម្លេងនៅពេលសម្ភាសន៍។ម្យ៉ាងទៀត អ្នកចូលរួមអាចបដិសេធមិនឆ្លើយសំណួរ ឬរំលងសំណួរ ឬឈប់ឆ្លើយសំណួរនៅពេលពួកគេមានបំណងមិនឆ្លើយ ឬមិនសប្បាយចិត្ត។

# ជំពូកទី៤ លទ្ធផលស្រាវជ្រាវ

ទិន្នន័យដែលបានមកពីកម្រងសំណួរ ត្រូវបានយកមកវិភាគជារួមសម្រាប់ខេត្តឧត្តរមានជ័យទាំងមូល និងយកមកវិភាគទៅតាមអនុវិទ្យាល័យនីមួយៗដូចខាងក្រោមនេះ៖

## ៤.១ អនុ.វិទ្យាល័យទាំង ៣៦ ក្នុងខេត្តឧត្តរមានជ័យ

តាមការសិក្សាស្រាវជ្រាវទៅលើអនុវិទ្យាល័យទូទាំងខេត្ត បានបង្ហាញថា ចំនួនថ្នាក់រៀនសរុបមាន ២១៤ ថ្នាក់ មានគ្រូបង្រៀនកម្រិតបឋមភូមិចំនួន ៤៧៥នាក់ ហើយមានសិស្សសរុបគិតពីថ្នាក់ទី៧ ដល់ទី៩ មានចំនួន៩៩៦៧នាក់។

បើគិតទៅតាមនិយាមសិស្ស១ថ្នាក់ចំនួន៤៥នាក់ នោះចំនួនថ្នាក់រៀនស្មើនឹង២២១ ថ្នាក់( ៩៩៦៧ នាក់ ចែកនឹង៤៥) ចំណែកចំនួនម៉ោងគឺគិតតាមនិយាម ៣២ម៉ោងក្នុង១សប្តាហ៍ នាំឲ្យយើងទទួលបានចំនួនម៉ោងសរុប ៧០៧២ ម៉ោងសិក្សា (២២១ថ្នាក់គុណនឹង៣២ម៉ោង) ហើយត្រូវការគ្រូបង្រៀនចំនួន ៣៩៣ នាក់ (៧០៧២ នាក់ចែកនឹង១៨ ម៉ោង)។

បើយើងធ្វើការប្រៀបធៀបចំនួនទិន្នន័យដែលទទួលបានជាក់ស្តែងធៀបនឹងចំនួនតម្រូវការ តាមនិយាមរបស់ក្រសួងអប់រំ យុវជន និងកីឡា បានឲ្យដឹងថា ចំនួនថ្នាក់ ២១៤ តិចជាងចំនួនថ្នាក់រៀនតាមនិយាម ០៧ ថ្នាក់ (២២១ ដក ២១៤) នេះសបញ្ជាក់ឲ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យពុំទាន់បានគោរពត្រឹមត្រូវនៅឡើយទេ។ ចំណែកគ្រូបង្រៀនដែលមានគុណវុឌ្ឍិគ្រូមធ្យមសិក្សាបឋមភូមិ ដែលកំពុងបង្រៀនជាក់ស្តែងចំនួន ៤៧៥ នាក់ ច្រើនជាងនិយាមចំនួន៨២នាក់(៣៩៣ ដក ៤៧៥) មានន័យថាលើសគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិចំនួន ៨២នាក់ នេះបើគិតតាមនិយាម ដែលបានកំណត់ដោយច្បាប់។

**តារាងទី១៖ ស្ថិតិ សិស្ស ថ្នាក់ ម៉ោង និងចំនួនគ្រូតាមតម្រូវការ និងតាមការជាក់ស្តែង**

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ៩៩៦៧ | ៩៩៦៧ |
| ថ្នាក់ | ២២១ | ២១៤ |
| ម៉ោង | ៧០៧២ | ៦៨៤៨ |
| គ្រូ | ៣៩៣ | ៤៧៥ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ៤៧៥ | |

តាមការវិភាគ បើទោះបីជាមានការលើសគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិយ៉ាងច្រើនដូចនេះក៏ដោយ ក៏មិនប្រាកដ ឬបញ្ជាក់ថា លើសគ្រូគ្រប់មុខវិជ្ជានោះដែរ ពីព្រោះចំនួនគ្រូបង្រៀនដែលគិតទៅតាមនិយាម និងចំនួនគ្រូបង្រៀនដែលកំពុងបង្រៀនជាក់ស្តែងគឺមានមុខវិជ្ជាខ្លះគ្រប់ មុខវិជ្ជាខ្លះខ្វះ និងមុខវិជ្ជាមួយចំនួនលើស ដូចបង្ហាញក្នុងក្រាបទី១។ មុខវិជ្ជាដែលខ្វះរួមមានមុខវិជ្ជាគណិតវិទ្យា មុខវិជ្ជាអក្សរសាស្ត្រខ្មែរ មុខវិជ្ជាគីមីវិទ្យា មុខវិជ្ជាផែនដីវិទ្យា មុខវិជ្ជាភូមិវិទ្យា មុខវិជ្ជាសីលធម៌ពលរដ្ឋ មុខវិជ្ជាICT មុខវិជ្ជាគេហវិទ្យា និងមុខវិជ្ជាអប់រំកាយជាដើម។ រីឯមុខវិជ្ជាដែលលើសពីតម្រូវការរួមមានមុខវិជ្ជាជីវវិទ្យា មុខវិជ្ជារូបវិទ្យា មុខវិជ្ជាប្រវត្តិវិទ្យា និងមុខវិជ្ជាភាសាបរទេស។ លទ្ធផលនេះបង្ហាញឱ្យឃើញថាការបែងចែកគ្រូបង្រៀនពីក្រសួងទៅមន្ទីរគឺមិនទាន់បានត្រឹមត្រូវនៅឡើយ។

**ក្រាបទី១៖ គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**
**១.អនុវិទ្យាល័យទាំង ៣៦ ក្នុងខេត្តឧត្តរមានជ័យ**




## ៤.២ វិទ្យាល័យហ៊ុន សែនចុងកាល់៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

លទ្ធផលស្រាវជ្រាវវិទ្យាល័យទី១ នៃខេត្តឧត្តរមានជ័យមានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែលកំពុងសិក្សាពីថ្នាក់ទី ៧ ៨ ៩ មានចំនួន ៣២៥ នាក់ ស្មើនឹង ១៧ ថ្នាក់។ តាមការរកឃើញថាមានចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន៥៤៤ម៉ោង និងមានគ្រូកម្រិតបឋមភូមិ១៧ នាក់។

តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោង ក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ២២៤ម៉ោង (៧ថ្នាក់គុណនឹង៣២ម៉ោង)ក្នុងវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន១២ នាក់(២២៤ម៉ោងចែកនឹង១៨ថ្នាក់)។នេះបញ្ជាក់ឲ្យឃើញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់សិស្ស និងគ្រូរបស់វិទ្យាល័យមិនទាន់បានគោរពទៅតាមនិយាមកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡាឡើយ។ តាមការរកឃើញចំនួនមុខវិជ្ជាវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ១៣មុខវិជ្ជា ដោយមិនបានគោរពតាមនិយាមរបស់ក្រសួង ដែលកំណត់ឲ្យបង្រៀនចំនួន១៥មុខវិជ្ជានៅតាមវិទ្យាល័យ។

**តារាងទី២៖**

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ៣២៥នាក់ | ៣២៥នាក់ |
| ថ្នាក់ | ០៧ | ១៧ |
| ម៉ោង | ២២៤ | ៥៤៤ |
| គ្រូ | ១២ | ៣៥ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ១៥ | |

ក្រាបទី២៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែ
២.វិទ្យាល័យហ៊ុនសែន ចុងកាល់




## ៤.៣ វិទ្យាល័យ ហ៊ុនសែនពង្រ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

លទ្ធផលស្រាវជ្រាវវិទ្យាល័យទី២ នៃខេត្តឧត្តរមានជ័យមានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ៣០៦ នាក់ ស្មើនិង ១០ ថ្នាក់។ តាមការរកឃើញថាមានចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន៣២០ម៉ោង និងគ្រូកម្រិតបឋមភូមិ១២នាក់។

តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ២២៤ម៉ោង( ០៧ថ្នាក់គុណនិង៣២ម៉ោង )ក្នុងវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន១២ នាក់(២២៤ម៉ោងចែកនិង១៨ថ្នាក់ )។ តាមតារាងជាក់ស្តែងចំនួនសិស្ស ៣០៦ នាក់ ស្មើនិង ០៧ ថ្នាក់

ធ្វើឲ្យចំនួន សិស្ស ថ្នាក់ ម៉ោង និងចំនួនគ្រូសមស្របតាមនិយាម ទៅនិងចំនួនគ្រូដែលមានគុណវុឌ្ឍិសរុប ចំនួន១២នាក់ ដែលបង្រៀននៅវិទ្យាល័យនេះ។

**តារាងទី៣៖**

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ៣០៦នាក់ | ៣០៦នាក់ |
| ថ្នាក់ | ០៧ | ១០ |
| ម៉ោង | ២២៤ | ៥៤៤ |
| គ្រូ | ១២ | ១៥ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ១៥ | |

**ក្រាបទី៖ ៣ គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**៣.វិទ្យាល័យហ៊ុនសែន ពង្រ**




## ៤.៤ អនុវិទ្យាល័យជើងឡៀន ៖ ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

លទ្ធផលស្រាវជ្រាវអនុវិទ្យាល័យទី៣ នៃខេត្តឧត្តរមានជ័យមានបង្ហាញឲ្យឃើញថា ស្ថិតិសិស្ស ដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ១៧០ នាក់ ស្មើនិង ០៥ ថ្នាក់។ តាមការរកឃើញថាមាន ចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន ១៦០ ម៉ោង និងគ្រូកម្រិតបឋមភូមិកំពុង បង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន១២នាក់។

តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប

១២០ម៉ោង( ០៤ថ្នាក់គុណនិង៣២ម៉ោង )ក្នុងវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន០៧ នាក់( ១២០ម៉ោងចែកនិង០៧ថ្នាក់ )។នេះបញ្ជាក់ឲ្យឃើញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់ សិស្ស និងគ្រូរបស់អនុវិទ្យាល័យគោរពមិនទាន់បានទៅតាមនិយាមកំណត់ដោយក្រសួង អប់រំយុវជន និង កីឡាឡើយ។ តាមការរកឃើញចំនួនមុខវិជ្ជាវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ១២មុខវិជ្ជា ដោយ មិនបានគោរពតាមនិយាមរបស់ក្រសួង ដែលកំណត់ឲ្យបង្រៀនចំនួយ១៤មុខវិជ្ជានៅតាមវិទ្យាល័យ។

តារាងទី៤៖

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ១៧០នាក់ | ១៧០នាក់ |
| ថ្នាក់ | ០៤ | ០៥ |
| ម៉ោង | ១២០ | ១៦០ |
| គ្រូ | ០៧ | ១១ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ១១ | |

**ក្រាបទី៤៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**៤.អនុវិទ្យាល័យ ជើងទៀន**




## ៤.៥ អនុវិទ្យាល័យគោកស្លានៈស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

លទ្ធផលស្រាវជ្រាវវិទ្យាល័យទី៤ នៃខេត្តឧត្តរមានជ័យមានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែល បានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ១៧៦ នាក់ ស្មើនិង ០៤ ថ្នាក់។ តាមការរកឃើញថាមាន

ចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន១២៨ម៉ោង និងគ្រូកម្រិតបឋមភូមិ បង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន០៧នាក់។

តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ១២៨ម៉ោង( ០៤ថ្នាក់គុណនិង៣២ម៉ោង )នៅក្នុងអនុវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិ ចំនួន០៧នាក់( ១២៨ម៉ោងចែកនិង១៨ថ្នាក់ )។នេះបញ្ជាក់ឲ្យឃើញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់ សិស្ស និងគ្រូរបស់អនុវិទ្យាល័យគោរពមទៅតាមនិយាមកំណត់ដោយក្រសួង អប់រំយុវជន និងកីឡា។ តាមការរកឃើញចំនួនមុខវិជ្ជាអនុវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ១០មុខវិជ្ជា ដោយមានការខ្វះខាតគ្រូបង្រៀនទើបមិនបានគោរពតាមនិយាមរបស់ក្រសួង ដែលកំណត់ឲ្យបង្រៀនចំនួន១៤មុខវិជ្ជានៅតាមអនុវិទ្យាល័យឡើយ។

**តារាងទី៥៖**

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ១៧៦នាក់ | ១៧៦នាក់ |
| ថ្នាក់ | ០៤ | ០៤ |
| ម៉ោង | ១២៨ | ១២៨ |
| គ្រូ | ០៧ | ០៨ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៨ | |

**ក្រាបទី៥៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**៥.អនុវិទ្យាល័យគោកស្គន**



## ៤.៦ អនុវិទ្យាល័យ សម្តេចតេជោ សែន ចុងកាល់៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

លទ្ធផលស្រាវជ្រាវ នៃខេត្តឧត្តរមានជ័យក្នុងអនុវិទ្យាល័យ តេជោសែន មានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែលស្រង់ពីអនុវិទ្យាល័យថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ២១៩ នាក់ ស្មើនិង ០៦ ថ្នាក់។ តាមការរកឃើញថាមានចំនួនម៉ោងពិតប្រាកដដែលអនុវិទ្យាល័យកំពុងបង្រៀនចំនួន១៩២ម៉ោង និងមានគ្រូកម្រិតបឋមភូមិចំនួន នីមួយៗមានចំនួន០៨នាក់។តាមនិយាមថ្នាក់សិស្ស៤៥នាក់គឺ( ៥ថ្នាក់គុណ ៣២ )ស្មើម៉ោងសរុបចំនួន១៦០ ម៉ោង ហើយមានគ្រូសរុប០៩នាក់។និយាមម៉ោងសិស្សមួយថ្នាក់ត្រូវរៀន ៣២ម៉ោងក្នុងមួយសប្តាហ៍។នេះបញ្ជាក់ឲ្យឃោះញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់សិស្ស និងគ្រូអនុវិទ្យាល័យគោរពមិនទាន់បានទៅតាមនិយាមកំណត់ឡើយ។ តាមការរកឃើញចំនួនមុខវិជ្ជាអនុវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ១២មុខវិជ្ជា ដោយមិនបានគោរពតាមនិយាមរបស់ក្រសួង ដែលកំណត់ឲ្យបង្រៀនចំនួយ១៤មុខវិជ្ជានៅតាមវិទ្យាល័យ។

**តារាងទី៦៖**

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ២១៩នាក់ | ២១៩នាក់ |
| ថ្នាក់ | ០៥ | ០៦ |
| ម៉ោង | ១៦០ | ១២៩ |
| គ្រូ | ០៩ | ០៨ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៨ | |

**ក្រាបទី៦៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**៦.អនុវិទ្យាល័យសម្តេចតេជោ សែន ចុងកាល់**



## ៤.៧ វិទ្យាល័យ តេជោសែនសំរោង ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

លទ្ធផលស្រាវជ្រាវវិទ្យាល័យទី១ នៃខេត្តឧត្តរមានជ័យមានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ១២៦៤ នាក់ ស្មើនិង ៣៤ ថ្នាក់។ តាមការរកឃើញថាមានចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន១០៨៨ម៉ោង និងមានគ្រូកម្រិតមបមភូមិចំនួន ៤២នាក់ ។

តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ៨៩៦ម៉ោង( ២៨ថ្នាក់គុណនិង៣២ម៉ោង )ក្នុងវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបបមភូមិចំនួន៥០ នាក់( ៨៩៦ម៉ោងចែកនិង១៨ថ្នាក់ )។នេះបញ្ជាក់ឲ្យឃោះញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់ សិស្ស និងគ្រូរបស់វិទ្យាល័យគោរពមិនទាន់បានទៅតាមច្បាប់និយាមដែលកំណត់ដោយក្រសួងអប់រំ។ តាមការរកឃើញចំនួនមុខវិជ្ជាវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ១២មុខវិជ្ជា ដោយមិនបានគោរពតាមនិយាមរបស់ក្រសួង ដែលកំណត់ឲ្យបង្រៀនចំនួយ១៤មុខវិជ្ជានៅតាមវិទ្យាល័យ។

**តារាងទី៧៖**

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ១២៦៤នាក់ | ១២៦៤នាក់ |
| ថ្នាក់ | ២៨ | ៣៤ |
| ម៉ោង | ៨៩៦ | ១០៨៨ |
| គ្រូ | ៥០ | ៤២ |
| គ្រូដែលមានគុណវុឌ្ឍបបមភូមិ | ៤២ | |

**ក្រាបទី៧៖គ្រូកម្រិតមធ្យមសិក្សាបបមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**៧.វិទ្យាល័យ តេជោសែនសំរោង**



## ៤.៨ អនុវិទ្យាល័យ កូនក្រៀល ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

លទ្ធផលស្រាវជ្រាវអនុវិទ្យាល័យ នៃខេត្តឧត្តរមានជ័យមានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ២៥៦ នាក់ ស្មើនិង ០៦ ថ្នាក់។ តាមការរកឃើញថាមានចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន១៩២ម៉ោង និងមានគ្រូកម្រិតបឋមភូមិបង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន០៣នាក់។

បើតាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ១៩២ម៉ោង( ០៦ថ្នាក់គុណនិង៣២ម៉ោង )ក្នុងវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន០៧នាក់( ១៩៣ម៉ោងចែកនិង១៨ថ្នាក់ )។នេះបញ្ជាក់ឲ្យឃើញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់ សិស្ស និងគ្រូរបស់អនុវិទ្យាល័យនេះមិនទាន់បានទៅតាមនិយាមកំណត់ដោយច្បាប់របស់ក្រសួង អប់រំយុវជន និងកីឡានៅឡើយនោះទេ។ តាមការរកឃើញចំនួនមុខវិជ្ជាដែលអនុវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ១២មុខវិជ្ជាតែប៉ុណ្ណោះដែលកំពុងអនុវត្តន៍។

**តារាងទី៨៖**

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ២៥៦នាក់ | ២៥៦នាក់ |
| ថ្នាក់ | ០៦ | ០៦ |
| ម៉ោង | ១៩២ | ១៩២ |
| គ្រូ | ០៧ | ០៣ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៩ | |

ក្រាបទី៨៖ គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង

៨.អនុវិទ្យាល័យកូនក្រៀល



## ៤.៩ អនុវិទ្យាល័យ ហ៊ុនសែន រួតចំប៉ី ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

តាមលទ្ធផលស្រាវជ្រាវអនុវិទ្យាល័យ នៃខេត្តឧត្តរមានជ័យបានបង្ហាញឲ្យឃើញថា ស្ថិតិសិស្ស ដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ៣៧២ នាក់ ស្មើនិង ០៧ ថ្នាក់។ តាមការរកឃើញថា មានចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួនម៉ោង ២២៤ដែលមានគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិ កំពុងបង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន០៩នាក់។

បើគិតតាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប២៥៦ម៉ោង(០៨ថ្នាក់គុណនិង៣២ម៉ោង)ក្នុងវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន ១៤នាក់(២៥៦ម៉ោងចែកនិង១៨ម៉ោង)។នេះសបញ្ជាក់យ៉ាងច្បាស់ថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់ សិស្ស និងគ្រូនៃអនុវិទ្យាល័យនេះមិនទាន់បានគោរពទៅតាមនិយាមកំណត់ ។តាមការរកឃើញចំនួនមុខវិជ្ជាអនុវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ១២មុខវិជ្ជា ដោយមិនបានគោរពតាមនិយាមរបស់ក្រសួងដែលកំណត់ឲ្យបង្រៀនចំនួយ១៤មុខវិជ្ជានៅតាមអនុវិទ្យាល័យឡើយ។

**តារាងទី៩៖**

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ៣៧២នាក់ | ៣៧២នាក់ |
| ថ្នាក់ | ០៨ | ០៧ |
| ម៉ោង | ២៥៦ | ២២៤ |
| គ្រូ | ១៤ | ០៩ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ១១ | |

**ក្រាបទី៩៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

៩.វិទ្យាល័យហ៊ុនសែន រួតចំប៉ី



## ៤.១០ អនុវិទ្យាល័យ បុស្សូវ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

តាមលទ្ធផលស្រាវជ្រាវអនុវិទ្យាល័យ នៃខេត្តឧត្តរមានជ័យមានបង្ហាញឲ្យឃើញថា ស្ថិតិសិស្ស ដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ២០៧ នាក់ ស្មើនិង ០៦ ថ្នាក់។ តាមការរកឃើញថា មានចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន១៩២ម៉ោង និងមានគ្រូបង្រនកម្រិតបឋមភូមិ កំពុងបង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន០៩នាក់។

បើតាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ១៦០ម៉ោង( ០៥ថ្នាក់គុណនិង៣២ម៉ោង )ក្នុងអនុវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន ០៩នាក់( ១៦០ម៉ោងចែកនិង១៨ម៉ោង )។នេះបានបញ្ជាក់ឲ្យឃើញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់ សិស្ស និងគ្រូរបស់អនុវិទ្យាល័យគោរពមិនទាន់បានទៅតាមនិយាមកំណត់ដោយក្រសួង អប់រំយុវជន និងកីឡាឡើយទេ។ តាមការរកឃើញចំនួនមុខវិជ្ជាវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ០៩មុខវិជ្ជា ដោយមិនបានគោរពតាមនិយាមសាលា ដែលកំណត់ឲ្យបង្រៀនចំនួន១៤មុខវិជ្ជានៅតាមវិទ្យាល័យ។

**តារាងទី១០៖**

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ២០៧នាក់ | ២០៧នាក់ |
| ថ្នាក់ | ០៥ | ០៦ |
| ម៉ោង | ១៦០ | ១៩២ |
| គ្រូ | ០៩ | ០៩ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ១១ | |

**ក្រាបទី១០៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

១០.អនុវិទ្យាល័យ បុស្សូវ



## ៤.១១ អនុវិទ្យាល័យ បន្សាយរាក់ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

តាមលទ្ធផលស្រាវជ្រាវអនុវិទ្យាល័យ នៃខេត្តឧត្តរមានជ័យនេះបានបង្ហាញឲ្យឃើញថា ស្ថិតិសិស្ស ដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ១៥៦ នាក់ ស្មើនិង ០៣ ថ្នាក់។ តាមការរកឃើញថា មានចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន៩៦ម៉ោង និងមានគ្រូកម្រិតមធ្យមសិក្សាបឋមភូមិកំពុងបង្រៀន តាមមុខវិជ្ជានីមួយៗមានចំនួន០៨នាក់។

បើតាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្ដាហ៍ នាំឲ្យចំនួនម៉ោងសរុប ៩៦ម៉ោង( ០៣ថ្នាក់គុណនិង៣២ម៉ោង )ក្នុងវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន០៥ នាក់( ៩៦ម៉ោងចែកនិង១៨ម៉ោង )។នេះបញ្ជាក់ឲ្យឃើញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់ សិស្ស និងគ្រូនៃអនុវិទ្យាល័យនេះមិនទាន់គោរពបានទៅតាមនិយាមកំណត់ដោយក្រសួង អប់រំឡើយ ។ តាមការរកឃើញចំនួនមុខវិជ្ជាវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ១២មុខវិជ្ជា ដោយមិនបានគោរពតាមនិយាមរបស់ក្រសួង ដែលកំណត់ឲ្យបង្រៀនចំនួយ១៤មុខវិជ្ជានៅតាមវិទ្យាល័យ។

តារាងទី១១៖

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ១៥៦នាក់ | ១៥៦នាក់ |
| ថ្នាក់ | ០៣ | ០៣ |
| ម៉ោង | ៩៦ | ៩៦ |
| គ្រូ | ០៥ | ០៨ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៨ | |

### ក្រាបទី១១៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង

១១.អនុវិទ្យាល័យ បន្សាយរាក់



## .១២ អនុវិទ្យាល័យ គោកត្នុក ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

លទ្ធផលស្រាវជ្រាវអនុវិទ្យាល័យ នៃខេត្តឧត្តរមានជ័យមានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ២១៥ នាក់ ស្មើនិង ០៤ ថ្នាក់។ តាមការរកឃើញថាមានចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន១២៨ម៉ោង និងមានគ្រូកម្រិតបឋមភូមិកំពុងបង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន០៦នាក់។

គិតតាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ១៦០ម៉ោង( ០៥ថ្នាក់គុណនិង៣២ម៉ោង )នៅក្នុងអនុវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន០៩នាក់( ១៦០ម៉ោងចែកនិង១៨ម៉ោង )។បញ្ជាក់ឲ្យឃើញថាការប្រើប្រាស់និយាម ម៉ោង ថ្នាក់ សិស្ស និងគ្រូនៃអនុវិទ្យាល័យគោរពមិនទាន់បានត្រឹមត្រូវទៅតាមនិយាមនៅឡើយទេ។ តាមការរកឃើញចំនួនមុខវិជ្ជាដែលអនុវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ១៣មុខវិជ្ជា ដោយមិនទាន់បានគោរពតាមនិយាមរបស់ក្រសួង ដែលកំណត់ឲ្យបង្រៀនចំនួយ១៤មុខវិជ្ជានៅតាមអនុវិទ្យាល័យជាក់ស្តែងឡើយ។

តារាងទី១០៖

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ២១៥នាក់ | ២១៥នាក់ |
| ថ្នាក់ | ០៥ | ០៤ |
| ម៉ោង | ១៦០ | ១២៨ |
| គ្រូ | ០៩ | ០៦ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៧ | |

**ក្រាបទី១២៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**១២.អនុវិទ្យាល័យគោកត្នុក**



## ៤.១៣ អនុវិទ្យាល័យ សូរ៉ែកគុណពោធិវង្ស៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

តាមលទ្ធផលស្រាវជ្រាវអនុវិទ្យាល័យ នៃខេត្តឧត្តរមានជ័យនេះបានបង្ហាញឲ្យឃើញថា ស្ថិតិសិស្ស ដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ១៨៤ នាក់ ស្មើនិង ០៤ ថ្នាក់។ តាមការរកឃើញថាមាន ចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន១២៣ម៉ោង មានគ្រូបង្រៀនកម្រិតបឋមភូមិ កំពុងបង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន០៨នាក់។

តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ១២៣ម៉ោង( ០៤ថ្នាក់គុណនិង៣២ម៉ោង )នៅក្នុងអនុវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិ ចំនួន០៧នាក់( ១២៣ម៉ោងចែកនិង១៨ម៉ោង )។នេះបញ្ជាក់ឲ្យឃើញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់ សិស្ស និងគ្រូរបស់អនុវិទ្យាល័យគោរពបានល្អ ទៅតាមនិយាមកំណត់ដោយក្រសួង អប់រំយុវជន និងកីឡា។ តាមការរកឃើញចំនួនមុខវិជ្ជាអនុវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ១៣មុខវិជ្ជា ។

**តារាងទី១៣៖**

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ១៨៤នាក់ | ១៨៤នាក់ |
| ថ្នាក់ | ០៤ | ០៤ |
| ម៉ោង | ១២៣ | ១២៣ |
| គ្រូ | ០៧ | ០៨ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៨ | |

**ក្រាបទី១៣៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**១៣.វិទ្យាល័យសូរ៉ែកគុណពោធិវង្ស**



## ៤.១៤ វិទ្យាល័យ បន្ទាយអំពិល ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

តាមលទ្ធផលស្រាវជ្រាវវិទ្យាល័យ នៃខេត្តឧត្តរមានជ័យនេះមានបង្ហាញឲ្យឃើញថា ស្ថិតិសិស្ស ដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ៥៦៤ នាក់ ស្មើនិង ១២ ថ្នាក់។ តាមការរកឃើញថាមាន ចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន ៣៨៤ ម៉ោង មានគ្រូកម្រិតមធ្យមសិក្សាបឋម ភូមិ កំពុងបង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួនសរុប៤០នាក់។

តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ៤១៦ម៉ោង( ១៣ថ្នាក់គុណនិង៣២ម៉ោង )ក្នុងវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន២៣ នាក់( ៤១៦ម៉ោងចែកនិង១៨ ម៉ោង )។សូមបញ្ជាក់ថា ការប្រើប្រាស់ និយាម ម៉ោង  ថ្នាក់ សិស្ស និងគ្រូនៃ វិទ្យាល័យនេះមិនបានគោរពត្រឹមត្រូវតាម និយាមកំណត់ឡើយ។ ដោយជាក់ស្តែងប្រើប្រាស់គ្រូ ច្រើនខុស ពីនិយាម។តាមការរកឃើញចំនួនមុខវិជ្ជាវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមាន១៤មុខវិជ្ជា ដោយបាន គោរពតាមនិយាមរបស់ក្រសួង ដែលកំណត់ឲ្យបង្រៀនចំនួន១៤មុខវិជ្ជានៅតាមវិទ្យាល័យ។

**តារាងទី១៤៖**

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ៥៦៤នាក់ | ៥៦៤នាក់ |
| ថ្នាក់ | ១៣ | ១២ |
| ម៉ោង | ៤១៦ | ៣៨៤ |
| គ្រូ | ២៣ | ៤០ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ៤០ | |

**ក្រាបទី១៤៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**១៤.វិទ្យាល័យ បន្ទាយអំពិល**



## ៤.១៥ វិទ្យាល័យ អំពិល ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

តាមលទ្ធផលស្រាវជ្រាវវិទ្យាល័យ នៃខេត្តឧត្តរមានជ័យនេះបានបង្ហាញឲ្យឃើញថា ស្ថិតិសិស្ស ដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ៣៦១ នាក់ ស្មើនិង ០៧ ថ្នាក់។ តាមការរកឃើញថា មានចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន ២២៤ ម៉ោង មានគ្រូបង្រៀនកម្រិតបឋមភូមិ ចំនួន២១នាក់។

តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ២៥៦ម៉ោង( ០៨ថ្នាក់គុណនិង៣២ម៉ោង )ក្នុងវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន១៤ នាក់( ២៥៦ម៉ោងចែកនិង១៨ម៉ោង )។នេះបញ្ជាក់ឲ្យឃោះញថា ការប្រើប្រាស់និយាម ម៉ោង ថ្នាក់ សិស្ស និងគ្រូរបស់វិទ្យាល័យនេះ មិនគោរពទៅតាមនិយាមកំណត់ដោយក្រសួង អប់រំយុវជន និងកីឡា ឡើយ។ តាមការបញ្ជាក់រកឃើញចំនួនមុខវិជ្ជាវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ១៣មុខវិជ្ជា ។

តារាងទី១៥៖

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ៣៦១នាក់ | ៣៦១នាក់ |
| ថ្នាក់ | ០៨ | ០៧ |
| ម៉ោង | ២៥៦ | ២២៤ |
| គ្រូ | ១៤ | ២១ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ២៤ | |

**ក្រាបទី១៥៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**១៥.វិទ្យាល័យ អំពិល**



## ៤.១៦ អនុវិទ្យាល័យ ឈូក ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

តាមលទ្ធផលស្រាវជ្រាវអនុវិទ្យាល័យ នៃខេត្តឧត្តរមានជ័យមានបង្ហាញឲ្យឃើញថា ស្ថិតិសិស្ស ដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ២៥៤ នាក់ ស្មើនិង ០៦ ថ្នាក់។ តាមការរកឃើញថាមាន ចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន១៣២ម៉ោង និងមានគ្រូកម្រិតមធ្យមសិក្សាបឋម ភូមិកំពុងបង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន០៩នាក់។

តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ១៣២ម៉ោង( ០៦ថ្នាក់គុណនិង៣២ម៉ោង )ក្នុងអនុវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន ០៧នាក់( ១៣២ម៉ោងចែកនិង១៨ម៉ោង )។នេះបញ្ជាក់ឲ្យឃោះញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់ សិស្ស និងគ្រូរបស់អនុវិទ្យាល័យនេះមិនទាន់គោរពបានទៅតាមនិយាមកំណត់ដោយក្រសួង អប់រំយុវជន និងកីឡាឡើយ។ តាមការរកឃើញចំនួនមុខវិជ្ជាវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ១២មុខវិជ្ជា ។

តារាងទី១៦៖

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ២៥៤នាក់ | ២៥៤នាក់ |
| ថ្នាក់ | ០៦ | ០៦ |
| ម៉ោង | ១២៣ | ១២៣ |
| គ្រូ | ០៧ | ០៩ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៩ | |

### ក្រាបទី១៦៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង

១៦.អនុវិទ្យាល័យ ឈូក



## ៤.១៧ អនុវិទ្យាល័យ គោកខ្ពស់ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

តាមលទ្ធផលស្រាវជ្រាវអនុវិទ្យាល័យ នៃខេត្តឧត្តរមានជ័យនេះបានបង្ហាញឲ្យឃើញថា ស្ថិតិសិស្ស ដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ១៨២ នាក់ ស្មើនិង ០៤ ថ្នាក់។ តាមការរកឃើញថាមាន ចំនួនម៉ោងពិតប្រាកដដែលអនុវិទ្យាល័យកំពុងបង្រៀនចំនួន១២៨ម៉ោង មានគ្រូកម្រិតបឋមភូមិ កំពុង បង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន០៧នាក់។ យោងតាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប១២៨ ម៉ោង( ០៤ថ្នាក់គុណនិង៣២ម៉ោង )ក្នុងអនុវិទ្យាល័ យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន០៧នាក់( ១២៨ម៉ោងចែកនិង១៨ម៉ោង )។នេះបញ្ជាក់ឲ្យ ឃោះញថា ការប្រើប្រាស់ និយាមម៉ោង ថ្នាក់ សិស្ស និងគ្រូរបស់អនុវិទ្យាល័យគោរពបានទៅតាមនិយាម កំណត់ដោយក្រសួង អប់រំយុវជន និងកីឡា។ តាមការរកឃើញចំនួនមុខវិជ្ជាអនុវិទ្យាល័យកំពុងបង្រៀន ជាក់ស្តែងនេះមានតែ១២ មុខវិជ្ជា ។

តារាងទី១៧៖

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ១៨២នាក់ | ១៨២នាក់ |
| ថ្នាក់ | ០៤ | ០៤ |
| ម៉ោង | ១២៨ | ១២៨ |
| គ្រូ | ០៧ | ០៧ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៩ | |

**ក្រាបទី១៧៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**១៧.អនុវិទ្យាល័យ គោកខ្ពស់**



## ៤.១៨ អនុវិទ្យាល័យ បេង ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

លទ្ធផលស្រាវជ្រាវអនុវិទ្យាល័យ នៃខេត្តឧត្តរមានជ័យមានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ៧៩ នាក់ ស្មើនិង ០៣ ថ្នាក់។ តាមការរកឃើញថាមានចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន ៩៦ ម៉ោង មានគ្រូបង្រៀនកម្រិតបឋមភូមិកំពុងបង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន ០៦ នាក់។

បើតាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ៦២ ម៉ោង(០២ថ្នាក់គុណនិង៣២ម៉ោង)ក្នុងវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន០៤ នាក់(៦៤ម៉ោងចែកនិង១៨ ម៉ោង)។នេះបញ្ជាក់ថា ការប្រើប្រាស់និយាម ម៉ោង ថ្នាក់ សិស្ស និងគ្រូរបស់អនុវិទ្យាល័យនេះមមិនគោរពទៅតាមនិយាមកំណត់ ដោយប្រើប្រាស់គ្រូ និង ថ្នាក់លើសចំនួន ដើម្បីទទួលមានប្រាក់ឧបត្ថម្ភម៉ោងបបន្ថែម។។ តាមកាជាក់ស្តែងចំនួនមុខវិជ្ជាអនុវិទ្យាល័យនេះកំពុងបង្រៀនជាក់ស្តែងមានតែ ១១ មុខវិជ្ជា ដោយមានខ្វះមុខវិជ្ជាមួយចំនួនទៀតមិនទាន់បានបង្រៀន។

តារាងទី១៨៖

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ៧៩នាក់ | ៧៩នាក់ |
| ថ្នាក់ | ០២ | ០៣ |
| ម៉ោង | ៦៤ | ៩៦ |
| គ្រូ | ០៤ | ០៧ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៧ | |

**ក្រាបទី១៨៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**១៨.អនុវិទ្យាល័យ បេង**




## ៤.១៩ អនុវិទ្យាល័យ គោកឪឡោក ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

តាមលទ្ធផលស្រាវជ្រាវនៃអនុវិទ្យាល័យនៃខេត្តឧត្តរមានជ័យបានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ៨២ នាក់ ស្មើនិង ០៣ ថ្នាក់។ តាមការរកឃើញថាមានចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន ៩៦ម៉ោង និងមានគ្រូកំពុងបង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន០៦នាក់។យោងតាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍នាំឲ្យចំនួនម៉ោងសរុប៦៤ម៉ោង( ០២ថ្នាក់គុណនិង៣២ម៉ោង )ដែលមានក្នុងអនុវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន០៤នាក់(៦៤ម៉ោងចែកនិង១៨ម៉ោង )។នេះបញ្ជាក់ឲ្យឃោះញថា ការប្រើប្រាស់និយាម ម៉ោង ថ្នាក់ សិស្ស និងគ្រូនៅអនុវិទ្យាល័យនេះមិនបានគោរពទៅតាមនិយាមកំណត់ដោយឡើយ។ ដោយរកឃើញថាចំនួនមុខវិជ្ជានៅអនុវិទ្យាល័យដែលកំពុងបង្រៀនជាក់ស្តែងមាន១៤មុខវិជ្ជាដោយបានគោរពតាមនិយាមរបស់ក្រសួង តែនៅមានខ្វះមួយមុខវិជ្ជាទៀតគឺមុខវិជ្ជា កុំព្យូទ័រ ដែលខ្វះគ្រូឯកទេស និងខ្វះសម្ភារបង្រៀន។

តារាងទី១៩៖

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ៨២នាក់ | ៨២នាក់ |
| ថ្នាក់ | ០២ | ០៣ |
| ម៉ោង | ៦៤ | ៩៦ |
| គ្រូ | ០៤ | ០៦ |

| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៧ | |
|---|---|---|

ក្រាបទី១៩៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង

១៩.អនុវិទ្យាល័យ គោកឪឡោក




## ៤.២០ អនុវិទ្យាល័យ ប្រាសាទចី ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

លទ្ធផលស្រាវជ្រាវ ក្នុងខេត្តឧត្តរមានជ័យ នៅក្នុងអនុវិទ្យាល័យខាងលើបានបង្ហាញថា ស្ថិតិសិស្ស ដែលបានស្រង់មកពីថ្នាក់ទី ៧ ៨ ៩ មានចំនួនសិស្ស ៩០ នាក់ ។ តាមនិយាមសិស្សក្នុងមួយថ្នាក់៤៥ នាក់ ដែលបានកំណត់ដោយច្បាប់នោះចំនួនថ្នាក់នៅអនុវិទ្យាល័យខាងលើ មាន២ថ្នាក់( ៩០ចែកនិង ៤៥ )។ បើតាមនិយាមសិស្សមួយថ្នាក់ត្រូវរៀន ៣២ម៉ោងក្នុងមួយសប្តាហ៍ និងនាំឲ្យចំនួនម៉ោងសរុបគឺ ៦៤ម៉ោង( ២ថ្នាក់គុណនិង៣២ ) ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតបឋមភូមិចំនួន ០៤នាក់( ៦៤ម៉ោង ចែកនឹង១៨ ម៉ោង ) សម្រាប់មុខវិជ្ជាឯកទេសទាំងអស់( និយាមគ្រូបង្រៀននៅអនុវិទ្យាល័យគឺ១៨ម៉ោង ក្នុងមួយសប្តាហ៍ )។ ក៏ប៉ុន្តែតាមទិន្នន័យជាក់ស្តែងដែលទទួលបានពីអនុវិទ្យាល័យខាងលើមានចំនួនថ្នាក់ សរុប០៣ថ្នាក់។ ចំពោះគ្រូដែលមានគុណវុឌ្ឍិគឺមានតែ០៤នាក់ប៉ុណ្ណោះដែលកំពុងបង្រៀននៅអនុវិទ្យាល័ យខាងលើនេះ។ បើតាមនិយាមជាក់ស្តែងត្រូវការគ្រូបង្រៀនតែកម្រិតបឋមភូមិត្រឹមតែ៤នាក់ប៉ុណ្ណោះ។

តារាងទី២០៖

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ៧៩នាក់ | ៧៩នាក់ |
| ថ្នាក់ | ០២ | ០៣ |
| ម៉ោង | ៦៤ | ៩៦ |

| | | |
|---|---|---|
| គ្រូ | ០៤ | ០៤ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៤ | |

**ក្រាបទី២០ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**២០.អនុវិទ្យាល័យ ប្រាសាទបី**




## ៤.២១ វិទ្យាល័យ អន្លង់វែង ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

តាមលទ្ធផលស្រាវជ្រាវវិទ្យាល័យ នៃខេត្តឧត្តរមានជ័យបានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ៩៤២ នាក់ ស្មើនិង ១៨ ថ្នាក់។ តាមការរកឃើញថាមានចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន៥៧៦ម៉ោង និងមានគ្រូកម្រិតមធ្យមសិក្សាបឋមភូមិកំពុងបង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន៥៣នាក់។

តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប៧០៤ម៉ោង( ២២ថ្នាក់គុណនិង៣២ម៉ោង )ក្នុងវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន៣៧នាក់( ៧០៤ម៉ោងចែកនិង១៩ម៉ោង )។នេះបញ្ជាក់ឲ្យឃើញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់ សិស្ស និងគ្រូរបស់វិទ្យាល័យគោរពមិនទាន់បានទៅតាមនិយាមកំណត់ដោយក្រសួង អប់រំយុវជន និងកីឡាឡើយ។ តាមការរកឃើញចំនួនមុខវិជ្ជាវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ១៣មុខវិជ្ជា ដោយមិនបានគោរពតាមនិយាមរបស់ក្រសួង ដែលកំណត់ឲ្យបង្រៀនចំនួយ១៤មុខវិជ្ជានៅតាមវិទ្យាល័យ។

តារាងទី២១៖

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ៩៤២នាក់ | ៩៤២នាក់ |

| | | |
|---|---|---|
| ថ្នាក់ | ២២ | ១៨ |
| ម៉ោង | ៧០៤ | ៥៧៦ |
| គ្រូ | ៣៧ | ៥៣ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ៥៣ | |

**ក្រាបទី២១ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**២១.អនុវិទ្យាល័យ អន្លង់វែង**




## ៤.២២ វិទ្យាល័យ តេជោហ៊ុនសែន ត្រពាំងតាវ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

តាមលទ្ធផលស្រាវជ្រាវវិទ្យាល័យ នៃខេត្តឧត្តរមានជ័យនេះបានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ៣៣៨ នាក់ ស្មើនិង ០៧ ថ្នាក់។ តាមការរកឃើញថាមានចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន២២៤ម៉ោង ហើយមានគ្រូបង្រៀនកម្រិតបឋមភូមិចំនួន១៧នាក់។

បើតាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ២៥៦ម៉ោង( ០៨ថ្នាក់គុណនិង៣២ម៉ោង )ក្នុងវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន១៤នាក់( ២៥៦ម៉ោងចែកនិង១៨ម៉ោង )។នេះបញ្ជាក់ឲ្យឃោះញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់ សិស្ស និងគ្រូរបស់វិទ្យាល័យគោរពមិនទាន់បានទៅតាមនិយាមកំណត់ដោយក្រសួង អប់រំយុវជន និង

កីឡាឡើយ។ តាមការរកឃើញចំនួនមុខវិជ្ជាវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ១១មុខវិជ្ជា ដោយមិនបានគោរពតាមនិយាមរបស់ក្រសួង ដែលកំណត់ឲ្យបង្រៀនចំនួយ១៤មុខវិជ្ជានៅតាមវិទ្យាល័យ។

តារាងទី២២៖

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ៣៣៨នាក់ | ៣៣៨នាក់ |
| ថ្នាក់ | ០៨ | ០៧ |
| ម៉ោង | ២៥៦ | ២២៤ |
| គ្រូ | ១៤ | ១៧ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ១៧ | |

**ក្រាបទី២២ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង ២២.វិទ្យាល័យ តេជោហ៊ុនសែន ត្រពាំងតាវ**




## ៤.២៣ អនុវិទ្យាល័យ ហ៊ុនសែន ត្រពាំងប្រីយ៍ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

តាមលទ្ធផលស្រាវជ្រាវវិទ្យាល័យ នៃខេត្តឧត្តរមានជ័យបានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ៤១៧ នាក់ ស្មើនិង ០៨ ថ្នាក់។ តាមការរកឃើញថាមានចំនួនម៉ោងពិតប្រាកដដែលអនុវិទ្យាល័យកំពុងបង្រៀនចំនួន ២៥៦ម៉ោង មានគ្រូកម្រិតមធ្យមសិក្សាបឋមភូមិកំពុងបង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន១២នាក់។

យោងតាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ៣២០ម៉ោង( ១០ថ្នាក់គុណនិង៣២ម៉ោង )នៅក្នុងសាលានេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន១៨ នាក់( ៣២០ម៉ោងចែកនិង១៨ថ្នាក់ )។នេះបង្ហាញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់សិស្ស និងគ្រូរបស់ អនុវិទ្យាល័យនេះមិនទាន់បានគោរពទៅតាមនិយាមកំណត់ដោយក្រសួង អប់រំយុវជន និងកីឡាឡើយ។ តាមការរកឃើញចំនួនមុខវិជ្ជាអនុវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ១២មុខវិជ្ជា ។

តារាងទី២៣៖

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ៤១៧នាក់ | ៤១៧នាក់ |
| ថ្នាក់ | ១០ | ០៨ |
| ម៉ោង | ៣២០ | ២៥៦ |
| គ្រូ | ១៨ | ១២ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ១២ | |

**ក្រាបទី២៣ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**២៣.អនុវិទ្យាល័យ ហ៊ុនសែន ត្រពាំងប្រីយ៍**




## ៤.២៤ អនុវិទ្យាល័យ លំទង ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

តាមលទ្ធផលស្រាវជ្រាវអនុវិទ្យាល័យ នៃខេត្តឧត្តរមានជ័យបានបង្ហាញឲ្យឃើញថា ស្ថិតិសិស្ស ដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ១៥៣ នាក់ ស្មើនិង ០៤ ថ្នាក់។ តាមការរកឃើញថា មានចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន១២៨ម៉ោង មានគ្រូបង្រៀនកម្រិតអនុវិទ្យា ល័យកំពុងបង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន០៨នាក់។

បើយោងតាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ៩៦ម៉ោង( ០៣ថ្នាក់គុណនិង៣២ម៉ោង )ក្នុងអនុវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន ០៥នាក់( ៩៦ម៉ោងចែកនិង១៨ថ្នាក់ )។នេះបានបញ្ជាក់ថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់សិស្ស និងគ្រូរបស់អនុវិទ្យាល័យនេះមិនទាន់បានគោរពទៅតាមនិយាមកំណត់ដោយក្រសួង អប់រំយុវជន និងកីឡាឡើយ។ តាមការរកឃើញចំនួនមុខវិជ្ជាវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានរហូតដល់១៤មុខវិជ្ជា ។

តារាងទី២៤៖

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ១៥៣នាក់ | ១៥៣នាក់ |
| ថ្នាក់ | ០៣ | ០៨ |
| ម៉ោង | ៩៦ | ១២៨ |
| គ្រូ | ០៥ | ០៨ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៩ | |

**ក្រាបទី២៤ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**២៤.អនុវិទ្យាល័យ លំទង**




## ៤.២៥ អនុវិទ្យាល័យថ្លាត ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

ការស្រាវជ្រាវអនុវិទ្យាល័យ នៃខេត្តឧត្តរមានជ័យមានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ១២៥ នាក់ ស្មើនិង ០៣ ថ្នាក់។ តាមការរកឃើញថាមានចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន៩៦ម៉ោង និងមានគ្រូកម្រិតអនុវិទ្យាល័យកំពុងបង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន០៦នាក់។

បើយោងតាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ៩៦ម៉ោង(០៣ថ្នាក់គុណនិង៣២ម៉ោង)ក្នុងអនុវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន ០៥នាក់(៩៦ម៉ោងចែកនិង១៨ថ្នាក់)។នេះបញ្ជាក់ឲ្យឃោះញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់ សិស្ស និងគ្រូរបស់អនុវិទ្យាល័យគឺបានគោរព ទៅតាមនិយាមកំណត់ដោយក្រសួង អប់រំយុវជន និង កីឡា។ តាមការរកឃើញចំនួនមុខវិជ្ជាវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ១៤មុខវិជ្ជា ។តែមុខវិជ្ជា ICT មិនទាន់បានអនុវត្តន៍នៅឡើយទេដោយខ្វះគ្រូឯកទេស និងបន្ទប់ សម្ភារៈ។

តារាងទី២៥៖

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ១២៥នាក់ | ១២៥នាក់ |
| ថ្នាក់ | ០៣ | ០៣ |
| ម៉ោង | ៩៦ | ៩៦ |
| គ្រូ | ០៥ | ០៦ |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៦ | |

**ក្រាបទី២៥ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**២៥.អនុវិទ្យាល័យ ថ្លាត**




## ៤.២៦ អនុវិទ្យាល័យ រំចេក ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

លទ្ធផលនៃការស្រាវជ្រាវក្នុងខេត្តឧត្តរមានជ័យក្នុងខេត្តខាងលើបានបង្ហាញឲ្យឃើញថា ស្ថិតិ សិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ២៣៩ នាក់ ។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវ មានចំនួនសិស្ស ៤៥ ដែលកំណត់ដោយច្បាប់ និងមានចំនួនថ្នាក់នៅវិទ្យាល័យខាងលើ មាន០៥ថ្នាក់ (២៣៩ ចែកនិង ៤៥) បើគិតទៅតាមនិយាមសិស្សក្នុងមួយថ្នាក់៣២ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួន

ម៉ោងសរុបគឺ១៦០ម៉ោង( ០៥ថ្នាក់គុណនឹង៣២ម៉ោង ) ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតបឋមភូមិចំនួន៩នាក់( ១៦០ម៉ោងចែកនឹង១៨ម៉ោង )សម្រាប់គ្រប់មុខវិជ្ជាទាំងអស់( និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្ដាហ៍ )។ជាការជាក់ស្ដែងទិន្នន័យដែលទទួលបានពីអនុវិទ្យាល័យខាងលើមានចំនួនថ្នាក់សរុប០៤ថ្នាក់។ សម្រាប់គ្រូបង្រៀនដែលមានគុណវុឌ្ឍិ( កម្រិតមធ្យមសិក្សាបឋមភូមិ )មានតែ ០៦នាក់តែប៉ុណ្ណោះដែលកំពុងបង្រៀននៅអនុវិទ្យាល័យនេះ។ តាមនិយាមជាក់ស្ដែងត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន០៣នាក់( ០៩នាក់ដក០៦ ) មានន័យថាខ្វះគ្រូបង្រៀនចំនួន០៣នាក់។

តារាងទី២៦៖

| ចំនួន | តាមនិយាម | ជាក់ស្ដែង | លើស | ខ្វះ |
|---|---|---|---|---|
| សិស្ស | ២៣៩នាក់ | ២៣៩នាក់ | | |
| ថ្នាក់ | ០៥ | ០៤ | | |
| ម៉ោង | ១៦០ | ១២៨ | | |
| គ្រូ | ០៩ | ០៦ | | |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៦ | ០៩ | ០០ | ០៣ |

**ក្រាបទី២៦ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្ដែង**

**២៦.អនុវិទ្យាល័យ រំចេក**




## ៤.២៧ អនុវិទ្យាល័យសម្ដេចតេជោ អូរស្រមរ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

តាមលទ្ធផលស្រាវជ្រាវ នៃខេត្តឧត្ដរមានជ័យ នៃអនុវិទ្យាល័យនេះបានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ៧២ នាក់ ស្មើនិង ០៣ ថ្នាក់។ តាមការរកឃើញថាមានចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន ៩៦ម៉ោង និងមានគ្រូបង្រៀនកម្រិតបឋមភូមិកំពុងបង្រៀនតាមមុខវិជ្ជាជាក់ស្ដែងមានចំនួន០៤នាក់។

គិតតាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្ដាហ៍ នាំឲ្យចំនួនម៉ោងសរុបគឺ ៦៤ ម៉ោង(០២ថ្នាក់គុណនិង៣២ម៉ោង)និង ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន០៤នាក់(៦៤ម៉ោងចែកនិង១៨ម៉ោង)។នេះបានបង្ហាញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់ សិស្ស និងគ្រូរបស់អនុវិទ្យាល័យនេះមិនទាន់បានគោរពទៅតាមនិយាមកំណត់ដោយក្រសួង អប់រំយុវជន និងកីឡាឡើយ។ សម្រាប់គ្រូបង្រៀនដែលមានគុណវុឌ្ឍិ(កម្រិតមធ្យមសិក្សាបឋមភូមិ)មានតែ០៥នាក់តែប៉ុណ្ណោះដែលកំពុងបង្រៀននៅអនុវិទ្យាល័យនេះ។ តាមនិយាមជាក់ស្ដែងត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន០១នាក់(០៥នាក់ដក០៤) មានន័យថាលើសគ្រូបង្រៀនចំនួន០១នាក់។

តារាងទី២៧៖

| ចំនួន | តាមនិយាម | ជាក់ស្ដែង | លើស | ខ្វះ |
|---|---|---|---|---|
| សិស្ស | ៧២នាក់ | ៧២នាក់ | | |
| ថ្នាក់ | ០២ | ០៣ | | |
| ម៉ោង | ៦៤ | ៩៦ | | |
| គ្រូ | ០៤ | ០៥ | | |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៤ | ០៥ | ០១ | ០០ |

**ក្រាបទី២៧ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្ដែង**

**២៧.អនុវិទ្យាល័យសម្ដេចតេជោ អូស្រមរ**




## ៤.២៨ អនុវិទ្យាល័យ ហ៊ុនសែនទួលតាសេក ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

លទ្ធផលនៃការស្រាវជ្រាវក្នុងខេត្តឧត្តរមានជ័យក្នុងអនុវិទ្យាល័យខាងលើបានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ៧០២ នាក់ ។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវមានចំនួនសិស្ស ៤៥ ដែលកំណត់ដោយច្បាប់ និងមានចំនួនថ្នាក់នៅវិទ្យាល័យខាងលើ មាន១៦ថ្នាក់(៧០២ ចែកនិង ៤៥) បើគិតទៅតាមនិយាមសិស្សក្នុងមួយថ្នាក់៣២ម៉ោងក្នុងមួយសប្ដាហ៍ នាំឲ្យចំនួន

ម៉ោងសរុបគឺ៥១២ម៉ោង( ១៦ថ្នាក់គុណនឹង៣២ម៉ោង ) ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតបឋមភូមិចំនួន២៨នាក់( ៥១២ម៉ោងចែកនឹង១៨ម៉ោង )សម្រាប់គ្រប់មុខវិជ្ជាទាំងអស់( និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្តាហ៍ )។ជាការជាក់ស្តែងទិន្នន័យដែលទទួលបានពីអនុវិទ្យាល័យខាងលើមានចំនួនថ្នាក់សរុប១២ថ្នាក់។ សម្រាប់គ្រូបង្រៀនដែលមានគុណវុឌ្ឍិ( កម្រិតមធ្យមសិក្សាបឋមភូមិ )មានតែ១៧នាក់តែប៉ុណ្ណោះដែលកំពុងបង្រៀននៅអនុវិទ្យាល័យនេះ។ តាមនិយាមជាក់ស្តែងត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន១១នាក់( ២៨នាក់ដក១៧ ) មានន័យថាខ្វះគ្រូបង្រៀនចំនួន១១នាក់។

តារាងទី២៨៖

| ចំនួន | តាមនិយាម | ជាក់ស្តែង | លើស | ខ្វះ |
|---|---|---|---|---|
| សិស្ស | ៧០២នាក់ | ៧០២នាក់ | | |
| ថ្នាក់ | ១៦ | ១២ | | |
| ម៉ោង | ៥១២ | ៣៨៤ | | |
| គ្រូ | ២៨ | ១៧ | | |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ២៨ | ១៧ | ០០ | ១១ |

**ក្រាបទី២៨ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

២៨.អនុវិទ្យាល័យ ហ៊ុនសែនទួលតាសេក




## ៤.២៩ អនុវិទ្យាល័យ ទំនប់ដាច់ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

បើតាមលទ្ធផលស្រាវជ្រាវ នៃខេត្តឧត្តរមានជ័យនៅអនុវិទ្យាល័យខាងលើបានបង្ហាញឲ្យឃើញថាស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ៥៦ នាក់ ស្មើនិង ០៣ ថ្នាក់។ តាមការរក

ឃើញថាមានចំនួនម៉ោងពិតប្រាកដដែលសាលាខាងលើនេះកំពុងបង្រៀនចំនួន៩៦ម៉ោង និងមានគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិកំពុងបង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន០៦នាក់។

តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុបគឺ ៦៤ម៉ោង( ០២ថ្នាក់គុណនិង៣២ម៉ោង )មានក្នុងអនុវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិ ចំនួន០៤នាក់( ៦៤ម៉ោងចែកនិង១៨ម៉ោង )។នេះបង្ហាញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់សិស្ស និង គ្រូរបស់វិអនុឡាល័យនេះមិនទាន់បានគោរពទៅតាមនិយាមកំណត់ដោយក្រសួង អប់រំយុវជន និងកីឡា ឡើយ។តាមការរកឃើញចំនួនមុខវិជ្ជាក្នុងសាលារៀននេះកំពុងបង្រៀនជាក់ស្តែងមានតែ១៣មុខវិជ្ជា។

តារាងទី២៩៖

| ចំនួន | តាមនិយាម | ជាក់ស្តែង | លើស | ខ្វះ |
|---|---|---|---|---|
| សិស្ស | ៥៦នាក់ | ៥៦នាក់ | | |
| ថ្នាក់ | ០២ | ០៣ | | |
| ម៉ោង | ៦៤ | ៩៦ | | |
| គ្រូ | ០៤ | ០៥ | | |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៥ | ០៦ | ០១ | ០០ |

**ក្រាបទី២៩ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**២៩.អនុវិទ្យាល័យ ទំនប់ដាច់**




## ៤.៣០ អនុវិទ្យាល័យ ហ៊ុនសែនអូរគ្រូច ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

លទ្ធផលនៃការស្រាវជ្រាវនៃខេត្តឧត្តរមានជ័យក្នុងខេត្តក្នុងសាលាលើបានបង្ហាញឲ្យឃើញថា ស្ថិតិ សិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ៣២២ នាក់ ។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវ

មានចំនួនសិស្ស ៤៥ ដែលកំណត់ដោយច្បាប់ និងមានចំនួនថ្នាក់នៅអនុវិទ្យាល័យខាងលើ មាន០៧ថ្នាក់(៣២២ ចែកនិង ៤៥) បើគិតទៅតាមនិយាមសិស្សក្នុងមួយថ្នាក់៣២ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុបគឺ២២៤ម៉ោង(០៧ថ្នាក់គុណនឹង៣២ម៉ោង) ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតបឋមភូមិចំនួន១២នាក់(២២៤ម៉ោងចែកនឹង១៨ម៉ោង)សម្រាប់គ្រប់មុខវិជ្ជាទាំងអស់(និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្តាហ៍)។ជាការជាក់ស្តែងទិន្នន័យដែលទទួលបានពីអនុវិទ្យាល័យខាងលើមានចំនួនថ្នាក់សរុប០៦ថ្នាក់។ សម្រាប់គ្រូបង្រៀនដែលមានគុណវុឌ្ឍិ(កម្រិតមធ្យមសិក្សាបឋមភូមិ)មានតែ០៨នាក់តែប៉ុណ្ណោះដែលកំពុងបង្រៀននៅអនុវិទ្យាល័យនេះ។ តាមនិយាមជាក់ស្តែងត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន០៤នាក់(១២នាក់ដក០៨) មានន័យថាខ្វះគ្រូបង្រៀនចំនួន០៤នាក់។

តារាងទី៣០៖

| ចំនួន | តាមនិយាម | ជាក់ស្តែង | លើស | ខ្វះ |
|---|---|---|---|---|
| សិស្ស | ៣២២នាក់ | ៣២២នាក់ | | |
| ថ្នាក់ | ០៧ | ០៦ | | |
| ម៉ោង | ២២៤ | ១៩២ | | |
| គ្រូ | ១២ | ០៨ | | |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ១២ | ០៨ | ០០ | ០៤ |

**ក្រាបទី៣០ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**៣០.អនុវិទ្យាល័យ ហ៊ុនសែនអូក្រូច**




## ៤.៣១ អនុវិទ្យាល័យ អូរស្វាយ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

តាមលទ្ធផលស្រាវជ្រាវនៃអនុវិទ្យាល័យនេះ នៃខេត្តឧត្តរមានជ័យបានបង្ហាញថា ស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ១៥៤ នាក់ ស្មើនិង ០៣ ថ្នាក់។ តាមការរកឃើញថាមាន

ចំនួនម៉ោងពិតប្រាកដដែលវិទ្យាល័យកំពុងបង្រៀនចំនួន ៩៦ ម៉ោង និងមានគ្រូបង្រៀនកម្រិតអនុវិទ្យាល័យកំពុងបង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន០៦នាក់។តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប៩៦ម៉ោង( ០៣ថ្នាក់គុណនិង៣២ម៉ោង )ក្នុងអនុវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន០៥នាក់( ៩៦ម៉ោងចែកនិង១៨ម៉ោង )។នេះបញ្ជាក់ឲ្យឃើញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់ សិស្ស របស់អនុវិទ្យាល័យបានគោរពទៅតាមនិយាមកំណត់ដោយក្រសួង អប់រំយុវជន និងកីឡា។ចំនែកនិយាមគ្រូគឺការប្រើប្រាស់មិនបានត្រឹមត្រូវទៅតាមនិយាមទេ ដោយប្រើប្រាស់គ្រូកម្រិតបឋមសិក្សាមកបង្រៀន។ តាមការរកឃើញចំនួនមុខវិជ្ជានៅអនុវិទ្យាល័យនេះ កំពុងបង្រៀនជាក់ស្តែងមានតែ១១មុខវិជ្ជា ដោយមិនបានគោរពតាមនិយាមរបស់ក្រសួងអប់រំ យុវជននិងកីឡាឡើយ។

តារាងទី៣១៖

| ចំនួន | តាមនិយាម | ជាក់ស្តែង | លើស | ខ្វះ |
|---|---|---|---|---|
| សិស្ស | ១៥៤នាក់ | ១៥៤នាក់ | | |
| ថ្នាក់ | ០៣ | ០៣ | | |
| ម៉ោង | ៩៦ | ៩៦ | | |
| គ្រូ | ០៥ | ០៦ | | |
| គ្រូដែលមានគុណវុឌ្ឍិបឋមភូមិ | ០៦ | ០៨ | ០២ | ០០ |

**ក្រាបទី៣១ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**៣១.អនុវិទ្យាល័យ អូរស្វាយ**




## ៤.៣២ អនុវិទ្យាល័យ ផ្កាច ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

បើតាមលទ្ធផលស្រាវជ្រាវក្នុងអនុវិទ្យាល័យ នៃខេត្តឧត្តរមានជ័យនេះបានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ២១៥ នាក់ ស្មើនិង ០៤ ថ្នាក់។ តាមការរក

ឃើញថាមានចំនួនម៉ោងពិតប្រាកដដែលសាលានេះកំពុងបង្រៀនចំនួន១២៨ម៉ោង និងមានគ្រូកម្រិតអនុវិទ្យាល័យដែលបានកំពុងបង្រៀនតាមមុខវិជ្ជាជាក់ស្តែងមានចំនួន០៤នាក់។

បើគិតទៅតាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន ៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុបគឺ ១៦០ម៉ោង(០៥ថ្នាក់គុណនិង៣២ម៉ោង)ហើយក្នុងអនុវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន ០៩នាក់(១៦០ម៉ោងចែកនិង១៨ម៉ោង)។នេះសបញ្ជាក់ថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់សិស្ស និងគ្រូរបស់សាលាខាងលើនេះមិន ទាន់បានអនុវត្តន៍តាមនិយាមកំណត់ដោយក្រសួង អប់រំយុវជន និងកីឡានៅឡើយនោះទេ។ តាមការរកឃើញចំនួនមុខវិជ្ជាក្នុងអនុវិទ្យាល័យនេះកំពុងបង្រៀនជាក់ស្តែងមានតែ១១មុខវិជ្ជា។

តារាងទី៣២៖

| ចំនួន | តាមនិយាម | ជាក់ស្តែង | លើស | ខ្វះ |
|---|---|---|---|---|
| សិស្ស | ២១៥នាក់ | ២១៥នាក់ | | |
| ថ្នាក់ | ០៥ | ០៤ | | |
| ម៉ោង | ១៦០ | ១២៨ | | |
| គ្រូ | ០៩ | ០៥ | | |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៩ | ០៥ | ០០ | ០៤ |

**ក្រាបទី៣២ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**៣២.អនុវិទ្យាល័យ ផ្កាវ**




## ៤.៣៣ អនុវិទ្យាល័យ ព្រះប្រឡាយ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

លទ្ធផលនៃការស្រាវជ្រាវនៃខេត្តឧត្តរមានជ័យក្នុងខេត្តក្នុងសាលាលើបានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ២១៤ នាក់ ។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវ

មានចំនួនសិស្ស ៤៥ ដែលកំណត់ដោយច្បាប់ និងមានចំនួនថ្នាក់នៅអនុវិទ្យាល័យខាងលើ មាន០៥ថ្នាក់ (២១៤ ចែកនិង ៤៥) បើគិតទៅតាមនិយាមសិស្សក្នុងមួយថ្នាក់៣២ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុបគឺ ១៦០ ម៉ោង (០៥ថ្នាក់គុណនឹង៣២ម៉ោង) ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតបឋមភូមិ ចំនួន ០៩ នាក់(១៦០ ម៉ោងចែកនឹង១៨ម៉ោង) សម្រាប់គ្រប់មុខវិជ្ជាទាំងអស់(និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្តាហ៍)។ជាការជាក់ស្តែងទិន្នន័យដែលទទួលបានពីអនុវិទ្យាល័យខាងលើមានចំនួនថ្នាក់សរុប ០៤ថ្នាក់។ សម្រាប់គ្រូបង្រៀនដែលមានគុណវុឌ្ឍិ(កម្រិតមធ្យមសិក្សាបឋមភូមិ) មានតែ០៥នាក់តែប៉ុណ្ណោះដែលកំពុងបង្រៀននៅអនុវិទ្យាល័យនេះ។ តាមនិយាមជាក់ស្តែងត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន០៤នាក់(០៩នាក់ដក០៥) មានន័យថាខ្វះគ្រូបង្រៀនកម្រិតបឋមភូមិ(គ្រូអនុវិទ្យាល័យ)ចំនួន០៤នាក់។

តារាងទី១០៖

| ចំនួន | តាមនិយាម | ជាក់ស្តែង | លើស | ខ្វះ |
|---|---|---|---|---|
| សិស្ស | ២១៤នាក់ | ២១៤នាក់ | | |
| ថ្នាក់ | ០៥ | ០៤ | | |
| ម៉ោង | ១៦០ | ១២៨ | | |
| គ្រូ | ០៩ | ០៥ | | |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៩ | ០៥ | ០០ | ០៤ |

**ក្រាបទី៣៣ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**៣៣.អនុវិទ្យាល័យ ព្រះប្រឡាយ**




## ៤.៣៤ អនុវិទ្យាល័យ ជ័យនិវត្តន៍ ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

យោងលទ្ធផលនៃការស្រាវជ្រាវ នៃខេត្តឧត្តរមានជ័យនៅអនុវិទ្យាល័យខាងលើបានបង្ហាញឲ្យឃើញថា ចំនួនស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ២៣១នាក់ ស្មើនិង ០៤ថ្នាក់។

តាមការរកឃើញថាមានចំនួនម៉ោងពិតប្រាកដដែលអនុវិទ្យាល័យនេះកំពុងបង្រៀនចំនួន ១២៨ម៉ោង និងមានគ្រូបង្រៀនកម្រិតបឋមភូមិដែលកំពុងបង្រៀនតាមមុខវិជ្ជានីមួយៗសរុបគឺមានចំនួន០៥នាក់។ បើគិតតាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ១៦០ម៉ោង( ០៥ថ្នាក់គុណនិង៣២ម៉ោង )ក្នុងវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនដែលមានគុណវុឌ្ឍិកម្រិតបឋមភូមិចំនួន០៩នាក់( ១៦០ម៉ោងចែកនិង១៨ម៉ោង )។នេះបញ្ជាក់ឲ្យឃើញថា ការប្រើប្រាស់ម៉ោង និយាម ថ្នាក់សិស្ស និងគ្រូរបស់អនុវិទ្យាល័យខាងលើនេះមិនទាន់បានគោរពទៅតាមនិយាមកំណត់ដោយក្រសួង អប់រំយុវជន និងកីឡាឡើយ។ តាមការរកឃើញចំនួនមុខវិជ្ជានៃអនុវិទ្យាល័យកំពុងបង្រៀនជាក់ស្តែងមានតែ១១មុខវិជ្ជាតែប៉ុណ្ណោះ។

តារាងទី៣៤៖

| ចំនួន | តាមនិយាម | ជាក់ស្តែង | លើស | ខ្វះ |
|---|---|---|---|---|
| សិស្ស | ២៣១នាក់ | ២៣១នាក់ | | |
| ថ្នាក់ | ០៥ | ០៤ | | |
| ម៉ោង | ១៦០ | ១២៨ | | |
| គ្រូ | ០៩ | ០៥ | | |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៩ | ០៦ | ០០ | ០៣ |

**ក្រាបទី៣៤ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**៣៤.អនុវិទ្យាល័យ ជ័យនិវត្តន៍**




## ៤.៣៥ អនុវិទ្យាល័យ បាក់អន្លូង ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

តាមលទ្ធផលស្រាវជ្រាវអនុវិទ្យាល័យ នៃខេត្តឧត្តរមានជ័យនេះបានបង្ហាញថា ស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ ដែលមានសិស្សចំនួន ១១៣ នាក់ ស្មើនិង ០៣ ថ្នាក់។ តាមការបញ្ជាក់ថាមាន

ចំនួនម៉ោងពិតប្រាកដដែលអនុវិទ្យាល័យខាងលើនេះកំពុងបង្រៀនចំនួន ៩៦ម៉ោង និងមានគ្រូកម្រិតបឋមភូមិកំពុងបង្រៀនតាមមុខវិជ្ជានីមួយៗមានចំនួន០៦នាក់ ដែល និងកំពុងបង្រៀននៅក្នុងអនុវិទ្យាល័យនេះ ។យោងតាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុប ៩៦ ម៉ោង( ០៣ថ្នាក់គុណនិង៣២ម៉ោង )ក្នុងអនុវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន០៥នាក់( ៩៦ ម៉ោងចែកនិង១៨ម៉ោង )។នេះបញ្ជាក់ឲ្យឃើញថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់ សិស្ស និងគ្រូរបស់អនុវិទ្យាល័យគោរពបានទៅតាមនិយាមកំណត់ដោយក្រសួង អប់រំយុវជន និងកីឡា។ តាមការរកឃើញចំនួនមុខវិជ្ជាដែលអនុវិទ្យាល័យនេះកំពុងបង្រៀនជាក់ស្តែងមានតែ១២មុខវិជ្ជា។

តារាងទី៣៥៖

| ចំនួន | តាមនិយាម | ជាក់ស្តែង | លើស | ខ្វះ |
|---|---|---|---|---|
| សិស្ស | ១១៣នាក់ | ១១៣នាក់ | | |
| ថ្នាក់ | ០៣ | ០៣ | | |
| ម៉ោង | ៩៦ | ៩៦ | | |
| គ្រូ | ០៥ | ០៦ | | |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៥ | ០៦ | ០១ | ០០ |

**ក្រាបទី៣៥ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**៣៥.អនុវិទ្យាល័យ បាក់អន្លូង**




## ៤.៣៦ អនុវិទ្យាល័យ តេជោ ថ្នល់បំបែក ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

បើតាមលទ្ធផលស្រាវជ្រាវអនុវិទ្យាល័យ នៃខេត្តឧត្តរមានជ័យនេះបានបង្ហាញឲ្យឃើញថា ស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ ៩ មានសិស្សចំនួន ១០៥ នាក់ ស្មើនិង ០៣ ថ្នាក់។ តាមការរកឃើញ

ថាមានចំនួនម៉ោងពិតប្រាកដដែលអនុវិទ្យាល័យកំពុងបង្រៀនចំនួន ៩៦ ម៉ោង ដែលមានគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិកំពុងបង្រៀននៅតាមមុខវិជ្ជានីមួយៗមានចំនួន០៤នាក់។គិតតាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវបង្រៀន៣២ ម៉ោងក្នុងមួយសប្ដាហ៍ នាំឲ្យចំនួនម៉ោងសរុប៦៤ ម៉ោង( ០២ថ្នាក់គុណនិង៣២ម៉ោង )នៅក្នុងអនុវិទ្យាល័យនេះ ត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន០៤នាក់( ៦៤ម៉ោងចែកនិង១៨ម៉ោង )។សបញ្ជាក់ថា ការប្រើប្រាស់និយាមម៉ោង ថ្នាក់ សិស្ស និងគ្រូនៃអនុវិទ្យាល័យនេះ គោរពបានតាមនិយាមនៃចំនួនគ្រូ ប៉ុន្តែចំនួន ថ្នាក់ ម៉ោង សិស្ស មិនទាន់គោរពតាមនិយាមនៅឡើយទេ។ តាមការរកឃើញចំនួនមុខវិជ្ជានៃអនុវិទ្យាល័យខាងលើនេះដែលកំពុងបង្រៀនជាក់ស្តែងមានតែ១០មុខវិជ្ជាតែប៉ុណ្ណោះ និងការប្រើប្រាស់គ្រូបង្រៀនឲ្យអស់តាមលទ្ធភាពជាក់ស្តែងរបស់សាលារៀនខាងលើនេះ។

តារាងទី៣៦៖

| ចំនួន | តាមនិយាម | ជាក់ស្តែង | លើស | ខ្វះ |
|---|---|---|---|---|
| សិស្ស | ១០៥នាក់ | ១០៥នាក់ | | |
| ថ្នាក់ | ០២ | ០៣ | | |
| ម៉ោង | ៦៤ | ៩៦ | | |
| គ្រូ | ០៤ | ០៤ | | |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៤ | ០៤ | ០០ | ០០ |

**ក្រាបទី៣៦ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង ៣៦.អនុវិទ្យាល័យ តេជោ ថ្នល់បំបែក**




## ៤.៣៧ អនុវិទ្យាល័យ ដីក្រហម ៖ស្ថិតិ សិស្ស ថ្នាក់ គ្រូ និងម៉ោង

លទ្ធផលនៃការស្រាវជ្រាវក្នុងខេត្តឧត្តរមានជ័យក្នុងអនុវិទ្យាល័យខាងលើបានបង្ហាញឲ្យឃើញថាស្ថិតិសិស្សដែលបានមកពីថ្នាក់ទី ៧ ៨ មានសិស្សចំនួន ១១០ នាក់ ។ តាមនិយាមសិស្សក្នុងមួយថ្នាក់

ត្រូវមានចំនួនសិស្ស ៤៥ ដែលកំណត់ដោយច្បាប់ និងមានចំនួនថ្នាក់នៅអនុវិទ្យាល័យខាងលើ មាន០២ ថ្នាក់( ១១០ ចែកនិង ៤៥) បើគិតទៅតាមនិយាមសិស្សក្នុងមួយថ្នាក់៣២ម៉ោងក្នុងមួយសប្តាហ៍ នាំឲ្យចំនួនម៉ោងសរុបគឺ ៦៤ ម៉ោង( ០២ថ្នាក់គុណនឹង ៣២ ម៉ោង) ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតបឋមភូមិចំនួន០៤នាក់( ៦៤ម៉ោងចែកនឹង១៨ម៉ោង)សម្រាប់គ្រប់មុខវិជ្ជាទាំងអស់( និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្តាហ៍)។ជាការជាក់ស្តែងទិន្នន័យដែលទទួលបានពីអនុវិទ្យាល័យខាងលើ មានចំនួនថ្នាក់សរុប ០២ថ្នាក់។ សម្រាប់គ្រូបង្រៀនដែលមានគុណវុឌ្ឍិ( កម្រិតមធ្យមសិក្សាបឋមភូមិ) មានតែ០៤នាក់តែប៉ុណ្ណោះដែលកំពុងបង្រៀននៅអនុវិទ្យាល័យនេះ។ តាមនិយាមជាក់ស្តែងត្រូវការគ្រូបង្រៀនកម្រិតបឋមភូមិចំនួន០៤នាក់( ០៤នាក់ស្មើរ០៤) មានន័យថាគ្រូបង្រៀនចំនួន០៤នាក់គឺគ្រប់គ្រាន់សម្រាប់អនុវិទ្យាល័យខាងលើនេះ។

តារាងទី៣៧៖

| ចំនួន | តាមនិយាម | ជាក់ស្តែង | លើស | ខ្វះ |
|---|---|---|---|---|
| សិស្ស | ១១០នាក់ | ១១០នាក់ | | |
| ថ្នាក់ | ០២ | ០២ | | |
| ម៉ោង | ៦៤ | ៦៤ | | |
| គ្រូ | ០៤ | ០៤ | | |
| គ្រូដែលមានគុណវុឌ្ឍបឋមភូមិ | ០៤ | ០៤ | ០០ | ០០ |

**ក្រាបទី៣៧ ៖គ្រូកម្រិតមធ្យមសិក្សាបឋមភូមិ តាមមុខវិជ្ជានិងតម្រូវការគ្រូបង្រៀនជាក់ស្តែង**

**៣៧.អនុវិទ្យាល័យ ដីក្រហម**



# ជំពូកទី៥ ការសន្និដ្ឋាន និងសំណូមពរ

## ៥.១.ការសន្និដ្ឋាន

ជារួម ការគណនាគ្រូ ការបែងចែកគ្រូ និងការប្រើប្រាស់គ្រូបង្រៀន តាមសាលានីមួយៗគឺជាកូនសោរគន្លឹះក្នុងការកំណត់ពីគុណភាព និងប្រសិទ្ធភាពនៃការអប់រំ។ ការអប់រំដែលមានគុណភាពគឺផ្អែកលើកត្តា នាយកសាលា គ្រូបង្រៀន កម្មវិធីសិក្សា និងសម្ភារបង្រៀន និងរៀន។ គ្រូនៅតាមអនុវិទ្យាល័យក្នុងខេត្តឧត្តរមានជ័យគឺនៅមានកម្រិតនៅឡើយ។ វិធីសាស្ត្រដែលនាយកសាលាធ្លាប់យកមកអនុវត្តតាមទម្លាប់ ដូចជាវិធីគណនាតាមផលធៀបសិស្សគ្រូ ផលធៀបសិស្សថ្នាក់ ឬការស្មានតាមតម្រូវការជាក់ស្តែងដោយគ្មានគោលការណ៍ច្បាស់លាស់ ឬរូបមន្តជាក់លាក់ជាដើម។

តាមការសិក្សាស្រាវជ្រាវបានបង្ហាញឲ្យឃើញថាស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិក្នុងខេត្តឧត្តរមានជ័យមមិនទាន់សមស្របនៅឡើយទេ៖

-ការប្រើប្រាស់និយាមសិស្សថ្នាក់ មិនត្រូវតាមគោលការណ៍(មានការលើសនិងខ្វះពីនិយាម)

-ការពង្រាយគ្រូរបស់ក្រសួងទៅតាមខេត្ត និងពីខេត្តទៅតាមស្រុក មិនទាន់បានសមស្រប(មុខវិជ្ជាខ្លះខ្វះ និង ខ្លះលើស)។ហើយករណីនេះអាចមានពីតាមស្រុកទៅតាមសាលារៀននីមួយៗផងដែរ

+បញ្ហាប្រឈមធំៗដែលកើតឡើងចំពោះការប្រើប្រាស់គ្រូមធ្យមសិក្សាបឋមភូមិមាន៖

-កង្វះគ្រូបង្រៀនឯកទេសមុខវិជ្ជាសង្គម និង វិទ្យាសាស្ត្រគឺ(កុំព្យូទ័រ) និងការផ្គត់ផ្គង់គ្រូមិនបានមិនបានឆ្លើយតបទៅតាមាករស្នើសុំ ហើយជាពិសេសការផ្លាស់ចេញមុនឆ្នាំកំណត់។

+ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀនលើការដោះស្រាយបញ្ហាប្រឈមមាន

ក.ករណីខ្វះគ្រូ សុំផ្តល់គ្រូថ្មីបន្ថែមចំលើមុខវិជ្ជាឯកទេសដែលបានស្នើរ រើសគ្រូចេញពីមូលដ្ឋាន ដំឡើងប្រាក់បៀវត្សរ៍ និងដំឡើងកាំប្រាក់

ខ.ករណីលើសគ្រូ លើកទឹកចិត្តអ្នកដែលស្ម័គ្រចិត្តទៅបម្រើការងារនៅកន្លែងខ្វះគ្រូ ប្តូរវេនក្នុងស្រុករាងរាល់បីឆ្នាំម្តង ពង្រឹងការអនុវត្តច្បាប់ក្នុងការផ្លាស់ប្តូរទីកន្លែងធ្វើការរបស់គ្រូបង្រៀន។

ខេត្តឧត្តរមានជ័យ

| ចំនួន | តាមនិយាម | ជាក់ស្តែង |
|---|---|---|
| សិស្ស | ៩៩៦៧នាក់ | ៩៩៦៧នាក់ |
| ថ្នាក់ | ២២១ | ២១៥ថ្នាក់ |
| ម៉ោង | ៧០៧២ម៉ោង | ៦៨៤៦ ម៉ោង |
| គ្រូ | ៣៩៣ នាក់ | ៤៧៥ នាក់ |
| គ្រូដែលមានគុណវុឌ្ឍិ(មធ្យមសិក្សាបឋមភូមិ) | ៨២នាក់ | |

ក្រាបគុណវុឌ្ឍិគ្រូបង្រៀនមធ្យមសិក្សាបឋភូមិ តាមមុខវិជ្ជាឯកទេស(គិតតាមតម្រូវការនិងតាមជាកស្តែង)

## ៥.២.សំណូមពរ

ក្រោយពីបានសិក្សាស្រាវជ្រាវចប់សព្វគ្រប់រួចមក តាមទស្សនៈយល់ឃើញនិងជាក់ស្តែងឃើញថា

ដើម្បីជានាបាននិរន្តភាពការបែងចែកគ្រូបង្រៀន នៅតាមអនុវិទ្យាល័យនីមួយៗ គឺធ្វើយ៉ាងណាដើម្បីឲ្យឆ្លើយតបទៅនិងតម្រូវការដែលអនុវិទ្យាល័យស្នើរសុំជាពិសេស គឺថ្នាក់មន្ទីរត្រូវប្រមើលមើលឲ្យគ្រប់ជ្រុងជ្រោយធ្វើយ៉ាងណាកុំឲ្យអនុវិទ្យាល័យនៅទីប្រជុំជនលើសគ្រូ ចំណែកអនុវិទ្យាល័យតាមជនបទនៅមិនមានគ្រូគ្រប់គ្រាន់ ឬខ្វះគ្រូ។

+ចំពោះសាលារៀន

-ធ្វើចំណោលឲ្យបានត្រឹមត្រូវពីតម្រូវការគ្រូ តាមមុខវិជ្ជាឯកទេស និងប្រើប្រាស់គ្រូដែលនៅសល់ឲ្យទៅបំពេញការងារ ឲ្យអស់លទ្ធភាព។

– រាល់ការផ្លាស់ចេញ ឬផ្លាស់ចូលគួរតែអនុវត្តទៅតាមច្បាប់អប់រំជៀសវាងកុំឲ្យមានការអន្តរាគមន៍ដែលជាហេតុធ្វើឲ្យខ្វះគ្រូទៅតាមឯកទេសនីមួយៗ។

+ចំពោះការិយាល័យអប់រំយុវជន និងកីឡាស្រុក

ត្រូវបែងចែកគ្រូបង្រៀនទៅតាមសាលាដោយធ្វើការស្រាវជ្រាវពីតម្រូវការឲ្យបានច្បាស់លាស់

+ចំពោះមន្ទីរអប់រំយុវជន និងកីឡាខេត្ត

ត្រូវបែងចែកគ្រូទៅតាមស្រុក ដោយធ្វើការស្រាវជ្រាវឲ្យបានច្បាស់លាស់ពីតម្រូវការនិងការផ្គត់ផ្គង់ត្រូវត្រួតពិនិត្យតាមដានការបែងចែកបន្តពីស្រុកទៅសាលារៀន ពិសេសត្រួតពិនិត្យមើលការអនុវត្តនិយាមនៃការប្រើប្រាស់គ្រូ និងការផ្លាស់ប្តូរគ្រូ។

+ ចំពោះក្រសួងអប់រំយុវជន និងកីឡា ៖គួរតែបណ្តុះបណ្តាលគ្រូបន្ថែមទៀត ដើម្បីបំពេញសេចក្តីត្រូវការចាំបាច់នៅក្នុងខេត្តទាំងមូល។ ហើយជាពិសេសគ្រូបង្រៀននៅក្នុងមូលដ្ឋានស្រាប់តែម្តង។

– គួរតែកុំបង្កើតអនុវិទ្យាល័យថ្មីៗ ដែលជាហេតុធ្វើឲ្យមានការខ្វះគ្រូច្រើនគ្រប់ឯកទេស។

– សាលាអនុវិទ្យាល័យនីមួយៗ ត្រូវប្រើប្រាស់និយាមសិស្សគ្រូ ជាពិសេសនិយាមសិស្សមិនឲ្យលើសពី៤៥នាក់ក្នុងមួយថ្នាក់(ព្រោះតាមការស្រាវជ្រាវបានបង្ហាញថា មានអនុវិទ្យាល័យខ្លះមានសិស្សរហូតដល់ទៅ ៦០ ទៅ ៦៥ ក្នុងមួយថ្នាក់)។

– អ្នកគ្រប់គ្រងអនុវិទ្យាល័យ ឬវិទ្យាល័យនីមួយៗ គួរតែធ្វើការគ្រប់គ្រង បែងចែកបុគ្គលិករបស់ខ្លួនឲ្យមានត្រឹមត្រូវ និងមានលក្ខណៈល្អប្រសើរតាមគោលការណ៍នៃច្បាប់អប់រំនៅកម្ពុជា។

– ត្រូវចេះលើកទឹកចិត្តបុគ្គលិកណា ដែកបំពេញការងារបានល្អ តាមរយៈការដំឡើងកាំប្រាក់ប័ណ្ណសរសើរ ជាសម្ភារប្រើប្រាស់ ឬមេដាយ។

– បង្កើនភាពស្និលស្នាលរវាងបុគ្គលិកក្រោមឱវាទ និងចេះជួយសម្រួលការលំបាកនានាដល់បុគ្គលិកកំពុងជួបប្រទះនូវបញ្ហា ដោយមោនរើសអើង ជាពិសេសគឺមានតម្លាភាពជាមួយបុគ្គលិក។

# ឯកសារយោង

១.គោលនយោបាយគ្រូបង្រៀន វិទ្យាស្ថានជាតិអប់រំ  បណ្ឌិត សៀង សុវណ្ណា
២.សីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ( នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ២០០២ )
៣.លក្ខណៈសម្បត្តិគ្រូបង្រៀន( នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ២០០២)
៤.វចនានុក្រមខ្មែរ  **សម្តេចសង្ឃរាជ ជួន ណាត** ភ្នំពេញ ព.ស ២៥១១  គ.ស ១៩៦៧
៥.ទ្រឹស្តីនៃការបណ្តុះបណ្តាលគ្រូ( សន្និបាតអប់រំ ចក្ខុវិស័យនៃកំណែទម្រង់វិស័យអប់រំនៅកម្ពុជា)
៦.វិធានការកំណែរទម្រង់ វិស័យអប់រំ យុវជន និងកីឡា( យុទ្ធសាស្រ្តកំណែទម្រង់ វិស័យអប់រំយុវជន និង កីឡា ២០១៨–២០២៣)
៧.ការគ្រប់គ្រង និងអនុវត្តផែនការយុទ្ធសាស្រ្តវិស័យអប់រំ
(ផែនការយុទ្ធសាស្រ្ត វិស័យអប់រំ ឆ្នាំ ២០១៤-២០១៨ ទំព័រ ៧៣ )
៨.ការពង្រាយគ្រូ (គោលនយោបាយស្តីពីគ្រូបង្រៀន)(លេខ:៥៣ សយក.សណន )
៩.គោលនយោបាយស្តីពីគ្រូបង្រៀន  អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ
(នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ខែកមរា ឆ្នាំ២០១៨)
១០.ចក្ខុវិស័យវិស័យនៃកំណែទម្រង់វិស័យអប់រំនៅកម្ពុជា( ការលើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀន)
១១.ការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់គ្រូបង្រៀន( លេខ:២៨ អយក.សណន)
១២.១៩៩៨ ឯកសារៈប្រវត្តិនៃការអប់រំ បឋម និងមធ្យមសិក្សានៅកម្ពុជា ១៩៩៩
១៣.សេចក្តីណែនាំស្តីពីការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកអប់រំ( លេខ ២៨ អយក.សណន)
១៤.ព្រះរាជាក្រម ៈច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា( លេខ:០៦ នស .៩៤)
១៥.សេចក្តីណែនាំស្តីពីការកំណត់និយាមប្រើប្រាស់មន្ត្រីរាជការសម្រាប់សាលាមេត្តយ្យ បឋម និងមធ្យម សិក្សាចំនេះដឹងទូទៅ និងសាលាគរុកោសល្យ
១៦.សេចក្តីណែនាំស្តីពីនិយាមប្រើបុគ្គលិកអប់រំ ខ្មែរ (លេខ:២០ អយក.សណន)
១៧.ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន(លេខ:១២៦.អនក្រ.បក)

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំយុវជន និងកីឡា
វិទ្យាស្ថានជាតិអប់រំ

**កម្រងសំណួរ កម្រិត អនុវិទ្យាល័យ**

**ប្រធានបទ៖ ស្ថានភាព ក្នុងការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យក្នុង..........**

## កម្រងសំណួរសម្រាប់សម្ភាសន៍នាយកសាលា

**វត្ថុបំណងនៃការស្រាវជ្រាវ៖**

1. រកឱ្យឃើញពីស្ថានភាពក្នុងការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀននៅតាមអនុវិទ្យាល័យ ក្នុងប្រទេសកម្ពុជា។
2. រកឱ្យឃើញនូវយុទ្ធសាស្ត្រសមស្របដើម្បីគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀននៅកម្ពុជាឱ្យមានប្រសិទ្ធភាព។

*ការរក្សាការសម្ងាត់*

*ព័ត៌មានដែលទទួលបានពីលោក លោកស្រីសម្រាប់ការវិភាគពីការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀននៅកម្ពុជា នឹងត្រូវរក្សាការសម្ងាត់។ អត្តសញ្ញាណរបស់លោក លោកស្រីមិនត្រូវបានបង្ហាញក្នុងការស្រាវជ្រាវនេះទេ។*

- ការកំណត់ពីតម្រូវការ

1. តើសាលាអនុវិទ្យាល័យរបស់លោក~លោកស្រី មានទីតាំងស្ថិតក្នុងស្រុកណា?
   - ក្នុងស្រុក....................ខេត្ត.....................ឈ្មោះសាលា...............................
2. តើសាលាអនុវិទ្យាល័យ របស់លោក~លោកស្រី មានសិស្សចំនួនប៉ុន្មាននាក់ និងចំនួនថ្នាក់ប៉ុន្មាន?
   - ថ្នាក់ទី៧៖ ចំនួនសិស្ស.......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
   - ថ្នាក់ទី៨៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
   - ថ្នាក់ទី៩៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
3. តើចំនួនបន្ទប់រៀនដែលសាលាមានជាក់ស្តែងចំនួនប៉ុន្មានបន្ទប់?
   - ចំនួនបន្ទប់រៀនសរុប.................បន្ទប់ ប្រើប្រាស់ជាក់ស្តែង.................បន្ទប់
4. តើគ្រូ ក្របខ័ណ្ឌដែលមានគុណវុឌ្ឍិ បានបណ្តុះបណ្តាលចេញពី សាលាគរុកោសល្យ សរុបចំនួនប៉ុន្មាននាក់?
   - ចំនួនសរុប.......................នាក់ ស្រី......................នាក់
5. តើគ្រូកំពុងបង្រៀនជាក់ស្តែង(មិនគិតមន្ត្រីការិយាល័យចំពោះរបបម៉ោងបន្ថែម)ចំនួនប៉ុន្មាននាក់ និងតាមមុខវិជ្ជានីមួយៗចំនួនប៉ុន្មាននាក់?(សូមជួយបំពេញតាមតារាងខាងក្រោមដែលផ្តល់ជូន)
   - ចំនួនគ្រូកំពុងបង្រៀនជាក់ស្តែង.....................នាក់ ស្រី.................នាក់

| ល.រ | មុខវិជ្ជាបង្រៀន | ចំនួនគ្រូកំពុងបង្រៀនជាក់ស្តែង | ស្រី |
|---|---|---|---|

| | | | |
|---|---|---|---|
| ១ | ភាសាខ្មែរ | | |
| ២ | ភាសាបរទេស | | |
| ៣ | គណិត | | |
| ៤ | រូប | | |
| ៥ | គីមី | | |
| ៦ | ជីវៈ | | |
| ៧ | ផែនដី | | |
| ៨ | ប្រវត្តិ | | |
| ៩ | ភូមិ | | |
| ១០ | សីលធម៌ ពលរដ្ឋ | | |
| ១១ | ICT | | |
| ១២ | អប់រំកាយនិងកីឡា | | |
| ១៣ | អប់រំសិល្បៈ | | |
| ១៤ | អប់រំសុខភាព | | |
| ១៥ | បំណិនជីវិតតាមមូលដ្ឋាន | | |
| សរុបចំនួន | | | |

6. តើក្នុងចំណោមមុខវិជ្ជាទាំងអស់ខាងលើ តើមុខវិជ្ជាណាខ្លះដែលមិនបានអនុវត្ត? បញ្ជាក់ពីមូលហេតុ ។

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

7. បើមុខវិជ្ជាមិនបានអនុវត្ត តើម៉ោងមុខវិជ្ជាទាំងនោះយកទៅបញ្ចូលជាមួយមុខវិជ្ជាណា?

.......................................................................................................................

.......................................................................................................................

.......................................................................................................................

8. តើលោក លោកស្រី ដោះស្រាយបញ្ហាលើស ឬខ្វះគ្រូយ៉ាងដូចម្តេច?

- ករណីលើស ..........................................................................................
  ..........................................................................................................
- ករណីខ្វះ ...........................................................................................

..........................................................................................................................................

- ទស្សនៈរបស់នាយកលើការជ្រើសរើសគ្រូ

1. តើអនុវិទ្យាល័យ របស់លោក~លោកស្រី  បានទទួលចំនួនគ្រូតាមការស្នើសុំដែរ ឬទេរយៈពេល៥ ឆ្នាំចុងក្រោយនេះ?

   ចំនួនគ្រូទទួលបានតាមការស្នើសុំគឺ៖

   ☐ គ្រប់ចំនួន ☐ ទទួលបានខ្លះ ☐ មិនទទួលបាន ☐ ផ្សេងៗ.................

2. តើលោក~លោកស្រី ជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ  ក្នុងការកំណត់ពីចំនួនគ្រូបង្រៀននៅតាមអនុវិទ្យាល័យ?

   ..........................................................................................................................................

   ..........................................................................................................................................

   ..........................................................................................................................................

3. តើលោក លោកស្រីផ្តល់អនុសាសន៍ ដូចម្តេចចំពោះក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីលើស និងខ្វះគ្រូ ?

   **<u>ករណីខ្វះ</u>**

   ☐ ផ្តល់គ្រូថ្មីបន្ថែម
   ☐ ផ្តល់ប្រាក់ម៉ោងបន្ថែម
   ☐ បង្កើននិយាមម៉ោងបង្រៀន ពី១៨ ម៉ោង ទៅ ២០ម៉ោង
   ☐ កែប្រែប្រព័ន្ធជ្រើសរើសគ្រូដោយយកចេញពីមូលដ្ឋាន ឬសហគមន៍
   ☐ បង្កើនគុណវុឌ្ឍិគ្រូបង្រៀនកម្រិតបឋមសិក្សា ទៅជាគ្រូអនុវិទ្យាល័យ
   ☐ ផ្សេងៗ.........................................................

   **<u>ករណីលើស</u>**

   ☐ ប្រើគោលការណ៍ប្តូរវេនសាលា ក្នុងស្រុក រយៈពេល ៣ឆ្នាំម្តង
   ☐ ផ្តល់លើកទឹកចិត្តបន្ថែម លើប្រាក់បៀវត្សន៍រៀងរាល់ខែ ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ
   ☐ លើកទឹកចិត្តបង្កើនកាំប្រាក់ មួយឆ្នាំម្តង ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ
   ☐ លើកទឹកចិត្តដោយផ្តល់ឱកាសក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ
   ☐ ផ្សេងៗ.....................................................................

*សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចូលរួមឆ្លើយសំណួរទាំងនេះ។*

*សូមអរគុណ!*

***សម្គាល់៖*** កម្រិតការពារតាមសាលានីមួយៗ សរុបចូលគ្នា វិភាគលើថ្នាក់ស្រុកនីមួយៗនិងសរុបស្រុកបានថ្នាក់ខេត្ត ធៀបនឹងនិយាម និងកម្មវិធីសិក្សាចាស់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ១៣៤ វជអ. ន៨

# លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពីការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ នៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនាឆ្នាំ ២០២០តទៅ៖

| ល.រ | គោត្តនាម-នាម | ភេទ | រាជធានី ខេត្ត |
|---|---|---|---|
| 1 | សុខ ផល្លី | ស | កណ្តាល |
| 2 | ទុន វណ្ណៈ | ប | កណ្តាល |
| 3 | វង់ ប៊ុនថាន | ប | កែប |
| 4 | គុយ សេងលី | ប | កំពង់ចាម |
| 5 | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | ឈាង សោភា | ប | កំពង់ធំ |
| 7 | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | ប៊ិត សមពីសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លាង លីលី | ប | កំពង់ស្ពឺ |
| 10 | ជិន សុធី | ប | តាកែវ |
| 11 | មាន់ ម៉ៅ | ប | តាកែវ |
| 12 | មៀង ង៉ុន | ប | ត្បូងឃ្មុំ |
| 13 | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | ឆាន ឆាត | ប | បន្ទាយមានជ័យ |

| | | | |
|---|---|---|---|
| 15 | ឱ សុផល | ប | បន្ទាយមានជ័យ |
| 16 | ថាច់ សន | ប | ប៉ៃលិន |
| 17 | សុត សំអូន | ប | ពោធិ៍សាត់ |
| 18 | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | រស់ សាយ៉ាន | ស | ព្រៃវែង |
| 21 | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | កើត មាយលក្ខិណា | ស | ភ្នំពេញ |
| 23 | សុន ឌីណា | ស | ភ្នំពេញ |
| 24 | ម៉ោញ រដ្ឋា | ស | មណ្ឌលគីរី |
| 25 | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | វួច រី | ប | សៀមរាប |
| 27 | ខូ សុខា | ប | ស្វាយរៀង |
| 28 | អ៊ុក សម្ផស្ស | ស | ស្វាយរៀង |
| 29 | វីន សុធី | ប | ឧត្តរមានជ័យ |

ថ្ងៃពុធ ៩កើត ខែស្រាពណ៍ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"

-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក
"ដើម្បីជាព័ត៌មាន"

- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
លេខ : ១៣៦ វជអ.ផក

ថ្ងៃ ពុធ ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០

**ជម្រាបជូន**
**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ដើម្បីសរសេរនិក្ខេបបទបំពេញលក្ខខណ្ឌសិក្សាតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅវិទ្យាស្ថានជាតិអប់រំ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក លោកស្រី ប្រធាន ជ្រាបថា៖ និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ សរុបចំនួន២៩នាក់ ស្រី០៧នាក់ ដែលកំពុងសិក្សានៅវិទ្យាស្ថានជាតិអប់រំត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពី ការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ប្រធាន ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើតាមការគួរ។

សូម លោក លោកស្រី ប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៀង សុវណ្ណា**

**ចម្លងជូន៖**
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក "ដើម្បីជាព័ត៌មាន"
- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ២៧៧ វជអ.ឥក

# លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

គណៈគ្រប់គ្រង និងគ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យដឹកនាំការសរសេរនិក្ខេបបទរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ស្តីពីការ "**ប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ**" នៅតាមរាជធានី ខេត្ត៖

| ល.រ | គ្រូដឹកនាំ | និស្សិត | ភេទ | ករណីសិក្សា |
|---|---|---|---|---|
| 1 | លោក លឹម វ៉ាន់ | សុខ ផល្លី | ស | កណ្តាល |
| 2 | លោក លឹម វ៉ាន់ | ទុន វណ្ណៈ | ប | កណ្តាល |
| 3 | លោក ឡុច ចាន់ថន | វង់ ប៊ុនថាន | ប | កែប |
| 4 | លោក ប៉ូ ប៊ុន្នន | គុយ សេងលី | ប | កំពង់ចាម |
| 5 | លោក ប៉ូ ប៊ុន្នន | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | លោកបណ្ឌិត អាន វ៉ូប្រាវ | ឈាង សោភា | ប | កំពង់ធំ |
| 7 | លោកបណ្ឌិត អាន វ៉ូប្រាវ | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | លោកបណ្ឌិត គួយ សូគាន | ប៊ុត សមពីសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លោកបណ្ឌិត គួយ សូគាន | លាង លីលី | ប | កំពង់ស្ពឺ |
| 10 | លោក ម៉ន មុនិន្ទ | ជិន សុធី | ប | តាកែវ |

| | | | | |
|---|---|---|---|---|
| 11 | លោក ម៉ន មុនិន្ទ | មាន់ ម៉ៅ | ប | តាកែវ |
| 12 | លោកស្រី នូ ចន្ទី | មៀង ង៉ុន | ប | ត្បូងឃ្មុំ |
| 13 | លោកស្រី នូ ចន្ទី | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | លោកបណ្ឌិត នី វឌ្ឍា | ឆាន ឆាត | ប | បន្ទាយមានជ័យ |
| 15 | លោកបណ្ឌិត នី វឌ្ឍា | ឌី សុផល | ប | បន្ទាយមានជ័យ |
| 16 | លោកបណ្ឌិត នូវ វីរ៉ា | ថាច់ សន | ប | ប៉ៃលិន |
| 17 | លោកស្រី ខែក សំណាង | សុត សំអួន | ប | ពោធិ៍សាត់ |
| 18 | លោក លន លីណា | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | លោក ចាប រតនា | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | លោក ចាប រតនា | រស់ សាយ៉ាន | ស | ព្រៃវែង |
| 21 | លោក សៀង វាសនា | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | លោក ម៉ៅ សារឿន | កើត មាយលក្ខិណា | ស | ភ្នំពេញ |
| 23 | លោក ម៉ៅ សារឿន | សុន ឌីណា | ស | ភ្នំពេញ |
| 24 | លោក សៀង វាសនា | ម៉ោញ វឌ្ឍា | ស | មណ្ឌលគីរី |
| 25 | លោកបណ្ឌិត នូវ វីរ៉ា | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | វួច វី | ប | សៀមរាប |
| 27 | លោកបណ្ឌិត ឈាង សង្វាត | ខូ សុខា | ប | ស្វាយរៀង |
| 28 | លោកបណ្ឌិត ឈាង សង្វាត | អ៊ុក សម្ផស្ស | ស | ស្វាយរៀង |
| 29 | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | វីន សុធី | ប | ឧត្តរមានជ័យ |

ថ្ងៃ អង្គារ ១៣ រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

-នាយក នាយករង នាយិការងវជអ "ដើម្បីជ្រាបជាព័ត៌មាន"

-ប្រធានដេប៉ាតឺម៉ង់-ការិយាល័យក្រោមឱវាទវជអ "ដើម្បីសហការ"

-សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារ៖ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការវជអ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត ឧត្តរមានជ័យ**

**មន្ទីរអប់រំ យុវជន និងកីឡា**

លេខ:១១៣៦..អយក៖.របប

ថ្ងៃ ១៥កើត ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ឧត្តរមានជ័យ,ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០២០

**ជម្រាបមក**

**លោកប្រធានការិយាល័យអប់រំ យុវជននិងកីឡាក្រុង-ស្រុក**

កម្មវត្ថុ: ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទ បញ្ចប់ការសិក្សារបស់និស្សិតឯកទេសវិជ្ជាជីវៈ នាយកសាលា មធ្យមសិក្សាទុតិយភូមិជំនាន់ទី៣

យោង: លិខិតលេខ ១៣៤ វជអ.ផក ចុះថ្ងៃពុធ ៩កើត ខែ ស្រាពណ៍ ឆ្នាំជូត ទោស័កព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០២០ របស់វិទ្យាស្ថានជាតិអប់រំ

តបតាមកម្មវត្ថុ និងយោងខាងលើ សូមជម្រាបលោកប្រធានការិយាល័យជ្រាបថា៖ លោក រិន សុធី និស្សិតឯកទេសវិជ្ជាជីវៈ នាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ចុះប្រមូលទិន្នន័យពាក់ព័ន្ធការងារអប់រំ នៅការិយាល័យអប់រំ យុវជន និងកីឡា និងតាមបណ្ដាគ្រឹះស្ថានមធ្យមសិក្សា -សាលាបឋមសិក្សា ក្នុងខេត្ត ឧត្តរមានជ័យដើម្បីសរសេរនិក្ខេបបទ បញ្ចប់ការសិក្សា ចាប់ពីថ្ងៃទី ២៩ ខែ មិថុនា ដល់ ៣០ ខែ តុលា ឆ្នាំ ២០២០ ។

អាស្រ័យហេតុនេះ សូមលោកប្រធានការិយាល័យ ចាត់ចែងនិងសហការ ក្នុងការផ្ដល់ព័ត៌មាន ដល់និស្សិតខាងលើឱ្យទទួលបានលទ្ធផលល្អ ។

សូមលោកប្រធានការិយាល័យ ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ ។

**ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត**

**ប៊ិច រតនា**


វិទ្យាល័យ ហ៊ុន សែន ពង្រូ
HUN SEN PONG ROU HIGH SCHOOL
ភូមិ បន្ទាយថ្មី ឃុំ ចុងកាល់ ស្រុក ចុងកាល់ ខេត្ត ឧត្តរមានជ័យ


អនុវិទ្យាល័យគោកស្ពាន
ភូមិគោកស្ពាន ឃុំក្រសាំង ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ


អនុវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន ចុងកាល់
SAMDECH TECHO HUN SENC IONG KAL PRIMARY SCHOOL
ភូមិ ចុងកាល់ ឃុំ ចុងកាល់ ស្រុក ចុងកាល់ ខេត្ត ឧត្តរមានជ័យ


ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាល័យ តេជោសែន សំរោង
ភូមិ បុរីរដ្ឋបាល សង្កាត់ សំរោង ក្រុង សំរោង ខេត្ត ឧត្តរមានជ័យ


ទីចាត់ការ
អំណោយៈ សម្តេចតេជោ ហ៊ុន សែន និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី
ព.ស ២៥៦១ - ឆ្នាំ ២០១៧